ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ផែនទីបរិវត្តកម្មខ្សែសង្វាក់តម្លៃ និងកាត់ដេរកម្ពុជា

ឆ្នាំ២០២៣-២០២៧

ថ្ងៃសុក្រ ១១ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣

អារម្ភកថា

ក្រោមកត្តាសុខសន្តិភាព ឃ្លាំងណាភាពទឹកដី សាមគ្គីភាព និងស្ថិរភាពនយោបាយ រាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំប្រទេស និងអនុវត្តគោលនយោបាយជាតិគន្លឹះៗ រួមមានជាអាទិ៍ **គោលនយោបាយ «ឈ្នះ-ឈ្នះ» យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយជាតិតាមវិស័យ និងកម្មវិធីកែទម្រង់ផ្សេងៗ** ដោយសម្រេចបានទ្ធផលមិទ្ធផលគួរជាទីមោទនៈជូនជាតិមាតុភូមិ និងប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ក្នុងរយៈពេលជិត៣ទសវត្សរ៍កន្លងមកនេះ។ មូលដ្ឋានគ្រឹះទាំងនេះជាបុរេលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន ដែលអនុញ្ញាតឱ្យកម្ពុជាប្រែមុខមាត់លើឆាកអន្តរជាតិ និងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ៧,៧% ដែលបានរួមចំណែកកាត់បន្ថយអត្រាភាពក្រីក្រ បង្កើតការងារជូនប្រជាពលរដ្ឋពេញផ្ទៃប្រទេស និងជំរុញការអភិវឌ្ឍប្រកបដោយបរិយាបន្ន។ ជាក់ស្តែង សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងការអភិវឌ្ឍ និងសមិទ្ធផលជាតិទាំងនេះបានដើរតួជាកាតាលីករ ក្នុងការផ្តល់លទ្ធភាពឱ្យកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប និងត្រូវបានធនាគារពិភពលោកទទួលស្គាល់ និងចាត់ចូលក្នុងចំណោមប្រទេស «**ឯកទេសគ្គីករកំណើន**» ទាំងប្រាំបីនៅលើពិភពលោកក្នុងឆ្នាំ២០១៥ ផងដែរ។

ជាការពិត វិស័យវាយនភណ្ឌ និងកាត់ដេរ ជាវិស័យអាទិភាពមួយ និងបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ មក វិស័យនេះបានវិវត្តខ្លួនជាបន្តបន្ទាប់ក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ច ផ្អែកលើកត្តាសុខសន្តិភាព និងស្ថិរភាពនយោបាយ ប្រាក់ឈ្នួលនិងថ្លៃផលិតកម្មប្រកួត-ប្រជែង ប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្ម និងបរិយាកាសវិនិយោគអំណោយផល ដែលជាឧត្តមភាពប្រកួតប្រជែងរបស់វិស័យនេះ។ ជារួម វិស័យនេះមានសារៈសំខាន់ណាស់សម្រាប់ការនាំចេញរបស់កម្ពុជា និងការទ្រទ្រង់ជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជា យ៉ាងហោចណាស់ពី ២,៥ ទៅ ៣លាននាក់ ដែលអាស្រ័យផលពីវិស័យនេះ។ ជាមួយហេតុផលនេះ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហា-សេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់ផ្ទាល់ជាពិសេសលើវិស័យនេះ ក្នុងន័យលើកកម្ពស់បរិយាកាសការងារ ជីវភាពរស់នៅរបស់កម្មករនិយោជិត និងការអភិវឌ្ឍវិស័យនេះទាំងមូល។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏សង្កេតឃើញថា បើទោះជាវឌ្ឍនភាពនៃវិស័យនេះជាសក្តីភាព និងជាទីមោទនៈនៃដំណើរការនៃការអភិវឌ្ឍ រចនាសម្ព័ន្ធនៃវិស័យនេះក្នុងរយៈពេលជិត៣ទសវត្សរ៍កន្លងមក ពុំទាន់មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅឡើយទេ នៅតែជាមជ្ឈមណ្ឌលផលិតកម្មដែលមានតម្លៃបន្ថែមទាប។ កម្រិតសមាហរណកម្មនៃឧស្សាហកម្មគាំទ្រនៅក្នុងដំណើរការផ្សេងទៀតនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃនៅតិចតួច ហើយកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅមិនទាន់មានលក្ខណៈប្រមូលផ្តុំបានគ្រប់គ្រាន់ ដែលទាមទារឱ្យមានការគិតគូរពីការកំណត់នូវទិសដៅអភិវឌ្ឍរួមនៃវិស័យនេះ។

ក្នុងន័យនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងក្នុងនិងខាងក្រៅដែលមានចរិតជារចនាសម្ព័ន្ធក្នុងវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចរៀបចំ និងដាក់ឱ្យអនុវត្ត «**ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧**» ក្នុងគោលបំណងប្រែក្លាយឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឱ្យកាន់តែមានភាពប្រកួតប្រជែងខ្ពស់ និងបង្កើនតម្លៃបន្ថែមក្នុងខ្សែច្រវាក់តម្លៃ ចីរភាពបរិស្ថាន ការប្រើប្រាស់

បច្ចេកវិទ្យា ជំនាញ និងសហគ្រិនភាព តាមរយៈការដាក់ចេញនូវវិធានការមុតស្រួច និងជាក់លាក់សម្រាប់អនុវត្ត សំដៅគាំទ្រដល់ការអនុវត្ត «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ ២០២២-២០២៧**» ដែលរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ កន្លងមក។ ដើម្បីសម្រេចគោលបំណងខាងលើ ផែនទីបរិវត្តកម្មនេះបានដាក់ចេញនូវឃ្លាស់យុទ្ធសាស្ត្រចំនួន៤ រួមមាន ១-ល្បាយផលិតផលនិងពាណិជ្ជកម្មអន្តរជាតិ ២-ជំនាញនិងបច្ចេកវិទ្យា ៣-ចីរភាពនិងនវានុវត្តន៍ និង ៤-ហេដ្ឋារចនាសម្ព័ន្ធនិងអភិបាលកិច្ច។ បន្ថែមពីនេះ ខ្ញុំក៏សូមគូសបញ្ជាក់ផងដែរថា ផែនទីបរិវត្តកម្មនេះ ត្រូវបានរៀបចំឡើងដោយអនុលោមតាមឧត្តមានុវត្តន៍អន្តរជាតិ និងក្នុងការលើកកម្ពស់វិស័យអាទិភាពចម្បងៗ និងត្រូវតម្រង់ទិស ព្រមទាំងទទួលបានធាតុចូលពីក្រសួងស្ថាប័នមានសមត្ថកិច្ច ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានស្រាវជ្រាវ គ្រឹះស្ថានបណ្តុះបណ្តាល និងវិស័យឯកជន។ បន្ថែមពីនេះ ត្បិតក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តត្រូវបានកំណត់ត្រឹមឆ្នាំ២០២៧ ក៏ពិតមែនពិត ប៉ុន្តែផែនទីបរិវត្តកម្មនេះចាត់ទុកជាឯកសាររស់ដែលមានចរិតប្រតិបត្តិការ និងអាចត្រូវកែសម្រួលជាយថាហេតុដោយរាជរដ្ឋាភិបាល ដើម្បីធានាសង្គតិភាព និងភាពប្រាកដនិយមទៅតាមការវិវឌ្ឍជាក់ស្តែង។

ការអនុវត្តផែនទីបរិវត្តកម្មឧស្សាហកម្មនេះ នឹងចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យនេះ ដែលមានចរិតជារចនាសម្ព័ន្ធ និងផ្តល់លទ្ធភាពឱ្យកម្ពុជាត្រៀមខ្លួនចាប់យកកាលានុវត្តភាព ដើម្បីជំរុញការអភិវឌ្ឍនៃវិស័យនេះ ក្នុងន័យគាំទ្រការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ប្រកបដោយចីរភាពនិងបរិយាបន្ន។ មិនត្រឹមតែប៉ុណ្ណោះ ការសម្រេចបាននូវគោលបំណងនៃផែនទីបរិវត្តកម្មនេះនឹងចូលរួមចំណែកគាំទ្រនិងបំពេញបន្ថែមជាមួយការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំខាន់ផ្សេងទៀត រួមមានជាអាទិ៍ ១-យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ២-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ៣-គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ៤-គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ ៥-គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ៦-យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៩-២០២៣ ៧-ក្របខណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១-២០២៣ និង ៨-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ និងការកោតសរសើរ ជូនចំពោះ**អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.)** ដែលបានដឹកនាំសម្របសម្រួលនិងរៀបចំផែនទីបរិវត្តកម្មនេះឡើង ដោយបានធ្វើការងារយ៉ាងជិតស្និទ្ធ និងសកម្មជាមួយតួអង្គពាក់ព័ន្ធសំខាន់ៗ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ បន្ថែមពីនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា (ADB) ដែលបានសហការយ៉ាងជិតស្និទ្ធ និងផ្តល់ការគាំទ្រនានាទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំនិងដាក់ឱ្យអនុវត្តផែនទីបរិវត្តកម្មនេះ។

ជាចុងក្រោយ ជាមួយនឹងការអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការនូវផែនទីបរិវត្តកម្មនេះ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** នឹងទទួលបន្ទុកដឹកនាំសម្របសម្រួលអន្តរក្រសួងស្ថាប័ន ជំរុញ តាមដាននិងត្រួតពិនិត្យលើការអនុវត្តរាល់វិធានការ ដែលបានដាក់ចេញក្នុងផែនទីបរិវត្តកម្មនេះឱ្យបានជោគជ័យ និងមានប្រសិទ្ធភាព ព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល។ ក្នុងន័យនេះ ខ្ញុំជឿជាក់ថា គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនឹង

ចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ ប្រកបដោយការប្តេជ្ញាចិត្ត បុរេសកម្ម អន្តរសកម្ម និងស្មារតីទទួលខុសត្រូវក្នុងការអនុវត្តផែនទីបរិវត្តកម្មនេះ និងប្រកាន់ភ្ជាប់នូវអភិក្រមនិងអនុសាសន៍ ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញកន្លងមក «**ផ្ទុះកញ្ចក់ ទ្ធតធីក ជុំសក្តែល ព្យាឃាល និង ឫកាត់**» និង «**កែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីពង្រឹងឯកភាពជ្យ និងអធិបតេយ្យភាពជាតិ**» សំដៅចូលរួមចំណែកក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់កម្ពុជា ការឆ្លើយតបទៅនឹងការរំពឹងទុក និងតម្រូវការរបស់ប្រជាជន និងការកសាងមូលដ្ឋានគ្រឹះចាំបាច់ ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និង ២០៥០។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៣

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ខ្លឹមសារសង្ខេប

ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ជាវិស័យអាទិភាពដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលឆ្លុះបញ្ចាំងក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រគន្លឹះៗនានាដែលរាជរដ្ឋាភិបាលបានដាក់ចេញ។ ជាក់ស្តែង គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការកាលពីខែសីហា ឆ្នាំ២០១៥ ក្នុងគោលបំណងពន្លឿនការអភិវឌ្ឍឧស្សាហកម្មកម្ពុជា ដែលក្នុងនោះ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ជាវិស័យអាទិភាពមួយ ដើម្បីជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារដល់ប្រជាពលរដ្ឋកម្ពុជា។

ជារួម វិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប បានបង្កើតការងារច្រើនជាងគេនៅកម្ពុជា ដោយមានកម្មករនិយោជិតជាង៨០ម៉ឺននាក់បម្រើការក្នុងវិស័យនេះ ក្នុងនោះ ស្ត្រីមានចំនួនលើស ៨0%។ វិស័យនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារ និងការបង្កើនសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត ដែលផ្តត់ផ្គង់ជីវភាពរបស់កម្មករនិងប្រជាពលរដ្ឋដែលរស់នៅជុំវិញតំបន់រោងចក្រ។ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់កម្ពុជា ដោយរួមចំណែក ៥៧% នៃការនាំចេញទំនិញសរុបក្នុងឆ្នាំ២០១៩ និងប្រមាណ ៣៣% នៃសកម្មភាពផលិតកម្មទូទាំងប្រទេស។ ក្នុងឆ្នាំ២០១៩ ការនាំចេញផលិតផលវាយនភណ្ឌ និងកាត់ដេររបស់កម្ពុជាមានទំហំ៨,៥ពាន់លានដុល្លារអាម៉េរិក ដែលមានអត្រាកំណើន ១៣% ជាមធ្យមក្នុងមួយឆ្នាំក្នុងរយៈពេលដប់ឆ្នាំ (ឆ្នាំ២០០៩ ដល់ ២០១៩) ដែលភាគច្រើនជាផលិតផលសម្លៀកបំពាក់ ខណៈដែលការនាំចេញផលិតផលវាយនភណ្ឌមានតិចតួចប៉ុណ្ណោះ។ ក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច និងជាប្រទេសសមាជិកអាស៊ាន កម្ពុជាទទួលបានការអនុគ្រោះផ្នែកទីផ្សារ និងពន្ធ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនផងដែរ។

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ បានបង្កឱ្យមានភាពរអាក់រអួលដល់សកម្មភាពពាណិជ្ជកម្ម និងប្រព័ន្ធអេកូឡូស៊ីទាំងមូលនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ។ ជាក់ស្តែង រោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា បានទទួលរងផលប៉ះពាល់ពីវិបត្តិនេះ ដោយសារភាពមិនច្បាស់លាស់នៃការបញ្ជាទិញ វិបត្តិសន្ទនីយភាព (Liquidity crunch) និងវិធានការបិទខ្ទប់និងរឹតត្បិតការធ្វើចរាចរណ៍មនុស្សនិងទំនិញ ដែលប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់។ រោងចក្រជាច្រើនបានកាត់បន្ថយផលិតកម្មរបស់ខ្លួន ដែលនាំឱ្យកម្មករជាច្រើនត្រូវបានកាត់បន្ថយចំនួនម៉ោងធ្វើការ ឬបាត់បង់ការងារ។ ស្របតាមការអូសបន្លាយនៃវិបត្តិនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការមួយចំនួនដើម្បីបន្ធូរបន្ថយផលប៉ះពាល់នៃវិបត្តិនេះ រួមមានកម្មវិធីសាច់ប្រាក់ពលកម្ម ការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ ការពង្រឹងការទទួលបានការគាំពារសង្គម និងពង្រីកវិសាលភាពនៃការទទួលបានការគាំពារសង្គមដល់ក្រុមប្រជាជនផ្សេងទៀត ទាំងវិស័យសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធ ការផ្តល់ការលើកលែងឬអនុគ្រោះផ្នែកពន្ធដារ និងវិធានការមួយចំនួនទៀតដើម្បីជួយសម្រួលបន្ទុកដល់សហគ្រាសធុនតូចនិងមធ្យម តាមរយៈជម្រើសសហហិរញ្ញប្បទាន និងការធានាឥណទាន។

សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) ត្រូវបាន

បង្កើតឡើងក្នុងឆ្នាំ១៩៩៦ ក្នុងនាមជាស្ថាប័នពាណិជ្ជកម្មកំពូលមួយ ដែលតំណាងឱ្យសមាជិកនៃឧស្សាហកម្មវាយ-នភណ្ឌ និងកាត់ដេរនៅក្នុងប្រទេសកម្ពុជា។ សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា មានសមាជិកជាង ៦០០ ដែលគ្របដណ្ដប់ ២៨% នៃចំនួនរោងចក្រវាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើងនៅកម្ពុជាទូទាំងប្រទេស។ ជាការអង្កេត ប្រព័ន្ធអេកូឡូស៊ីនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា មានការចូលរួមពីតួអង្គពាក់ព័ន្ធជាច្រើន។ គិតមកត្រឹមឆ្នាំ២០២០ មានគ្រឹះស្ថានបណ្ដុះបណ្ដាលចំនួន ១០៤ ដែលបានចុះបញ្ជីផ្ទាល់ការជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្នុងនោះរួមមានគ្រឹះស្ថានសាធារណៈចំនួន ៣៧ គ្រឹះស្ថានឯកជនចំនួន ៤១ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៦ ដែលផ្ដល់ការបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជា។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បាននិងកំពុងផ្ដល់ការលើកទឹកចិត្តនានាដល់វិស័យនេះនាពេលកន្លងមកផងដែរ។

ទោះជាយ៉ាងនេះក្តី ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ប្រមាណ ៧០% ស្ថិតក្រោមទម្រង់ជាផលិតកម្មកាត់ដេរនិងតម្រឹម (ឬហៅកាត់ថា ស៊ីអិមធី ឬ CMT) ដែលមានភាពសាមញ្ញ និងមានតម្លៃបន្ថែមទាប។ សកម្មភាពដទៃទៀតនៅក្នុងខ្សែច្រវាក់តម្លៃ ដូចជាផលិតកម្មកប្បាស សរសៃធម្មជាតិជាដើម មានកម្រិតតិចតួចប៉ុណ្ណោះ។ ទន្ទឹមនេះ សមាហរណកម្មប្រតិគមន៍ (Backward Integration) នៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់-ដេរកម្ពុជា ដូចជាដំណើរការត្បាញអំបោះហុង ការផលិតក្រណាត់ជាដើម មានសកម្មភាពតិចតួចនៅឡើយ ដែលនាំឱ្យកម្ពុជាត្រូវពឹងផ្អែកខ្លាំងលើការនាំចូលវត្ថុធាតុដើម និងគ្រឿងម៉ាស៊ីនពីបរទេស។ ជាក់ស្តែង ក្នុងឆ្នាំ២០១៩ ប្រមាណ ៩០% នៃបរិមាណផ្គត់ផ្គង់ក្រណាត់ត្រូវបាននាំចូលពីបរទេស ជាពិសេស ចិន និងវៀតណាម។ ទន្ទឹមនេះ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា នៅមានបញ្ហាប្រឈមមួយចំនួនទៀតដូចជា កង្វះកម្លាំងពលកម្មជំនាញ ផលិតភាពទាប ការយកចិត្តទុកដាក់លើបញ្ហាចីរភាពបរិស្ថាននៅមានកម្រិត ការចាប់យកបច្ចេកវិទ្យា និងនវានុ-វត្តន៍ថ្មីៗនៅមានកម្រិត កង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។

បរិវត្តកម្មឧស្សាហកម្មក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរកម្ពុជា មានភាពផុសផុលនិងមានសន្ទុះកើនឡើងខ្លាំងក្នុងអំឡុងពេលនិងក្រោយពេលនៃវិបត្តិកូវីដ-១៩។ ការរាតត្បាតនៃជំងឺកូវីដ-១៩ បានពន្លឿនបរិវត្តកម្មឧស្សាកម្មនិងគំនិតផ្ដួចផ្ដើមថ្មីៗ ដែលរួមមានការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើចីរភាពបរិស្ថាន បដិវត្តកម្មឧស្សាហកម្មជំនាន់ ៤.០ និងការទទួលយកបច្ចេកវិទ្យា។ រំហួរពាណិជ្ជកម្មអន្តរជាតិនឹងមានការផ្លាស់ប្តូរ ដោយ-សារតែការកើនឡើងនៃចរន្តផ្លាស់ប្តូរទីតាំងផលិតកម្មមកកាន់តែជិតប្រទេសដើមកំណើត និងកិច្ចខិតខំប្រឹងប្រែងដោយបណ្ដាប្រទេសផលិតផលិតផលវាយនភណ្ឌ និងកាត់ដេរធំៗ ដើម្បីពង្រឹងស្វ័យភាពនៃខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងប្រទេសខ្លួនផ្ទាល់។ ស្ថានភាពនៃការវិវឌ្ឍផ្នែកពាណិជ្ជកម្ម ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីវៀតណាម-សហភាពអឺរ៉ុបជាដើម អាចនឹងមានផលប៉ះពាល់ដល់ពាណិជ្ជកម្មផលិតផលវាយនភណ្ឌ និងកាត់ដេរកម្ពុជាផងដែរ។ ម្យ៉ាងវិញទៀត កត្តាខាងក្នុងដូចជាសម្ពាធនៃការកើនឡើងប្រាក់ឈ្នួល ផលិតភាពទាប បញ្ហាផ្ដត់គំនិតក្នុងចំណោមយុវជនទៅលើវិស័យវាយនភណ្ឌ និងកាត់ដេរ ការយកចិត្តទុកដាក់តិចតួចទៅលើបញ្ហាចីរភាពបរិស្ថានរបស់វិស័យឯកជនជាដើម ក៏នៅតែជាបញ្ហាប្រឈមដែលរាជរដ្ឋាភិបាលបាននឹងកំពុងដោះស្រាយក្នុងន័យពន្លឿនការអភិវឌ្ឍឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា។

ក្នុងន័យនេះ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ឆ្នាំ២០២៣-២០២៧ មានភាពចាំបាច់សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ដើម្បីបង្កើនភាពប្រកួត-ប្រជែង និងធានានូវចីរភាពកំណើនរបស់វិស័យនេះ។ ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧ ត្រូវបានរៀបចំដោយផ្អែកលើការវាយតម្លៃលើវិស័យវាយនភណ្ឌ និងកាត់ដេរសកល និងកម្ពុជា និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧។ ផែនទីបរិវត្តកម្មនេះ ដើរតួជាឯកសារប្រតិបត្តិគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧ តាមរយៈការដាក់ចេញនូវវិធានការគន្លឹះជាយុទ្ធសាស្ត្រជាក់លាក់សម្រាប់រាជរដ្ឋាភិបាលនិងវិស័យឯកជន។

ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧ មានគោលបំណងប្រែ-ក្លាយឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ឱ្យកាន់តែមានឧត្តមភាពប្រកួតប្រជែង ដោយផ្តោតលើតម្លៃបន្ថែម ចីរ-ភាពបរិស្ថាន ការប្រើប្រាស់បច្ចេកវិទ្យា ជំនាញ និងសហគ្រិនភាព។ ដើម្បីសម្រេចគោលបំណងខាងលើ ផែនទីបរិវត្តកម្មនេះបានដាក់ចេញនូវឃ្នាស់យុទ្ធសាស្ត្រចំនួន ៤ រួមមានល្បាយផលិតផលនិងពាណិជ្ជកម្មអន្តរជាតិ ជំនាញនិងបច្ចេកវិទ្យា ចីរភាពនិងនវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធនិងអភិបាលកិច្ច។

ដើម្បីធានានូវការអនុវត្តផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧ ប្រកបដោយភាពជោគជ័យ ចាំបាច់ត្រូវមានការរៀបចំយន្តការស្ថាប័នសម្រាប់តាមដាន និងវាយតម្លៃការអនុវត្ត វិធានការ។ ជាកត្តាសត្យានុម័ត កិច្ចសម្របសម្រួលអន្តរស្ថាប័នជាមួយតួអង្គពាក់ព័ន្ធជាកត្តាចាំបាច់សម្រាប់ការអនុវត្តផែនទីបរិវត្តកម្មនេះដោយជោគជ័យ។ ការរៀបចំយន្តការស្ថាប័នប្រកបដោយកិច្ចសម្របសម្រួល ដែលមានប្រសិទ្ធភាព និងមានភាពប្រទាក់ក្រឡា ជាបុរេលក្ខខណ្ឌដើម្បីឈានទៅសម្រេចគោលបំណងនៃផែនទីបរិវត្តកម្មនេះ។ ដោយសារផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧ នេះ មានលក្ខណៈជាឯកសារប្រតិបត្តិសម្រាប់បម្រើឱ្យការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧ រាជរដ្ឋាភិបាលនឹងប្រើប្រាស់យន្តការស្ថាប័នដែលមានស្រាប់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧ រួមបញ្ចូលទាំងក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ដែលមានសមាសភាពពីតំណាងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ជំនាញការឯករាជ្យ តំណាងសមាគមនិងសហជីព ដើម្បីផ្តល់នូវប្រភពធាតុចូលមួយបន្ថែមទៀត សំដៅជួយសម្រួលដល់ការអនុវត្តផែនទីបរិវត្តកម្មនេះឱ្យបានគ្រប់ជ្រុងជ្រោយផងដែរ។

មាតិកា

អារម្ភកថា i

ខ្លឹមសារសង្ខេប iv

មាតិកា vii

បញ្ជីអក្សរកាត់ ix

បញ្ជីតារាង xi

បញ្ជីរូបភាព xi

បញ្ជីប្រអប់ xi

១-បរិការណ៍នៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា **១**

១.១-សាវតារ និងស្ថានភាពបច្ចុប្បន្ន ១

១.២-រចនាសម្ព័ន្ធ និងខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ២

១.៣-សកម្មភាពពាណិជ្ជកម្ម ៦

១.៣.១-ការនាំចេញ និងទីផ្សារនាំចេញសំខាន់ៗ ៦

១.៣.២-ការនាំចូល និងទីផ្សារនាំចូលសំខាន់ៗ ៧

១.៣.៣-កិច្ចព្រមព្រៀងពាណិជ្ជកម្ម ៧

១.៤-ប្រព័ន្ធអេកូឡូស៊ីគាំទ្រ ៩

១.៤.១-ការអភិវឌ្ឍជំនាញ និងការអប់រំកម្រិតខ្ពស់ ៩

១.៤.២-សមាគមពាណិជ្ជកម្ម ១០

១.៤.៣-រាជរដ្ឋាភិបាល ១១

២-បញ្ហាប្រឈម និងកាលានុវត្តភាព **១៣**

២.១-កម្លាំងពលកម្មជំនាញ ១៤

២.១.១-កម្មករនិយោជិតផ្នែកផលិតកម្ម ១៤

២.១.២-មុខដំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ និងអ្នកគ្រប់គ្រងថ្នាក់កណ្តាល ១៦

២.២-ល្បាយផលិតផល ១៨

២.៣-ផលិតភាព ១៩

២.៤-ចីរភាពបរិស្ថាន ២១

២.៥-ការចាប់យកបច្ចេកវិទ្យា ២៣

២.៦-ហេដ្ឋារចនាសម្ព័ន្ធ ២៣
២.៧-ពាណិជ្ជកម្ម និងអន្តរជាតូបនីយកម្ម ២៤
២.៨-នវានុវត្តន៍ ២៥
២.៩-អភិបាលកិច្ច ២៦
៣-ឃ្លាស់ និងវិធានការយុទ្ធសាស្ត្របរិវត្តកម្មខ្វះសក្ដានុពលកម្ចាយនតណ្ឌ និងកាត់ដេរ ២៦
៣.១-គោលបំណង ២៧
៣.២-ឃ្លាស់យុទ្ធសាស្ត្រ និងវិធានការយុទ្ធសាស្ត្រ ២៨
៣.២.១-ល្បាយផលិតផល និងពាណិជ្ជកម្មអន្តរជាតិ ២៨
៣.២.២-ជំនាញ និងបច្ចេកវិទ្យា ៣០
៣.២.៣-ចីរភាព និងនវានុវត្តន៍ ៣៤
៣.២.៤-ហេដ្ឋារចនាសម្ព័ន្ធ និងអភិបាលកិច្ច ៣៧
៤-ការរៀបចំយន្តការស្ថាប័នសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តវិធានការ ៤០
៤.១-រចនាសម្ព័ន្ធនៃការរៀបចំយន្តការស្ថាប័ន ៤១
៤.២-ក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រ ៤២
៤.៣-ក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ៤២
៥-សេចក្ដីសន្និដ្ឋាន ៤៣
ឧបសម្ព័ន្ធ៖ ឃ្លាស់យុទ្ធសាស្ត្រ និងវិធានការយុទ្ធសាស្ត្រ ៤៦

បញ្ជីអក្សរកាត់

	អក្សរពេញជាភាសាអង់គ្លេស	អក្សរពេញជាភាសាខ្មែរ
CAMFEBA	Cambodian Federation of Employers and Business Associations	សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
CDC	Council for the Development of Cambodia	ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
CCFTA	Cambodia-China Free Trade Agreement	កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន
CKFTA	Cambodia-Korea Free Trade Agreement	កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ
CMT	Cut, Make, and Trim	ស៊ីអិមធី ឬកាត់ដេរនិងតម្រឹម
CGTI	Cambodian Garment Training Institute	វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា
CSEZB	Cambodian Special Economic Zone Board	គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
EBA	Everything But Arm	ប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ
EIA	Environmental Impact Assessment	ការវាយតម្លៃផលប៉ះពាល់បរិស្ថាន
GFT	Cambodia Garment, Footwear and Travel Goods Sector Development Strategy 2022-2027	យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧
GSP	Generalised System of Preferences	ប្រជាជាតិក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ
FOB	Free on Board	អែហ្វអូប៊ី
IDP	Cambodia Industrial Development Policy 2015-2025	គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥
ILO	International Labor Organization	អង្គការអន្តរជាតិខាងការងារ
ITM	Industrial Transformation Map	ផែនទីបំរែបំរួលកម្មឧស្សាហកម្ម
NTB	National Training Board	គណៈកម្មាធិការជាតិបណ្តុះបណ្តាល
MFA	Multi-Fiber Arrangement	កិច្ចព្រមព្រៀងពាណិជ្ជកម្មលើផលិតផលពហុសរសៃ
MFNs	Most Favored Nations	ប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត
MMF	Man Made Fibers	សរសៃប្រភេទអ៊ីមអ៊ីមអ៊ីហ្ម
RCEP	The Regional Comprehensive Economic	កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុង-

	Partnership	ជ្រើយក្នុងតំបន់
SEZ	Special Economic Zone	តំបន់សេដ្ឋកិច្ចពិសេស
SSC	Sector Skills Council	ក្រុមប្រឹក្សាជំនាញតាមវិស័យ
STEM	Science, Technology, Engineering, and Mathematics	ការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
TAFTAC	Textile, Apparel, Footwear, and Travel Goods Association in Cambodia	សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា
T&A	Textile and Apparel	វាយនភណ្ឌ និងកាត់ដេរ
TVET	Technical and Vocational Education and Training	ការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ

បញ្ជីតារាង

តារាងទី១	ខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរវៀតណាម បង់ក្លាដែស និងឥណ្ឌា	៤
តារាងទី២	ទីតាំងរោងចក្រវាយនភណ្ឌ និងកាត់ដេរក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០២០	៥
តារាងទី៣	អត្រាអក្ខរកម្មនៅកម្ពុជា និងប្រទេសដែលជាដៃគូប្រកួតប្រជែងក្នុងតំបន់អាស៊ី	១៥
តារាងទី៤	កម្រិតនៃផលិតភាពក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេររបស់កម្ពុជា ធៀបនឹងបណ្តាលប្រទេសមួយចំនួន	១៩

បញ្ជីរូបភាព

រូបទី១	ខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ	៣
រូបទី២	គោលបំណង និងឃ្នាស់យុទ្ធសាស្ត្រ នៃផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា	២៧
រូបទី៣	រចនាសម្ព័ន្ធនៃការរៀបចំយន្តការស្ថាប័ន	៤១

បញ្ជីប្រអប់

ប្រអប់ទី១	វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែង ដែលផ្តល់ដោយគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជា	៩
ប្រអប់ទី២	គោលនយោបាយជាតិស្តីពីការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥	១០

១-បរិការណ៍នៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា

១.១-សាវតារ និងស្ថានភាពបច្ចុប្បន្ន

ការវិនិយោគលើឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា បានចាប់ផ្តើមនៅដើមទសវត្សរ៍ឆ្នាំ ១៩៩០[1] ដោយសារកត្តាចម្បងចំនួន២ គឺការទទួលបានកូតាពីទីផ្សារសហរដ្ឋអាម៉េរិកក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មលើផលិតផលពហុសរសៃ (Multi-Fiber Arrangement-MFA) នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ និងភាពសម្បូរនៃកម្លាំងពលកម្មក្នុងស្រុកដែលមានប្រាក់ឈ្នួលទាប។

ដោយសារការឡើងថ្លៃនៃប្រាក់ឈ្នួលកម្លាំងពលកម្ម និងការរឹតត្បិតកូតានាំចេញ បណ្តាខ្លាសេដ្ឋកិច្ចអាស៊ីទាំងបួន រួមមានហុងកុង សិង្ហបុរី កូរ៉េខាងត្បូង និងតៃវ៉ាន់ បានអនុវត្តយុទ្ធសាស្ត្រផលិតកម្មត្រីកោណ (Triangle Manufacturing) ដោយទទួលការបញ្ជាទិញពីទីផ្សារសហរដ្ឋអាម៉េរិក និងទីផ្សារអន្តរជាតិដទៃទៀត និងផលិតផលិតផលសម្រេច តាមរយៈខ្សែច្រវាក់ផលិតកម្មនៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ រួមទាំងកម្ពុជាផងដែរ។ វត្ថុធាតុដើមសម្រាប់ការផលិតសម្លៀកបំពាក់ត្រូវបាននាំចូលពីបណ្តាប្រទេសខ្លាំសេដ្ឋកិច្ចទាំងបួនខាងលើ ខណៈដែលផលិតផលសម្លៀកបំពាក់ ត្រូវបាននាំចេញពីប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក និងទីផ្សារអន្តរជាតិដទៃទៀតដោយផ្ទាល់តែម្តង ដោយប្រើកូតាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ជាអ្នកផលិតផ្ទាល់។

ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាបានចាប់ផ្តើមកើនឡើងគួរឱ្យកត់សម្គាល់ចាប់ពីឆ្នាំ១៩៩៧ បន្ទាប់ពីកម្ពុជាទទួលបានឋានៈជាប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត (Most Favored Nations ឬ MFNs) និងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ (Generalised System of Preferences ឬ GSP) ពីបណ្តាប្រទេសអភិវឌ្ឍន៍នានា រួមមានសហរដ្ឋអាម៉េរិក សហភាពអ៊ីរ៉ុប និងប្រទេសជប៉ុនជាដើម។ ក្នុងឆ្នាំ២០០១ កម្ពុជាទទួលបានលក្ខខណ្ឌអនុគ្រោះទីផ្សារមួយផ្សេងទៀត សម្រាប់ការនាំចេញទៅសហភាពអ៊ីរ៉ុប ក្រោមគំនិតផ្តួចផ្តើមប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ (Everything But Arms ឬ EBA) ដែលផ្តល់ការលើកលែងពន្ធគយ និងការកំណត់កូតា។ ការទទួលបានលក្ខខណ្ឌអនុគ្រោះផ្នែកទីផ្សារ ជាពិសេសពីទីផ្សារសហរដ្ឋអាម៉េរិក និងសហភាពអ៊ីរ៉ុប បានដើរតួយ៉ាងសំខាន់សម្រាប់ជំរុញកំណើន នៃការនាំចេញផលិតផលសម្លៀកបំពាក់កម្ពុជា។ កត្តាទីតាំងយុទ្ធសាស្ត្ររបស់កម្ពុជាស្ថិតនៅចំកណ្តាលតំបន់អាស៊ីអាគ្នេយ៍ ក៏បានបង្កភាពងាយស្រួលក្នុងការបញ្ជ្រៀតខ្លួនទៅក្នុងទីផ្សារសកលលោក តាមរយៈកំពង់ផែសមុទ្រខេត្តព្រះសីហនុ ព្រមទាំងបានដើរតួជាទីតាំងយុទ្ធសាស្ត្រក្នុងការលើកកម្ពស់តម្រូវការផលិតផលរបស់កម្ពុជានៅក្នុងតំបន់អាស៊ីផងដែរ។

---

[1] ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា បានចាប់ផ្តើមសកម្មភាពក្នុងសម័យអាណានិគមបារាំង ប៉ុន្តែផលិតកម្មសម័យនោះមានទ្រង់ទ្រាយតូចនៅឡើយ។ សកម្មភាពខ្នាតឧស្សាហកម្មទ្រង់ទ្រាយធំបានចាប់ផ្តើមនៅក្នុងសម័យសង្គមរាស្ត្រនិយម នៅពេលដែលសហគ្រាសរដ្ឋឈ្មោះ SONATEX ត្រូវបានបង្កើត។ ប៉ុន្តែ វិស័យនេះបានទទួលរងការបំផ្លិចបំផ្លាញដោយសារសង្គ្រាមស៊ីវិលរហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០។ ក្នុងឆ្នាំ១៩៩៣ កម្ពុជាបានរៀបចំការបោះឆ្នោតសកលក្រោមការគាំទ្រពី UNTAC និងចាប់ផ្តើមអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ។

ផលិតផលវាយនភណ្ឌ និងកាត់ដេរកម្ពុជា ភាគច្រើនជាផលិតផលសម្រេច។ ជាទូទៅ រោងចក្រកាត់ដេរនៅកម្ពុជា ស្ថិតក្រោមទម្រង់ជាផលិតកម្មកាត់ដេរនិងតម្រឹម (ហៅកាត់ថា ស៊ីអ៊ីមធី ឬ CMT) ដែលសកម្មភាពកាត់-ដេរសម្លៀកបំពាក់ធ្វើនៅក្នុងស្រុក ឯវត្ថុធាតុដើម បច្ចេកវិទ្យាផលិត និងគ្រឿងម៉ាស៊ីនត្រូវបាននាំចូលពីបរទេស។ រោងចក្រកាត់ដេរភាគច្រើនជាកម្មសិទ្ធិរបស់វិនិយោគិនបរទេស ជាពិសេសមកពីប្រទេសចិន ហុងកុង ម៉ាឡេស៊ី ភូវ៉េខាងត្បូង ថៃ និងសិង្ហបុរី។ ក្នុងនោះ ការវិនិយោគទុនពីប្រទេសចិនមានចំណែកធំជាងគេនៅកម្ពុជា គឺបានកើនឡើងពី ១៣,៨% នៃទុនវិនិយោគសរុបក្នុងឆ្នាំ១៩៩៤ រហូតដល់ ៦៦,៧% ក្នុងឆ្នាំ២០១៩។

ទិដ្ឋភាពជារួម វិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប បានបង្កើតការងារច្រើនជាងគេនៅកម្ពុជា ដោយមានកម្មករជាង ៨០ ម៉ឺននាក់ បម្រើការក្នុងវិស័យនេះ ក្នុងនោះ កម្មករស្ត្រីមានចំនួនលើស ៨០%[2]។ វិស័យនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារ និងការបង្កើនសកម្មភាពសេដ្ឋកិច្ចផ្សេងទៀតដែលផ្តត់ផ្គង់ដល់ជីវភាពរបស់កម្មកររស់នៅជុំវិញតំបន់រោងចក្រ។

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ បានបង្កឱ្យមានភាពរអាក់រអួលដល់សកម្មភាពពាណិជ្ជកម្ម និងប្រព័ន្ធអេកូឡូស៊ីទាំងមូលនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ។ ជាក់ស្តែង រោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា បានទទួលរងផលប៉ះពាល់ពីវិបត្តិនេះ ដោយសារភាពមិនច្បាស់លាស់នៃការបញ្ជាទិញ វិបត្តិសន្ទនីយភាព (Liquidity crunch) និងវិធានការបិទខ្ទប់និងរឹតត្បិតការធ្វើចរាចរណ៍មនុស្សនិងទំនិញ ដែលប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់។ រោងចក្រជាច្រើនបានកាត់បន្ថយផលិតកម្មរបស់ខ្លួន ដែលនាំឱ្យកម្មករជាច្រើនត្រូវបានកាត់-បន្ថយចំនួនម៉ោងធ្វើការ ឬបាត់បង់ការងារ។ ដោយសារការអូសបន្លាយនៃវិបត្តិនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការមួយចំនួន ដើម្បីបន្ធូរបន្ថយផលប៉ះពាល់នៃវិបត្តិនេះ រួមមានកម្មវិធីសាច់ប្រាក់ពលកម្ម ការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ ការពង្រឹងការទទួលបានការគាំពារសង្គម និងពង្រីកវិសាលភាពនៃការទទួលបានការគាំពារសង្គមដល់ក្រុមប្រជាជនផ្សេងទៀត ទាំងវិស័យសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធ ការផ្តល់ការលើកលែងឬអនុគ្រោះផ្នែកពន្ធដារ និងវិធានការមួយចំនួនទៀតដើម្បីជួយសម្រួលបន្ទុកដល់សហគ្រាសធុនតូចនិងមធ្យម តាមរយៈជម្រើសសហហិរញ្ញប្បទាន និងការធានាឥណទាន។

១.២-រចនាសម្ព័ន្ធ និងខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា

ខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ចាប់ផ្តើមពីការផលិតជាសរសៃអំបោះ និងការបំប្លែងសរសៃអំបោះទៅជាអំបោះតាមរយៈដំណើរការរង្វិលឬវៃអំបោះ។ អំបោះមួយចំនួនត្រូវបានជ្រលក់ពណ៌មុននឹងប្រែក្លាយជាក្រណាត់។ បន្ទាប់ពីអំបោះត្រូវបានផលិតជាក្រណាត់ តាមរយៈសកម្មភាពត្បាញ ប៉ាក់ឬចាក់ កំណាត់ត្រូវបានយកទៅជ្រលក់ពណ៌ ឬបោះពុម្ព មុននឹងយកទៅកាត់ដេរជាសម្លៀកបំពាក់។ ផលិតផលសម្លៀក-

[2] របាយការណ៍ប្រចាំឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

បំពាក់ដែលបានកាត់ដេររួចអាចនឹងឆ្លងកាត់ដំណាក់កាលច្នៃម៉ូដម្តងទៀត មុននឹងដាក់លក់នៅលើទីផ្សារ។ រូបភាពខាងក្រោមបង្ហាញពីខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ។ បន្ថែមពីនេះ ដំណាក់កាលនីមួយៗនៃខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ចាំបាច់ត្រូវការសេវាកម្មគាំទ្រ ដូចជាការរចនាម៉ូដ ការផ្គត់ផ្គង់វត្ថុធាតុដើម ការរក្សាទុក ការវេចខ្ចប់ជាដើម។

រូបទី១ ខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ



បន្ថែមពីនេះ ប្រព័ន្ធអេកូឡូស៊ីនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ រួមបញ្ចូលទាំងការផ្គត់ផ្គង់វត្ថុធាតុ-ដើម និងឧស្សាហកម្មគាំទ្រដទៃទៀត រួមមានដូចជា ១-ការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម ដូចជាសរសៃធម្មជាតិ (ដោយមានកប្បាស សូត្រ រោមចៀម ជាដើម) ២-ការផ្គត់ផ្គង់វត្ថុធាតុដើមឧស្សាហកម្ម ដូចជាសរសៃប្រភេទអ៊ីម-អ៊ីមអ៊ីហ្ស (Man Made Fibers-MMF) សារធាតុគីមី គ្រឿងតុបតែង សម្ភារៈវេចខ្ចប់ជាដើម និង ៣-ឧស្សាហកម្មគាំទ្រ ដូចជាឡូជីស្ទិក គ្រឹះស្ថានហិរញ្ញវត្ថុ វិទ្យាស្ថានបច្ចេកទេសនិងរចនាម៉ូដជាដើម។

ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ប្រមាណ ៧០% ស្ថិតក្រោមទម្រង់ជាផលិតកម្មកាត់ដេរនិងតម្រឹម (ហៅកាត់ថា ស៊ីអ៊ីមធី ឬ CMT)[3] ដែលមានភាពសាមញ្ញ និងមានតម្លៃបន្ថែមទាប។ សកម្មភាពដទៃទៀតនៅក្នុងខ្សែច្រវាក់តម្លៃ ដូចជាផលិតកម្មកប្បាស សរសៃធម្មជាតិជាដើម មានកម្រិតតិចតួចប៉ុណ្ណោះ។ ទន្ទឹមនេះ សមាហរណកម្មប្រតិគមន៍ (Backward Integration) នៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ដូចជាដំណើរការត្បាញអំបោះហុង និងការផលិតក្រណាត់ មានសកម្មភាពតិចតួចនៅឡើយ ដែលនាំឱ្យកម្ពុជាត្រូវពឹងផ្អែកខ្លាំងលើការនាំចូលវត្ថុធាតុដើម និងគ្រឿងម៉ាស៊ីនពីបរទេស។ ជាក់ស្តែង ក្នុងឆ្នាំ២០១៩ ប្រមាណ ៩០% នៃបរិមាណផ្គត់ផ្គង់ក្រណាត់ត្រូវបាននាំចូលពីបរទេស ជាពិសេស ចិន និងវៀតណាម។

---

[3] នៅក្នុងម៉ូដែលផលិតកម្មប្រភេទកាត់ដេរនិងតម្រឹម អ្នកបញ្ជាទិញបង់ថ្លៃឱ្យរោងចក្រវាយនភណ្ឌ និងកាត់ដេរសម្រាប់ដំណើរការកាត់ដេរនិងតម្រឹម។ ដំណើរការមុនផលិតកម្ម ដូចជាការបញ្ជាទិញ ការអភិវឌ្ឍផលិតផល ការបង្កើតប៉ាន់គំរូ និងចំណាត់ថ្នាក់គំរូ និងដំណើរការក្រោយការផលិត ដូចជាការដឹកជញ្ជូនទំនិញត្រូវបានគ្រប់គ្រងដោយអ្នកបញ្ជាទិញ។

តារាងទី១ ខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរវៀតណាម បង់ក្លាដែស និងឥណ្ឌា

ប្រទេស	ខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ
វៀតណាម	រោងចក្រកាត់ដេរមានចំនួន ៧0% នៃរោងចក្រវាយនភណ្ឌ និងកាត់ដេរសរុបទូទាំងប្រទេស។ កន្លងមក រោងចក្រកាត់ដេរទាំងនេះពឹងផ្អែកជាចម្បងលើម៉ូដែលអាជីវកម្មប្រភេទស៊ីអ៊ីមធី ប៉ុន្តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ រោងចក្រទាំងនេះបាននិងកំពុងផ្លាស់ប្តូរឆ្ពោះទៅរកម៉ូដែលអាជីវ-កម្មប្រភេទអ៊ីហ្វូប៊ី (Free-on-Board - FOB)[4]វិញ។ បើទោះជាបច្ចុប្បន្ននេះ វៀតណាមនៅតែពឹងផ្អែកលើការនាំចូលក្រណាត់ដែលបានកែច្នៃរួចហើយក៏ដោយ ឧស្សាហកម្មគាំទ្រនិងបន្ទាប់-បន្សំ ដែលរួមមានក្រុមហ៊ុនផលិតគ្រឿងម៉ាស៊ីន សារធាតុគីមី ឧបករណ៍ប្រើប្រាស់ផ្សេងៗ ជាដើមសម្រាប់បម្រើឱ្យវិស័យនេះ មានចំនួន ៣% នៃចំនួនរោងចក្រសរុប។
បង់ក្លាដែស	រោងចក្រកាត់ដេរមានចំនួន ៧0% នៃចំនួនរោងចក្រវាយនភណ្ឌ និងកាត់ដេរសរុបទូទាំងប្រទេស។ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរបង់ក្លាដែស មានសកម្មភាពខ្លាំងនៅក្នុងផ្នែកកាត់ដេរសម្លៀកបំពាក់ និងផលិតអំបោះ ប៉ុន្តែផ្នែកផ្សេងទៀតនៃខ្សែច្រវាក់តម្លៃនៃវិស័យនេះ មានសកម្មភាពតិចតួចនៅឡើយ។ ជាក់ស្តែង សកម្មភាពជ្រលក់ពណ៌អំបោះ និងកែច្នៃក្រណាត់ មានលក្ខណៈទ្រង់ទ្រាយតូចនៅឡើយ ខណៈដែលសកម្មភាពរចនាម៉ូដ និងផែនការផលិតកម្ម ធ្វើឡើងនៅក្នុងប្រទេសដើមរបស់វិនិយោគិន។ ទោះបីយ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រោងចក្រវាយនភណ្ឌ និងកាត់ដេរមួយចំនួន បាននិងកំពុងចាប់បង្កើតយីហោផ្ទាល់ខ្លួនសម្រាប់ទីផ្សារក្នុងស្រុក។
ឥណ្ឌា	ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរឥណ្ឌា មានសកម្មភាពដំណើរការនៅក្នុងគ្រប់ផ្នែកទាំងអស់នៃខ្សែច្រវាក់តម្លៃ ចាប់ពីការផលិតសរសៃអំបោះរហូតដល់ការផលិតផលិតផលចុងក្រោយ (សម្លៀកបំពាក់)។ ចំណុចខ្លាំងចម្បងនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរឥណ្ឌា គឺមូលដ្ឋានផលិតកម្មក្នុងស្រុកដ៏រឹងមាំលើវត្ថុធាតុដើម បច្ចេកវិទ្យា និងធនធានមនុស្ស។ ឥណ្ឌាគឺជាប្រទេសផលិតកប្បាស និងសរសៃអំបោះធំជាងគេបំផុតលើពិភពលោក និងជាប្រទេសផលិតសរសៃ Polyester និងសូត្រធំជាងគេទីពីរលើពិភពលោក។ ទន្ទឹមនេះ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរឥណ្ឌាក៏មានកិត្តិនាមល្បីល្បាញលើផ្នែករចនាម៉ូដផងដែរ ក្នុងនោះរោងចក្រមួយចំនួនបង្កើតម៉ាកយីហោផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ទីផ្សារក្នុងស្រុក។

[4] នៅក្នុងម៉ូដែលអាជីវកម្ម អ៊ីហ្វូអ្ហូប៊ី បន្ថែមពីលើដំណើរការកាត់ដេរនិងតម្រឹម សកម្មភាពមុនពេលផលិតដូចជាការបញ្ជាទិញ និងការផ្សព្វផ្សាយផលិតផលក៏ត្រូវបានរួមបញ្ចូលផងដែរ។ ដូចនេះ រោងចក្រដែលអនុវត្តម៉ូដែលអាជីវកម្ម អ៊ីហ្វូអ្ហូប៊ី ត្រូវការជំនាញលើសពីការកាត់ និងដេរ។ ជំនាញទាំងនេះរួមមានហិរញ្ញវត្ថុ លទ្ធកម្ម ការបង្កើតប៉ាន់គំរូ និងការទំនាក់ទំនងជាមួយម៉ាកផលិតផលល្បីៗក្នុងពិភពលោក។

ជារួម រោងចក្រវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូបកម្ពុជា ប្រមូលផ្តុំនៅតាមតំបន់សំខាន់ៗចំនួនពីរមាន តំបន់ជុំវិញរាជធានី តំបន់ព្រំដែន និងតំបន់កំពង់ផែសមុទ្រ។ រោងចក្រភាគច្រើនស្ថិតនៅក្នុងតំបន់ជុំវិញរាជធានី (រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម) ដោយសារមានហេដ្ឋារចនាសម្ព័ន្ធគាំទ្រ បរិយាកាសរស់នៅប្រកបដោយភាពអំណោយផល និងកម្លាំងពលកម្មច្រើន។ ក្រៅពីតំបន់ជុំវិញរាជធានី រោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងកាបូប ក៏ប្រមូលផ្តុំនៅតាមព្រំដែនថៃ វៀតណាម តំបន់សេដ្ឋកិច្ចពិសេស (SEZ) និងតំបន់កំពង់ផែសមុទ្រផងដែរ។

តារាងទី២ ទីតាំងរោងចក្រវាយនភណ្ឌ និងកាត់ដេរក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០២០

តំបន់ឧស្សាហកម្ម	ខេត្ត	វាយនភណ្ឌ	កាត់ដេរ	សរុប
រាជធានី	ភ្នំពេញ	២៨៩	៨៩១	១១៨០
រាជធានី	កណ្តាល	៣៩	១៥២	១៩១
រាជធានី	កំពង់ស្ពឺ	២៧	៦៩	៩៦
រាជធានី	កំពង់ឆ្នាំង	៤	១៧	២១
រាជធានី	កំពង់ចាម	៣	៩	១២
កំពង់ផែសមុទ្រ	ព្រះសីហនុ	២៥	៣៩	៦៤
កំពង់ផែសមុទ្រ	កំពត	១	៣	៤
ព្រំដែនថៃ	បន្ទាយមានជ័យ		៦	៦
ព្រំដែនថៃ	កោះកុង		៣	៣
ព្រំដែនថៃ	ប៉ៃលិន		២	២
ព្រំដែនវៀតណាម	តាកែវ	៨	៣៤	៤២
ព្រំដែនវៀតណាម	ស្វាយរៀង	៩	៣១	៤០
ព្រំដែនវៀតណាម	ព្រៃវែង		៣	៣
ព្រំដែនវៀតណាម	ត្បូងឃ្មុំ	២	១	៣
ផ្សេងទៀត	សៀមរាប	៥	១៤	១៩
ផ្សេងទៀត	ពោធិ៍សាត់	២	២	៤
ផ្សេងទៀត	បាត់ដំបង	១		១
ផ្សេងទៀត	ឧត្តរមានជ័យ		១	១
ផ្សេងទៀត	រតនគិរី			០
សរុបរួម		**៤១៥**	**១ ២៧៧**	**១ ៦៩២**

ប្រភព: ក្រសួងពាណិជ្ជកម្ម

១.៣-សកម្មភាពពាណិជ្ជកម្ម

កម្ពុជាជាប្រទេសនាំចេញសម្លៀកបំពាក់សំខាន់មួយ ដោយកាន់កាប់ចំណែកប្រមាណ ១%[5] នៃពាណិជ្ជ-កម្មសម្លៀកបំពាក់សកល ដោយក្នុងនោះ សហរដ្ឋអាមេរិក និងសហភាពអ៊ីរ៉ុប គឺជាទីផ្សារនាំចេញចម្បងរបស់កម្ពុជា ។ ក្រៅពីនេះ កម្ពុជាពឹងផ្អែកលើប្រទេសចិន វៀតណាម និងបណ្តាប្រទេសអាស៊ីមួយចំនួនទៀតផងដែរ សម្រាប់ការផ្គត់ផ្គង់វត្ថុធាតុដើម។

១.៣.១-ការនាំចេញ និងទីផ្សារនាំចេញសំខាន់ៗ

ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់កម្ពុជា ដោយរួមចំណែក ៥៧% នៃការនាំចេញទំនិញសរុបក្នុងឆ្នាំ២០១៩ និងប្រមាណ ៣៣% នៃសកម្មភាពផលិតកម្មសម្រាប់វិស័យនេះទូទាំងប្រទេស។ ក្នុងឆ្នាំ២០១៩ ការនាំចេញផលិតផលវាយនភណ្ឌ និងកាត់ដេររបស់កម្ពុជាមានទំហំ ៨,៥ ពាន់លានដុល្លារអាមេរិក ដែលមានអត្រាកំណើន ១៣% ជាមធ្យមក្នុងមួយឆ្នាំ ក្នុងរយៈពេលដប់ឆ្នាំ (ឆ្នាំ២០០៩-២០១៩) ដែលភាគច្រើនជាផលិតផលសម្លៀកបំពាក់ ខណៈដែលការនាំចេញផលិតផលវាយនភណ្ឌមានតិចតួចប៉ុណ្ណោះ។ ក្នុងឆ្នាំ២០២០ ការនាំចេញផលិតផលវាយនភណ្ឌ និងកាត់ដេររបស់កម្ពុជាបានធ្លាក់ចុះ ដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងការដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើក-លែងអាវុធដោយសហភាពអ៊ីរ៉ុប។

ក-ទិសដៅនៃការនាំចេញផលិតផលសម្លៀកបំពាក់របស់កម្ពុជា

សហភាពអ៊ីរ៉ុប និងសហរដ្ឋអាមេរិក គឺជាទីផ្សារចម្បង ២ សម្រាប់ការនាំចេញសម្លៀកបំពាក់របស់កម្ពុជា ដែលមានចំណែក ៣២% និង ២៧% រៀងគ្នា នៅក្នុងការនាំចេញសម្លៀកបំពាក់សរុបរបស់កម្ពុជាក្នុងឆ្នាំ២០១៩។ ក្នុងរយៈពេលដប់ឆ្នាំ (ឆ្នាំ២០០៩-២០១៩) ចំណែកទីផ្សារសហរដ្ឋអាមេរិកបានថយចុះពី ៦២% មក ២៧% ខណៈដែលចំណែកទីផ្សាររបស់សហភាពអ៊ីរ៉ុប បានកើនឡើងពី ១៨% ទៅ ៣២%។ កត្តាចម្បងដែលជំរុញឱ្យមានកំណើននៃការនាំចេញនេះ គឺដោយសារតែគំនិតផ្តួចផ្តើមប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ និងការបន្ធូរបន្ថយលើវិធាននៃប្រភពដើមទំនិញ (Rule of Origin)[6]។ ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាទៅកាន់ប្រទេសជប៉ុនក៏មានកំណើនគួរឱ្យកត់សម្គាល់ផងដែរ ពីទំហំ២៨,៥លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០០៩ ដល់ ៨២០លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៩។

---

[5] ផែនទីពាណិជ្ជកម្មព័ត៌មាននិងទូរគមនាគមន៍(ITC Trade Map) ឆ្នាំ២០២១

[6] ព្រឹត្តិបត្រវិស័យកាត់ដេរ និងស្បែកជើងកម្ពុជា លេខ៥ ខែមករា ឆ្នាំ២០១៧ របស់អង្គការអន្តរជាតិខាងការងារ។

១-ល្បាយផលិតផលសម្លៀកបំពាក់សម្រាប់នាំចេញរបស់កម្ពុជា

បើផ្អែកតាមទិដ្ឋភាពនៃវត្ថុធាតុដើមផលិត ក្នុងឆ្នាំ២០១៩ ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាភាគច្រើនជាប្រភេទសម្លៀកបំពាក់ផលិតពីកប្បាស ដែលមានចំណែក ៤២% នៃការនាំចេញសម្លៀកបំពាក់សរុប និងបន្ទាប់មកគឺសម្លៀកបំពាក់ផលិតពីសសៃប្រភេទអ៊ីមអ៊ីមអ៊ែហ្ស (Man Made Fibers ឬMMF) ដែលមានចំណែក ២៨%។ ក្នុងរយៈពេលដប់ឆ្នាំ (ឆ្នាំ២០០៩-២០១៩) ការនាំចេញសម្លៀកបំពាក់ផលិតពីកប្បាស និងសសៃប្រភេទ អ៊ីមអ៊ីមអ៊ែហ្ស ពីប្រទេសកម្ពុជាបានកើនឡើង ១១% និង ៧% រៀងគ្នា។

១.៣.២-ការនាំចូល និងទីផ្សារនាំចូលសំខាន់ៗ

កម្ពុជានាំចូលក្រណាត់ប៉ាក់ និងតម្បាញមួយចំនួនធំពីបរទេស ជាពិសេសប្រទេសចិន។ ទន្ទឹមនេះដោយសារម៉ូដែលអាជីវកម្មក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ជាប្រភេទស៊ីអ៊ីមធី ការប្រើប្រាស់វត្ថុធាតុដើម ដូចជាក្រណាត់ គ្រឿងបន្ទាស់ជាដើម ត្រូវសម្រេចដោយអ្នកបញ្ជាទិញអន្តរជាតិ។ ជាក់ស្តែង អ្នកបញ្ជាទិញភាគច្រើន បានតម្រូវឱ្យរោងចក្រកម្ពុជាជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់វត្ថុធាតុដើម ដែលពួកគេបានណែនាំ។ ក្នុងឆ្នាំ២០១៩ ការនាំចូលវត្ថុធាតុដើមវាយនភណ្ឌរបស់កម្ពុជាមានទំហំ ៥,២ ពាន់លានដុល្លារអាម៉េរិក ដោយបានកើនឡើងប្រមាណ ១៤% ជាមធ្យមប្រចាំឆ្នាំ គិតពីឆ្នាំ២០០៩ ដល់ ២០១៩។ កម្ពុជាក៏បាននាំចូលសម្ភារៈបន្ថែម សម្រាប់ផលិតសម្លៀកបំពាក់ដូចជា ខ្សែដេរ ខ្ទ្រ៉ូត ឡេវជាដើម ដែលមានតម្លៃប្រមាណ ៣០០លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៩ ដែលភាគច្រើនមកពីប្រទេសចិន វៀតណាម និងថៃ។ ការនាំចូលសម្ភារៈបន្ថែមទាំងនេះបានកើនឡើងប្រមាណ ១៩% ជាមធ្យមប្រចាំឆ្នាំ ពីឆ្នាំ២០០៩ ដល់ ២០១៩។

ប្រទេសដែលផ្គត់ផ្គង់ផលិតផលវាយនភណ្ឌធំជាងគេសម្រាប់ទីផ្សារកម្ពុជាក្នុងឆ្នាំ២០១៩ គឺប្រទេសចិន វៀតណាម ថៃ និងសាធារណៈរដ្ឋកូរ៉េ។ ប្រទេសចិន គឺជាអ្នកផ្គត់ផ្គង់ផលិតផលវាយនភណ្ឌធំជាងគេសម្រាប់កម្ពុជា ដែលមានចំណែក ៦៤% (៣,៣ពាន់លានដុល្លារអាម៉េរិក) នៃការនាំចូលផលិតផលវាយនភណ្ឌសរុបរបស់កម្ពុជា។ ការនាំចូលផលិតផលវាយនភណ្ឌរបស់កម្ពុជាពីប្រទេសចិន បានកើនឡើងក្នុងអត្រា ១៦% ជាមធ្យមប្រចាំឆ្នាំ ក្នុងរយៈពេលដប់ឆ្នាំ (ឆ្នាំ២០០៩-២០១៩)។ ប្រទេសវៀតណាមជាអ្នកផ្គត់ផ្គង់ផលិតផលវាយនភណ្ឌធំទីពីរដល់កម្ពុជាក្នុងឆ្នាំ២០១៩។

១.៣.៣-កិច្ចព្រមព្រៀងពាណិជ្ជកម្ម

ក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច និងជាប្រទេសសមាជិកអាស៊ាន កម្ពុជាទទួលបានការអនុគ្រោះផ្នែកទីផ្សារនិងពន្ធ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន រួមមានអាមេនី អូស្ត្រាលី កាណាដា សហភាពអ៊ីរ៉ុប អ៊ីស្លង់ ជប៉ុន កាហ្សាក់ស្ថាន ន្ធូវែលសេឡង់ ន័រវែស សហព័ន្ធរុស្សុី ស្វីស តួកគី ចក្រភពអង់គ្លេស សហរដ្ឋអាម៉េរិក ឥណ្ឌា ឈីលី សាធារណរដ្ឋប្រជាមានិតចិន

សាធារណរដ្ឋកៀហ្ស៊ីស៊ី ម៉ុងតេណេហ្ក្រូ តាជីគីស្ថាន ថៃ និងសាធារណរដ្ឋកូរ៉េ។ ទោះជាយ៉ាងនេះក៏ដោយ កម្ពុជាមិនទទួលបានការអនុគ្រោះពន្ធដូចៗគ្នា លើការនាំចេញផលិតផលវាយនភណ្ឌ និងសម្លៀកបំពាក់ពីបណ្តាប្រទេសខាងលើនោះទេ។ ជាក់ស្តែង សហរដ្ឋអាម៉េរិកបានដាក់ពន្ធដែលគិតជា Ad Valorem Equivalent (AVE) ស្មើនឹង ១៤,៣១% លើផលិតផលវាយនភណ្ឌ និងសម្លៀកបំពាក់កម្ពុជា ខណៈសហភាពអ៊ីរ៉ុបបានដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ ចាប់តាំងពីខែសីហា ឆ្នាំ២០២០។ ការដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ ដោយសហភាពអ៊ីរ៉ុប និងកិច្ច-ព្រមព្រៀងពាណិជ្ជកម្មសេរីវៀតណាម-សហភាពអ៊ីរ៉ុប អាចជះឥទ្ធិពលអវិជ្ជមានដល់ការនាំចេញផលិតផលវាយនភណ្ឌ និងកាត់ដេររបស់កម្ពុជា ក្នុងរយៈពេលខ្លីនិងមធ្យម។

ទោះជាយ៉ាងនេះក្តី ការវិវឌ្ឍផ្នែកពាណិជ្ជកម្មថ្មីៗ អាចនឹងជំរុញពាណិជ្ជកម្មផលិតផលវាយនភណ្ឌ និងកាត់ដេររបស់កម្ពុជា មានដូចខាងក្រោម÷

- បន្ទាប់ពីការចាកចេញរបស់អង់គ្លេសពីសហភាពអ៊ីរ៉ុប កម្ពុជាទទួលបានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ (GSP) ថ្មីរបស់ចក្រភពអង់គ្លេស ដែលបានចូលជាធរមានចាប់ពីខែមករា ឆ្នាំ២០២១។ ប្រព័ន្ធអនុគ្រោះនេះផ្តល់ការលើកលែងពន្ធ និងកូតាដល់កម្ពុជាក្នុងការនាំចេញទៅកាន់ចក្រភពអង់គ្លេសនូវទំនិញគ្រប់ប្រភេទទាំងអស់ លើកលែងតែអាវុធ និងគ្រាប់រំសេវ។ ដូចនេះ ប្រព័ន្ធអនុគ្រោះថ្មីដែលផ្តល់ដោយចក្រភពអង់គ្លេសនេះ មានលក្ខណៈដូចជាប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ (EBA) ពេញលេញរបស់សហភាពអ៊ីរ៉ុបដែរ។
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន (CCFTA) ដែលបានចុះហត្ថលេខាកាលពីខែតុលា ឆ្នាំ២០២០ លុបបំបាត់ការបង់ពន្ធ រហូតដល់ ៩៨% នៃការនាំចេញសរុបពីកម្ពុជាទៅចិន និង ៩០% នៃការនាំចេញពីចិនមកកម្ពុជា[7]។
- កម្ពុជា ក៏ទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ដែលបានចុះហត្ថលេខាក្នុងខែវិច្ឆិកា ឆ្នាំ២០២០ផងដែរ។ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ ដែលបានចូលជាធរមាននៅឆ្នាំ២០២២ គឺជាក្របខ័ណ្ឌពាណិជ្ជកម្មសេរីដ៏ទូលំទូលាយដែលរួមបញ្ចូលប្រទេសអាស៊ាន និងប្រទេសដៃគូចំនួនប្រាំផ្សេងទៀត ដែលអាស៊ានមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយ រួមមានចិន (ACFTA) សាធារណរដ្ឋកូរ៉េ (AKFTA) ជប៉ុន (AJCEP) ព្រមទាំងអូស្ត្រាលី និងនូវែលសេឡង់ (AANZFTA) ផងដែរ។
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា និងកូរ៉េខាងត្បូង (CKFTA) ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១) បានចូលជាធរមាននៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២។ តាមរយៈកិច្ចព្រមព្រៀងនេះ កូរ៉េខាងត្បូងផ្តល់ការអនុគ្រោះពន្ធដល់កម្ពុជារហូតដល់ ៩៥,០៣% នៃបន្ទាត់ពន្ធគយសរុប ក្នុងពេលដែលកម្ពុជាផ្តល់ការអនុគ្រោះដល់កូរ៉េខាងត្បូងវិញ ៨៩,០៩ %។

[7] <u>គេហទំព័រ</u>÷ https://textilevaluechain.in/news-insights/cambodia-china-sign-free-trade-agreement/ ដកស្រង់ខែកក្កដា ឆ្នាំ២០២១

១.៤-ប្រព័ន្ធអេកូឡូស៊ីគាំទ្រ

១.៤..១-ការអភិវឌ្ឍជំនាញ និងការរៀបរំកម្រិតខ្ពស់

គិតមកត្រឹមឆ្នាំ២០២០ មានគ្រឹះស្ថានបណ្តុះបណ្តាលចំនួន ១០៤ ដែលបានចុះបញ្ជីផ្លូវការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមមានគ្រឹះស្ថានសាធារណៈចំនួន ៣៧ គ្រឹះស្ថានឯកជនចំនួន ៤១ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៦ ដែលផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា។ គ្រឹះស្ថានសាធារណៈចំនួន ៣៧ មានទីតាំងនៅទូទាំងប្រទេស និងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ដើម្បីឆ្លើយតបតម្រូវការឧស្សាហកម្មនាពេលបច្ចុប្បន្ន និងអនាគត[8]។

ក្រៅពីគ្រឹះស្ថានបណ្តុះបណ្តាលខាងលើ កម្ពុជាក៏មានសាកលវិទ្យាល័យ និងវិទ្យាស្ថានមួយចំនួនទៀតដែលបាននិងកំពុងផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេសផងដែរ។ ជាក់ស្តែង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាកំពុងផ្តល់កម្មវិធីបណ្តុះបណ្តាលលើជំនាញ ឧស្សាហកម្ម អគ្គិសនី មេកានិច អេឡិចត្រូនិក និងវិស្វកម្មគីមីផងដែរ។ ទោះជាយ៉ាងនេះក្តី និស្សិតដែលបញ្ចប់ការសិក្សាភាគច្រើន មិនមានទំនោរក្នុងការស្វែងរកការងារក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរនោះទេ។

ប្រអប់ទី១ វគ្គបណ្តុះបណ្តាលរយៈពេលខ្លីនិងវែង ដែលផ្តល់ដោយគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជា

កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី (មួយសប្តាហ៍) រួមមានការដំឡើងអគ្គិសនី (តភ្លើង) តបណ្តាញទឹក ជួសជុលម៉ាស៊ីនត្រជាក់ ម៉ាស៊ីន រថយន្ត ម៉ូតូ ទូរសព្ទ កុំព្យូទ័រ សេវាកម្មមួយអាហារនិងភេសជ្ជៈ ជុតនំ កាត់ដេរ ហាងកែសម្ផស្ស ជាត់មុខ រៀបចំអាពាហ៍ពិពាហ៍ ការចិញ្ចឹមសត្ត ការដាំបន្លែ ផ្លែឈើនិងបន្លែកែច្នៃ និងជំនាញផ្សេងៗទៀត។ វគ្គបណ្តុះបណ្តាលរយៈពេលខ្លីទាំងនេះ ធ្វើឡើងទាំងនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាល និងនៅតាមសហគមន៍។

វគ្គបណ្តុះបណ្តាលរយៈពេលវែង (មួយឆ្នាំនិងយូរជាងនេះ) រួមមានស្ថាបត្យកម្ម សំណង់ស៊ីវិល អគ្គិសនី អេឡិចត្រូនិក មេកានិក ម៉ាស៊ីនត្រជាក់ យានយន្ត សហគ្រិនភាព គណនេយ្យ វិទ្យាសាស្ត្រកុំព្យូទ័រ បច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ ពាណិជ្ជកម្ម ទេសចរណ៍ និងជំនាញផ្សេងៗទៀត។

[8] របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០២០ ស្តីពីព័ត៌មានទូទៅនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (General Information of TVET Institutes)។

ប្រអប់ទី២ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ឱ្យអនុវត្តជាផ្លូវការនូវគោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ក្នុងគោលបំណងដូចខាងក្រោម÷

- *ពង្រឹងគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឱ្យស្របតាមតម្រូវការទីផ្សារការងារក្នុងនិងក្រៅប្រទេស*
- *បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈប្រកបដោយសមធម៌សម្រាប់បង្កើតការងារ*
- *លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឱ្យចូលរួមក្នុងការអភិវឌ្ឍ និងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និង*
- *លើកកម្ពស់អភិបាលកិច្ចក្នុងសប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។*

បច្ចុប្បន្ននេះ មានគ្រឹះស្ថានជាង ១០០ ដែលបាននិងកំពុងផ្តល់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា។ វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា (CGTI) គឺជាស្ថាប័នផ្តល់ការបណ្តុះបណ្តាលតែមួយគត់ ដែលមានឯកទេសក្នុងកម្មវិធីបណ្តុះបណ្តាលដែលឆ្លើយតបទៅនឹងតម្រូវការនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ។ វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៦ ដោយសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) ដើម្បីកសាង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដោយផ្តោតលើគុណភាព និងបរិមាណ សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា។ វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា ផ្តល់នូវវគ្គបណ្តុះបណ្តាលនានា ចាប់ពីដំណាក់កាលមុនការផលិត ផលិតកម្ម និងផលិតភាព រហូតដល់អនុលោមភាព។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើង ដើម្បីគាំទ្រកម្លាំងពលកម្មកម្ពុជា ក្នុងការរំកិលឡើងខ្សែច្រវាក់តម្លៃ ទទួលបានជំនាញសម្រាប់មុខតំណែងកម្រិតអ្នកគ្រប់គ្រងថ្នាក់កណ្តាល និងផ្លាស់ប្តូរម៉ូដែលអាជីវកម្មកាត់ដេរកម្ពុជាពីប្រភេទស៊ីអ៊ីមធីទៅជាអ៊ែហ្វអ្ហូ។ បច្ចុប្បន្ននេះ រោងចក្រដែលគ្រប់គ្រងដោយវិនិយោគិនបរទេសភាគច្រើន បានធ្វើការអភិវឌ្ឍផលិតផល និងម៉ាកយីហោ នៅទីស្នាក់ការប្រទេសដើមរបស់ពួកគេ។ បន្ថែមពីនេះ មុខតំណែងកម្រិតបច្ចេកទេសជាន់ខ្ពស់ និងអ្នកគ្រប់គ្រងភាគច្រើនគឺត្រូវបានផ្តល់ទៅឱ្យជនបរទេស។

១.៤.២-សមាគមពាណិជ្ជកម្ម

សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៦ ក្នុងនាមជាស្ថាប័នពាណិជ្ជកម្មកំពូល តំណាងឱ្យសមាជិកនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរនៅក្នុងប្រទេសកម្ពុជា។ សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា គ្រប់គ្រងដោយគណៈកម្មាធិការប្រតិបត្តិដែលមានសមាជិក២៥នាក់ តំណាងឱ្យរោងចក្រកាត់ដេរសំខាន់ៗ

នៅកម្ពុជា។ សមាជិកគណៈកម្មាធិការ មានតួនាទីផ្តល់យោបល់លើការរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយ របស់រាជរដ្ឋាភិបាលសម្រាប់វិស័យនេះ ខណៈដែលប្រតិបត្តិការប្រចាំថ្ងៃរបស់សមាគមត្រូវបានអនុវត្តដោយ លេខាធិការដ្ឋានដែលមានបុគ្គលិកជំនាញចំនួន ២៣នាក់។ ការងារសំខាន់ៗរបស់លេខាធិការដ្ឋាន រួមមានការ ចរចាជាមួយរាជរដ្ឋាភិបាលលើបញ្ហាពន្ធនិងលក្ខខណ្ឌការងារ សហការជាមួយភាគីពាក់ព័ន្ធអន្តរជាតិទាក់ទងនឹង គំនិតផ្តួចផ្តើមនានាក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ និងសហការជាមួយរាជរដ្ឋាភិបាលដើម្បីចរចាលើកិច្ច ព្រមព្រៀងពាណិជ្ជកម្មសេរីនានា។ សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅ កម្ពុជា មានសមាជិកជាង ៦០០ ដែលគ្របដណ្ដប់ ២៨% នៃចំនួនសរុប នៃរោងចក្រវាយនភណ្ឌ សម្លៀកបំពាក់ និង ស្បែកជើងនៅកម្ពុជា។ ទន្ទឹមនេះ សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា ក៏ផ្តល់វគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយពីបច្ចុប្បន្នភាពផ្នែកច្បាប់និងការផ្លាស់ប្តូរគោលនយោបាយនានារបស់រាជរដ្ឋ-ភិបាល ព័ត៌មានអាជីវកម្មទូទៅ ពិព័រណ៍ពាណិជ្ជកម្ម និងបណ្តាញទំនាក់ទំនង ដល់សមាជិកខ្លួនផងដែរ។ សមាគម វាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា ក៏សហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័ន នានារបស់រាជរដ្ឋាភិបាល ដើម្បីជំរុញឱ្យមានលក្ខខណ្ឌការងារកាន់តែប្រសើរឡើង និងការស្វែងរកទីផ្សារដែល ផ្តល់លក្ខខណ្ឌអនុគ្រោះដល់ការនាំចេញរបស់កម្ពុជា។

១.៤.៣-រាជរដ្ឋាភិបាល

ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ គឺជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលឆ្លុះ-បញ្ចាំងនៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់នានាដែលរាជរដ្ឋាភិបាលបានដាក់ចេញ។ ជាក់ស្តែង គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការកាលពីខែ សីហា ឆ្នាំ២០១៥ ក្នុងគោលបំណងពន្លឿនការអភិវឌ្ឍឧស្សាហកម្មកម្ពុជា ក្នុងនោះ ឧស្សាហកម្មវាយនភណ្ឌ និង កាត់ដេរ ជាវិស័យអាទិភាពមួយក្នុងការជំរុញពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារដល់កម្លាំងពលកម្មកម្ពុជា។ ទន្ទឹមនេះ ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧ កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។ យុទ្ធសាស្ត្រនេះ មានគោលបំណងកំណត់នូវទិសដៅ អភិវឌ្ឍន៍រួម បង្កើនភាពឯករាជ្យ ពង្រឹងភាពប៉ាន់ប្រមាណបាន និងស្ថិរភាពនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ដើម្បីបន្តលើកកម្ពស់ការអភិវឌ្ឍ វិស័យនេះប្រកបដោយចីរភាព និងបរិយាបន្ន។ យុទ្ធសាស្ត្រនេះ មានគោលដៅ÷

១-បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតតន្លង្គអាជីពសម្រាប់កម្មករ និយោជិត
២-បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត
៣-លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងផ្តោតលើ ផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស

៤-ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ និង

៥-ជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប។

ក-ការលើកទឹកចិត្តវិនិយោគនៅកម្ពុជា

ផ្អែកលើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដល់គម្រោងវិនិយោគ ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់-គ្រាន់ (គ.ល.គ.)។ គ.ល.គ. ទទួលបានការលើកទឹកចិត្តវិនិយោគដូចជា មានសិទ្ធិទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល ឬការប្រើប្រាស់វិធីសាស្ត្រកាត់កងចំណាយមូលធនតាមរយៈរំលស់ពិសេស និងសិទ្ធិនាំចូលដោយពន្ធគយអាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខាសំណង់ សម្ភារៈ-បរិក្ខាផលិតកម្ម និងធាតុចូលផលិតកម្ម។ លក្ខណៈវិនិច្ឆ័យដើម្បីក្លាយជា គ.ល.គ. ប្រែប្រួលទៅតាមវិស័យនីមួយៗ និងសកម្មភាពវិនិយោគអាទិភាពដែលបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា[9]។ ម៉្យាងវិញទៀត គម្រោងវិនិយោគទាំងឡាយដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZ) ក៏មានសិទ្ធិទទួលបានឋានៈ គ.ល.គ. និងទទួលបានការលើកទឹកចិត្ត និងការការពារដូចគ្នានឹង គ.ល.គ. ផងដែរ។

ខ-តំបន់សេដ្ឋកិច្ចពិសេស

ចាប់តាំងពីឆ្នាំ២០០៥ តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសកម្ពុជា ដើម្បីទាក់ទាញការវិនិយោគ ជាពិសេសសម្រាប់ការផលិតដែលផ្តោតលើការនាំចេញ រួមទាំងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរផងដែរ។ តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា (CSEZB) ដែលជាផ្នែកមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ គម្រោងវិនិយោគទាំងឡាយដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZ) មានសិទ្ធិស្នើសុំឋានៈជា គ.ល.គ. និងទទួលបានការលើកទឹកចិត្ត និងការការពារដូចគ្នានឹង គ.ល.គ.។ វិនិយោគិននៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទទួលបានអត្ថប្រយោជន៍ រួមមានសេវាច្រកចេញចូលតែមួយនៅនឹងកន្លែងតាមរយៈរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស[10] ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញឡូជីស្ទិកដែលមានស្រាប់ ការទទួលបាននីតិវិធីគយពិសេសជាដើម។

តំបន់សេដ្ឋកិច្ចពិសេសដែលមានភាពលេចធ្លោនៅកម្ពុជា រួមមានតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន (ខេត្តស្វាយរៀង) តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ខេត្តព្រះសីហនុ) តំបន់សេដ្ឋកិច្ចពិសេសសានកូន

---

[9] លក្ខណៈវិនិច្ឆ័យសម្រាប់សកម្មភាពវិនិយោគក្នុងវិស័យខ្លះ មិនត្រូវបានកំណត់ដោយទុនវិនិយោគ ឬទ្រព្យសកម្មឡើង។

[10] សេវាច្រកចេញចូលតែមួយ រួមមានសេវាទាំងអស់ដែលផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងអាជ្ញាធរមូលដ្ឋាន អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ) តំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុបភ្នំពេញ (រាជធានីភ្នំពេញ) តំបន់សេដ្ឋកិច្ចពិសេសតាយសេងបាវិត (ខេត្តស្វាយរៀង) តំបន់សេដ្ឋកិច្ចពិសេសហ្គីហ្គាវីសស៍ (ខេត្តស្វាយរៀង)ជាដើម។

គ-អនុលោមភាពផ្នែកបរិស្ថាន និងសង្គម

ក្រសួងស្ថាប័នរាជរដ្ឋាភិបាល មានតួនាទីជំរុញនិងធានាថា រោងចក្រសហគ្រាសទាំងអស់គោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានដែលទាក់ទងទៅនឹងបរិស្ថាន លក្ខខណ្ឌការងារ និងសុខភាពនិងសុវត្ថិភាពការងារ។ ក្រសួងបរិស្ថាន ទទួលបន្ទុកក្នុងកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ។ ក្នុងន័យនេះ ក្រសួងមានតួនាទីចុះអធិការកិច្ច ដើម្បីត្រួតពិនិត្យអនុលោមភាពបរិស្ថាននៅតាមរោងចក្រ និងអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) សម្រាប់គម្រោងសាធារណៈ និងឯកជននានា ដែលអាចមានផលប៉ះពាល់ដល់បរិស្ថាន។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានតួនាទីត្រួតពិនិត្យលើលក្ខខណ្ឌការងារ និងទិដ្ឋភាពអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ។ ក្នុងន័យនេះ ក្រសួងទទួលបន្ទុកធ្វើអធិការកិច្ចការងារ ដើម្បីធានាថាបណ្តារោង-ចក្រនានាគោរពតាមច្បាប់ការងារ។ ជាមួយគ្នានេះ កម្ពុជាបានអនុវត្តយន្តការចរចាប្រាក់ឈ្នួលអប្បបរមា ដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាយន្តការគំរូមួយប្រកបដោយតម្លាភាព និងគិតគូរអំពីទំនាក់ទំនងការងារ និងសុខុមាលភាពរបស់កម្មករនិយោជិត ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធ រួមមានតំណាងនិយោជិត និយោជក និងរាជរដ្ឋាភិបាល។

២-បញ្ហាប្រឈម និងការលានុវត្តភាព

ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា មានភាពចាំបាច់ក្នុងការផ្លាស់ប្តូរនូវម៉ូដែលអាជីវកម្ម ដើម្បីធានានូវភាពប្រកួតប្រជែង និងកំណើនក្នុងទីផ្សារអន្តរជាតិ។ ក្នុងន័យនេះ ល្បាយផលិតផលក្នុងវិស័យនេះ ត្រូវមានការអភិវឌ្ឍឱ្យសមស្របទៅនឹងនិន្នាការនៃប្រភពផ្គត់ផ្គង់សកល ដែលការណ៍នេះមានសារៈសំខាន់សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ក្នុងការចាប់យកនូវទីផ្សារថ្មីៗ និងការបង្កើននូវការជ្រៀតចូលទៅក្នុងទីផ្សារដែលកំពុងមានស្រាប់។

ការចាប់យក និងអនុវត្តបច្ចេកវិទ្យាថ្មីៗ គាំទ្រដល់ការបង្កើនផលិតភាពក្នុងដំណើការនៃផលិតកម្ម និងពង្រឹននូវភាពប្រកួតប្រជែងផ្នែកថ្លៃដើម តាមរយៈការប្រើប្រាស់ធនធានដល់កម្រិតឧត្តមានុពល។ ម្យ៉ាងទៀត ការបណ្តុះបណ្តាលចំណេះដឹង និងជំនាញផ្នែកបច្ចេកវិទ្យាដល់កម្លាំងពលកម្ម គឺជាកត្តាស្នូលដើម្បីធានានូវការទាញផលប្រយោជន៍ពីបច្ចេកវិទ្យាឱ្យអស់លទ្ធភាព។ បច្ចេកវិទ្យាបាននិងកំពុងដើរតួនាទីកាន់តែសំខាន់ក្នុងការអភិវឌ្ឍជំនាញ តាមរយៈការផ្សារភ្ជាប់កម្មវិធី និងសកម្មភាពអប់រំបណ្តុះបណ្តាលជំនាញ ដូចជាថ្នាលបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិចត្រូនិក (e-learning portals)ជាដើម។

សម្រាប់កម្ពុជា ការផ្តោតសំខាន់លើពាណិជ្ជកម្មអន្តរជាតិ និងអន្តរជាតូបនីយកម្ម គឺជាកត្តាសំខាន់ក្នុងការធានានូវភាពប្រកួតប្រជែង ដោយសារឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជាផ្តោតសំខាន់លើការនាំចេញ ស្របពេលដែលកម្ពុជាកំពុងស្ថិតនៅក្នុងអន្តរកាលនៃការបញ្ចប់ឋានៈជាប្រទេសមានកម្រិតអភិវឌ្ឍន៍តិចតួច។ ក្នុងន័យនេះ កម្ពុជាត្រូវផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការកំណត់ និងពង្រីកទិសដៅទីផ្សាររបស់ខ្លួន ជាពិសេសទីផ្សារដែលកំពុងរីកចម្រើនថ្មី និងការរៀបចំនិងដាក់ចេញឱ្យអនុវត្តនូវយុទ្ធសាស្ត្រសម្រាប់រយៈពេលវែងក្នុងការពង្រឹង និងពង្រីកចំណែកទីផ្សារ។

ហេដ្ឋារចនាសម្ព័ន្ធ ចីរភាព និងអភិបាលកិច្ច គឺជាសសរស្តម្ភក្នុងការគាំទ្របរិវត្តកម្មនៃឧស្សាហកម្មវាយ-នភណ្ឌ និងកាត់ដេរកម្ពុជា។ ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាព ទាំងក្នុងកម្រិតសហគ្រាស និងកម្រិតឧស្សាហកម្ម(រួមទាំងតំបន់សេដ្ឋកិច្ចពិសេស) មានភាពចាំបាច់សម្រាប់ប្រតិបត្តិការផលិតកម្ម ការរក្សានូវចីរភាពនិងផលិតកម្មដែលប្រើប្រាស់ធនធានស្អាតនិងប្រកបដោយប្រសិទ្ធភាព។ ចីរភាព មានភាពផ្សារភ្ជាប់យ៉ាងរឹងមាំជាមួយហេដ្ឋារចនាសម្ព័ន្ធ និងអភិបាលកិច្ច។ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ត្រូវអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធឱ្យបានសមស្រប ដើម្បីគាំទ្រដល់ការផ្តួចផ្តើមពាក់ព័ន្ធនឹងទិដ្ឋភាពចីរភាព ដូចជាការអនុវត្តប្រព័ន្ធផលិតកម្មស្អាតជាដើម។ ដោយឡែក យន្តការអភិបាលកិច្ចប្រកបដោយតម្លាភាព និងគណនេយ្យភាព មានសារៈសំខាន់ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងកម្រិតស្តង់ដាអន្តរជាតិ ដើម្បីគាំទ្រដល់បរិវត្តិកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរប្រកបដោយប្រសិទ្ធភាព និងចីរភាព សមស្របតាមនិយាមសកល ក្នុងការធ្វើសមាហរណកម្មយីហោ និងអ្នកចែកចាយផលិតផលវាយនភណ្ឌ និងកាត់ដេរសកលលោក។ ជាមួយគ្នានេះ ក្របខណ្ឌត្រួតពិនិត្យនិងវាយតម្លៃប្រកបដោយភាពច្បាស់លាស់ និងរឹងមាំជាកត្តាជំរុញនូវអនុលោមភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិដែលបានដាក់ចេញ។

ជារួម ការអភិវឌ្ឍជំនាញ ផលិតភាព បច្ចេកវិទ្យា ល្បាយផលិតផល នវានុវត្តន៍ ពាណិជ្ជកម្មនិងអន្តរជាតូបនីយកម្ម ចីរភាព ហេដ្ឋារចនាសម្ព័ន្ធ និងអភិបាលកិច្ច គឺជាកត្តាសំខាន់សម្រាប់ផែនទីបរិវត្តកម្មឧស្សា-ហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា។

២.១-កម្លាំងពលកម្មជំនាញ

២.១.១-កម្មករនិយោជិតផ្នែកផលិតកម្ម

កម្លាំងពលកម្មកម្ពុជាក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ភាគច្រើនបំពេញការងារក្នុងទម្រង់កាត់ដេរតម្រឹម មានជំនាញទាប និងភាគច្រើនជាស្ត្រីដែលបានធ្វើចំណាកស្រុកពីតំបន់ជនបទមកធ្វើការនៅរោងចក្រស្ថិតនៅក្នុងតំបន់ប្រជុំជនឬទីក្រុង។ អត្រាអក្ខរកម្មនៅកម្ពុជានៅមានកម្រិតទាប បើធៀបនឹងប្រទេសដែលជាដៃគូប្រកួតប្រជែងរបស់ខ្លួន រួមមានវៀតណាម ចិន និងថៃ។

តារាងទី៣ អត្រាអក្ខរកម្មនៅកម្ពុជា និងប្រទេសដែលជាដៃគូប្រកួតប្រជែងក្នុងតំបន់អាស៊ី

	កម្ពុជា	ចិន	វៀតណាម	ថៃ	មីយ៉ាន់ម៉ា	ឥណ្ឌា	បង់ក្লាដេស
អត្រាអក្ខរកម្ម	៨៧,៧%	៩៦,៨%	៩៥%	៩៨,១%	៧៥,៦%	៧៤,៤%	៧៤,៧%

ប្រភព: ទិន្នន័យពី UNESCO តាមរយៈគេហទំព័រ http://uis.unesco.org/en/home#tabs-0-uis_home_top_menus-3

ជាទូទៅ កម្មករ និងប្រធានក្រុមផលិតកម្មដែលបំពេញការងារក្នុងទម្រង់ស៊ីអ៊ីមធី មានការអប់រំកម្រិតមូលដ្ឋាន ដែលបានបញ្ចប់ការសិក្សាក្នុងចន្លោះពីថ្នាក់ទី ១ ដល់ទី ៩ ប៉ុណ្ណោះ ដែលភាគច្រើននៅមានកម្រិតក្នុងជំនាញនព្វន្ត និងភាសាជាតិ សមស្របសម្រាប់ការអានឬស្វែងយល់ការណែនាំក្នុងការអនុវត្តការងារ ឬប្រតិបត្តិការផលិតកម្ម។ ទន្ទឹមនេះ ភាគច្រើននៃប្រធានក្រុម ដែលត្រូវបានដំឡើងឋានៈពីកម្រិតប្រតិបត្តិករ ពុំមានជំនាញគ្រប់គ្រងក្រុម ដែលអាចធានានូវផលិតភាពនិងគុណភាពការងារ។ ភាពមានកម្រិតនៃអនុលោមភាពផ្នែកសង្គម រួមមានអនាម័យ និងសណ្តាប់ធ្នាប់កន្លែងធ្វើការ នៅតែបន្តចោទជាបញ្ហាក្នុងចំណោមកម្មករ និងប្រធានក្រុមផលិតកម្ម។ ទន្ទឹមនេះ ភាពមានកម្រិតនៃអក្ខរកម្មឌីជីថលធ្វើឱ្យមានភាពលំបាកក្នុងការបណ្តុះបណ្តាលផ្នែកលើបច្ចេកវិទ្យាព័ត៌មាន។

កម្ពុជាពុំទាន់មានន្ធវប្រព័ន្ធបញ្ជាក់កម្រិតជំនាញថ្នាក់ជាតិ ឬម៉ាទ្រិកជំនាញ រួមមានប្រតិបត្តិករដេរ អ្នកកាត់ និងអ្នកវេចខ្ចប់ ក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរនៅឡើយ។ កត្តាដែលបានរៀបរាប់ខាងលើនេះ បាននិងកំពុងបង្កើតជាឧបសគ្គក្នុងការកំណត់ស្តង់ដារួមនៃកម្មវិធីបណ្តុះបណ្តាល និងការវាយតម្លៃកម្រិតជំនាញរបស់ប្រតិបត្តិករ។ ជាមួយគ្នានេះ កម្លាំងពលកម្មដែលកំពុងស្វែងរកការងារ មានភាពលំបាកក្នុងការបញ្ជាក់ឱ្យបានច្បាស់លាស់នូវកម្រិតជំនាញរបស់ខ្លួនទៅកាន់ថៅកែរោងចក្រ ដែលធ្វើឱ្យថៅកែរោងចក្រមិនមានព័ត៌មានគ្រប់-គ្រាន់អំពីកម្រិតជំនាញរបស់កម្មករដែលកំពុងដាក់ពាក្យធ្វើការងារ។

គ្រឹះស្ថានបណ្តុះបណ្តាលជំនាញភាគច្រើន នៅបន្តផ្តោតលើការអប់រំ និងបណ្តុះបណ្តាលជំនាញទូទៅក្នុងមុខវិជ្ជាវិស្វកម្ម ខណៈដែលកិច្ចសហការរវាងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញជាមួយឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរក្នុងការបណ្តុះបណ្តាល ការផ្ទេរចំណេះដឹង និងជំនាញនៅមានកម្រិត។ ការបណ្តុះបណ្តាលមុនការងារ (Pre-employment training) សម្រាបកម្មករ និងប្រធានក្រុមនៅមានកម្រិតតិចតួចនៅឡើយ។ រោងចក្រកាត់-ដេរភាគច្រើន ផ្តល់ការបណ្តុះបណ្តាលផ្ទាល់នៅនឹងកន្លែងដល់កម្មករ ហើយមានរោងចក្រតិចតួចប៉ុណ្ណោះ ដែលបានសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា (CGTI) ដើម្បីទទួលយកការបណ្តុះ-បណ្តាល។ ប្រធានក្រុមភាគច្រើនត្រូវបានដំឡើងឋានៈផ្ទៃក្នុងពីកម្រិតកម្មករ តាមរយៈការវាយតម្លៃលើគុណភាពការងារ ឬកូរួមជាមួយបទពិសោធន៍និងអតីតភាពដែរ។ ជាមួយគ្នានេះ ប្រធានផ្នែកមួយចំនួនក៏ទទួលបានការ

បណ្តុះបណ្តាល និងបំពាក់ជំនាញក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (Better Factories Cambodia) ដែលគាំទ្រដោយអង្គការអន្តរជាតិខាងការងារ (ILO)[11] ដោយផ្តោតសំខាន់លើទំនាក់ទំនងឧស្សាហកម្មជំនាញ គ្រប់គ្រងនិងភាពជាអ្នកដឹកនាំ និងសុខភាពនិងសុវត្ថិភាព។

ការស្ទង់មតិរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ[12]បានបង្ហាញថា នៅពេលស្ថានភាពសេដ្ឋកិច្ចចាប់ផ្តើមងើបឡើងវិញក្រោយវិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩ រោងចក្រវាយនភណ្ឌ និងកាត់ដេរនឹងមានតម្រូវការខ្ពស់ លើកម្លាំងពលកម្មសម្រាប់ដំណែងប្រតិបត្តិករផលិតកម្មកាត់ដេរ ប្រតិបត្តិករម៉ាស៊ីនវាយនភណ្ឌ អ្នកជំនាញផ្នែកគ្រឿងម៉ាស៊ីន កម្មករនិយោជិតដែលទាក់ទងនឹងវិស័យដឹកជញ្ជូន និងឃ្លាំងស្តុកទំនិញ ដែលភាគច្រើនស្ថិតក្នុងប្រភេទនៃកម្លាំងពលកម្មជំនាញទាប។ បន្ថែមពីនេះ រោងចក្រក៏បានលើកឡើងផងដែរថា ភាគច្រើននៃវិធីសាស្ត្របង្រៀន និងបណ្តុះបណ្តាលជំនាញនៅកម្ពុជានៅមិនទាន់មានភាពបត់បែនគ្រប់គ្រាន់ និងសមស្របទៅនឹងការវិវឌ្ឍនៃសង្គមសេដ្ឋកិច្ចជាតិ និងនិន្នាការក្នុងតំបន់និងសកលលោក ដែលបណ្តាលមកពីកត្តាចម្បងមួយចំនួន រួមមាន ១-វគ្គសិក្សាមានរយៈពេលវែងនិងមិនទាន់សម័យ ២-កង្វះខាតទំនាក់ទំនងរវាងឧស្សាហកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាល និង ៣-បញ្ហាផ្ទត់គំនិតក្នុងចំណោមយុវជនកម្ពុជាលើវិស័យកាត់ដេរ។

២.១.២-មុខតំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ និងអ្នកគ្រប់គ្រងថ្នាក់កណ្តាល

នៅកម្ពុជា មុខតំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ និងអ្នកគ្រប់គ្រងថ្នាក់កណ្តាលមានប្រមាណ ១០%[13] នៃការងារសរុបនៅក្នុងឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌ។ មុខតំណែងទាំងនេះរួមមានប្រធានផ្នែកផលិតកម្ម អ្នកគ្រប់គ្រងផលិតកម្ម វិស្វករឧស្សាហកម្ម អ្នកជំនាញវិជ្ជាជីវៈ និងអ្នកជំនាញឯកទេស (អ្នកឯកទេសខាងជួសជុលអ្នកគ្រប់គ្រងផ្នែកចីរភាព អ្នកគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន។ល។)។ ការអភិវឌ្ឍសមត្ថភាព និងជំនាញដល់កម្លាំងពលកម្មក្នុងស្រុកសម្រាប់ត្រៀមចាប់យកមុខតំណែងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ និងថ្នាក់កណ្តាល មានសារៈសំខាន់បំផុតសម្រាប់ធានានូវការឈានចាប់យកនូវខ្សែច្រវាក់ផលិតកម្ម ដែលផ្តល់តម្លៃបន្ថែមខ្ពស់ក្នុងឧស្សាហកម្មវាយ-នភណ្ឌ និងកាត់ដេរ។

គិតមកដល់បច្ចុប្បន្ន ប្រមាណ៩០% នៃរោងចក្រកាត់ដេរ និងវាយនភណ្ឌនៅប្រទេសកម្ពុជាជាកម្មសិទ្ធិរបស់វិនិយោគិនបរទេស។ ជាទូទៅ វិនិយោគិនបរទេសទាំងនោះ និយមប្រើប្រាស់ធនធានមនុស្សមកពីប្រទេសខ្លួនផ្ទាល់ ជាជាងធនធានមនុស្សក្នុងស្រុក សម្រាប់ដំណែងឬតួនាទីដែលមានតម្រូវការជំនាញជាន់ខ្ពស់

[11] គេហទំព័ររបស់ Better Factory Cambodia https://betterwork.org/wp-content/uploads/2018/12/Overview-of-all-trainings.pdf

[12] របាយការណ៍សិក្សារបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការវាយតម្លៃឆាប់រហ័សនៃតម្រូវការកម្លាំងពលកម្ម និងជំនាញក្នុងបរិបទនៃវិបត្តិកូវីដ-១៩។

[13] របាយការណ៍លទ្ធផលសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI) ស្តីពីការរួមចំណែកនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់សេដ្ឋកិច្ចកម្ពុជា។

និងតម្លៃបន្ថែមខ្ពស់។ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា កំពុងមានកំណើនតម្រូវការបុគ្គលិកនិយោជិតក្នុងស្រុកសម្រាប់ដំណែងជាអ្នកគ្រប់គ្រងថ្នាក់កណ្តាល ដើម្បីធានានូវប្រសិទ្ធភាពចំណាយ និងចីរភាពក្នុងរយៈពេលវែង។ ជាមួយគ្នានេះ រោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា ជួបប្រទះបញ្ហាប្រឈមក្នុងការស្វែងរកបុគ្គលិកបច្ចេកទេសដែលមានជំនាញខ្ពស់ (អ្នកបច្ចេកទេស វិស្វករឧស្សាហកម្ម។ល។) អ្នករចនាម៉ូដ បុគ្គលិកផ្នែកទីផ្សារ និងផ្នែកលក់ អ្នកយុទ្ធសាស្ត្រឬវិភាគធុរកិច្ច។ល។ បន្ថែមពីនេះ កម្ពុជាក៏មានកង្វះខាតនូវធនធានមនុស្សផ្នែកជំនាញទន់ (Soft skills) រួមមានការដោះស្រាយបញ្ហា ការសម្រេចចិត្ត និងការគ្រប់គ្រងអតិថិជន។ល។ និងជំនាញភាសាបរទេស។

កន្លងមក ទោះបីជាវិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា បានផ្តល់នៅវគ្គបណ្តុះបណ្តាលបច្ចេកទេស ការគ្រប់គ្រង និងការរចនាម៉ូដក៏ដោយ ក៏ការចូលរៀនក្នុងវគ្គបណ្តុះបណ្តាលទាំងនោះនូវមានកម្រិតដែលធ្វើឱ្យការប្រើប្រាស់ធនធានសម្រាប់អភិវឌ្ឍជំនាញរបស់វិទ្យាស្ថាននេះ មិនបានប្រើប្រាស់អស់សក្តានុពល។ ការណ៍នេះ បណ្តាលមកពីកត្តារួមផ្សំគ្នាទាំងក្នុងទីផ្សារការងារទាំងក្នុងផ្នែកតម្រូវការនិងផ្គត់ផ្គង់។ ជាក់ស្តែងកម្មករ ភាគច្រើនត្រូវបានជួលឱ្យបំពេញការងារក្នុងមុខតំណែងប្រតិបត្តិករដែលមានតម្រូវការជំនាញទាប ធ្វើឱ្យពួកគេយល់ឃើញថា ការងារនៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ មិនផ្តល់ផលប្រយោជន៍ច្រើនដល់ខ្លួន ឬផ្តល់នូវលក្ខខណ្ឌសមស្របនិងច្បាស់លាស់សម្រាប់អភិវឌ្ឍអាជីពនាពេលអនាគត។ បន្ថែមពីនេះ អាជីពក្នុងការរចនាម៉ូដនៅតែត្រូវបានយល់ថាជាជម្រើសអាជីពមួយដែលមិនមានសុវត្ថិភាព និងស្ថិរភាពផ្នែកហិរញ្ញវត្ថុក្នុងរយៈពេលវែង ហើយអ្នកដែលចាប់យកការបណ្តុះបណ្តាល និងអាជីពផ្នែកនេះភាគច្រើនចាត់ទុកថាជាចំណង់ចំណូលចិត្តប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត វិនិយោគិនបរទេសក៏មានភាពស្ទាក់ស្ទើរផងដែរ ក្នុងការជ្រើសរើសអ្នកគ្រប់គ្រងថ្នាក់កណ្តាលដែលជាជនជាតិខ្មែរដោយសារបញ្ហាភាសា និងកង្វះជំនាញ។ បុគ្គលិកគ្រប់គ្រងដែលជាជនជាតិខ្មែរមានការខ្វះខាតការយល់ដឹង និងចំណេះដឹងលើបច្ចេកវិទ្យាទំនើប (ស្វ័យប្រវត្តិកម្ម និងបរិវត្តកម្មឧស្សាហកម្មជំនាន់ ៤.0) និងទិដ្ឋភាពចីរភាព។ ទន្ទឹមនេះ កម្លាំងពលកម្មក្នុងស្រុក មានភាពខ្វះខាតនូវការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)[14] និងបទពិសោធផ្នែកវិស្វកម្មផងដែរ ដែលជាឧបសគ្គចម្បងក្នុងការផ្ទេរនិងទទួលយកនូវបច្ចេកវិទ្យាថ្មីដល់រោងចក្រក្នុងស្រុក និងការធានានូវចីរភាព នៃប្រតិបត្តិការរបស់រោងចក្រ។ បន្ថែមពីនេះ កម្ពុជាពុំទាន់មានគ្រឹះស្ថានបណ្តុះបណ្តាលជំនាញ លើផ្នែកផលិតកម្មវាយនភណ្ឌ និងការលក់រាយសម្លៀកបំពាក់គ្រប់គ្រាន់ឡើយ ការណ៍នេះបង្កជាបញ្ហាប្រឈមសម្រាប់ការធ្វើសមាហរណកម្មឧស្សាហកម្មប្រតិ-គមន៍ (Backward linkage) និងឧស្សាហកម្មអនុគមន៍ (Forward linkage) ក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរនេះ។

[14] របាយការណ៍លទ្ធផលសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០២១ ស្តីពីការស្រូបទាញនូវប្រយោជន៍នៃបរិវត្តកម្មឧស្សាហកម្មជំនាន់ ៤.0 តាមរយៈអភិវឌ្ឍន៍ជំនាញ។

បន្ថែមពីនេះ ទំនាក់ទំនងរវាងភាគីឧស្សាហកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាល ក៏នៅមានកម្រិតនៅឡើយដែរ។ គ្រឹះស្ថានបណ្តុះបណ្តាល និងឧស្សាហកម្ម មានការយល់ឃើញផ្ទុយគ្នាទៅលើគុណភាពបណ្តុះបណ្តាល និងការត្រៀមខ្លួនរបស់សិស្ស និស្សិត ឬសិក្ខាកាមដែលបញ្ចប់ការសិក្សា ដើម្បីឈានជើងចូលក្នុងទីផ្សារការងារ ទាំងប្រភេទជំនាញជាក់លាក់សម្រាប់ការងារ និងជំនាញទូទៅ[15]។ ជាក់ស្តែង គ្រឹះស្ថានបណ្តុះបណ្តាលយល់ឃើញថាគុណភាពបណ្តុះបណ្តាល និងការត្រៀមខ្លួនរបស់សិស្ស និស្សិត ឬសិក្ខាកាមដែលបញ្ចប់ការសិក្សា មានលក្ខណៈល្អគ្រប់គ្រាន់ក្នុងការឈានជើងចូលក្នុងទីផ្សារការងារ ខណៈដែលឧស្សាហកម្មយល់ឃើញថាគុណភាពបណ្តុះ-បណ្តាល និងការត្រៀមខ្លួនរបស់សិស្ស និស្សិត ឬសិក្ខាកាម នៅមានកម្រិត។ ការណ៍នេះ បញ្ជាក់បានថាទាំងសងខាង នៅមិនទាន់យល់ច្បាស់និងគ្រប់ជ្រុងជ្រោយនូវលក្ខខណ្ឌតម្រូវរបស់ភាគីម្ខាងទៀត។

២.២-ល្បាយផលិតផល

ការនាំចេញរបស់កម្ពុជា ពឹងផ្អែកជាចម្បងលើផលិតផលសម្លៀកបំពាក់ ដែលមានចំណែកសរុបប្រមាណជាង ៥៥%[16] នៃការនាំចេញផលិតផលកម្មន្តសាលសរុបកាលពីឆ្នាំ២០១៩។ ការរីកចំរើនយ៉ាងឆាប់រហ័ស នៃវិស័យកាត់ដេរនៅកម្ពុជា ធ្វើឱ្យពិពិធកម្មនៃឧស្សាហកម្មកម្ពុជាមានកម្រិត ខណៈដែលការនាំចេញផលិតផលកាត់ដេររបស់កម្ពុជាភាគច្រើន ផ្តោតលើចំណែកនៃច្រវាក់ផលិតកម្មដែលមានតម្លៃទាប និងឆ្ពោះទៅទីផ្សារសហរដ្ឋអាម៉េរិក និងសហភាពអ៊ីរ៉ុប។

ភាគច្រើននៃរោងចក្រវាយនភណ្ឌ និងកាត់ដេរនៅកម្ពុជា មានប្រតិបត្តិការក្នុងទម្រង់ស៊ីអ៊ីមធី ខណៈដែលការផ្លាស់ប្តូរឆ្ពោះទៅម៉ូដែលអាជីវកម្មប្រភេទអ៊ែហ្វអ្ហូ ប៊ី មានភាពយឺតយ៉ាវ។ ភាពយឺតយ៉ាវក្នុងដំណើរឆ្ពោះទៅរកម៉ូដែលអាជីវកម្មប្រភេទអ៊ែហ្វអ្ហូ ប៊ីពេញលេញ អាចបណ្តាលមកពីរោងចក្រកាត់ដេរនៅកម្ពុជាភាគច្រើនជាកម្មសិទ្ធិរបស់វិនិយោគិនបរទេសទាំងស្រុង[17] ដែលគេប្រើប្រាស់ប្រទេសកម្ពុជាជាទីតាំងនាំចេញសម្រាប់សកម្មភាពផលិតកម្មដែលមានតម្លៃទាប ដោយរក្សាសកម្មភាពតម្លៃបន្ថែមខ្ពស់ ដូចជាការរចនាម៉ូដ សកម្មភាពទិញលក់ និងហិរញ្ញ-ប្បទានជាដើម នៅក្នុងប្រទេសដើមរបស់ពួកគេ។ ក្នុងន័យនេះ កម្ពុជាត្រូវពង្រឹងប្រព័ន្ធអេកូឡូស៊ីនៃការរចនាម៉ូដផលិតផលទាំងមូលរបស់ខ្លួន ដើម្បីអាចជំរុញការធ្វើពិពិធកម្មផលិតផលម៉ូដ នោះរួមមានទីផ្សារឌីជីថល សមត្ថភាពព្យាករនិន្នាការនិងតម្រូវការទីផ្សារ ការរចនាម៉ូដ ប្រភពផ្គត់ផ្គង់ និងសមត្ថភាពអភិវឌ្ឍន៍ផលិតផល។

---

[15] របាយការណ៍លទ្ធផលសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០២១ ស្តីពីការស្រូបទាញនូវប្រយោជន៍នៃបរិវត្តកម្មឧស្សាហកម្មជំនាន់៤.០ តាមរយៈ អភិវឌ្ឍន៍ជំនាញ។

[16] ផែនទីពាណិជ្ជកម្មព័ត៌មាននិងទូរគមនាគមន៍(ITC Trade Map) ឆ្នាំ២០២១

[17] គេហទំព័រ Enterprise Survey ខែកក្កដាឆ្នាំ២០២១ តាមរយៈ÷
https://www.enterprisesurveys.org/content/dam/enterprisesurveys/documents/country-highlights/Cambodia-2016.pdf

បន្ថែមពីនេះ បច្ចុប្បន្ននេះប្រទេសកម្ពុជាកំពុងខ្វះខាតអ្នកជំនាញផ្នែករចនាម៉ូដ និងស្វ្គីយ៉ូរចនាម៉ូដ។ ម៉ាកយីហោពិភពលោកភាគច្រើនមានស្វ្គីយ៉ូរចនាម៉ូដ នៅក្នុងប្រទេសដើមរបស់វិនិយោគិនដែលមានធនធានជំនាញ និងទីតាំងសមរម្យគ្រប់គ្រាន់ សម្រាប់ផ្តល់នូវគំរូរចនាម៉ូដដល់រោងចក្រផលិតនៅកម្ពុជាសម្រាប់ការអភិវឌ្ឍផលិតកម្ម។ ជាមួយគ្នានេះ កម្ពុជាក៏ខ្វះខាតការផ្គត់ផ្គង់វត្ថុធាតុដើមក្នុងស្រុក ដែលធ្វើឱ្យសមត្ថភាពពិសោធន៍លើការរចនាម៉ូដនិងអភិវឌ្ឍន៍ផលិតផលមានកម្រិត។ កន្លងមក កម្ពុជាពុំទាន់ទទួលបាននូវវិនិយោគច្រើន ដើម្បីជំរុញសមាហរណកម្មប្រតិគមន៍ (Backward integration) នៅក្នុងឧស្សាហកម្មកាត់ដេរនៅឡើយ ដោយសារកត្តាចម្បងមួយចំនួនរួមមាន ១-កង្វះមូលធននិងវត្ថុធាតុដើមដើម្បីផលិតក្រណាត់និងអំបោះ ២-កង្វះកម្លាំងពលកម្មជំនាញ និង ៣-ថ្លៃដើមខ្ពស់ក្នុងប្រតិបត្តិការ រួមមានការដឹកជញ្ជូនឬឡូជីស្ទិក និងនីតិវិធីពាក់ព័ន្ធដែលត្រូវចំណាយពេលយូរ។

២.៣-ផលិតភាព

ជាការអង្កេត ផលិតភាពជាមធ្យមរបស់កម្លាំងពលកម្មកម្ពុជាក្នុងឧស្សាហកម្មវាយនភណ្ឌ មានកម្រិតទាបធៀបនឹងប្រទេសដែលជាដៃគូប្រកួតប្រជែង បើទោះបីជាប្រាក់ឈ្នួលមានអត្រាទាបក៏ដោយ។ ម្យ៉ាងវិញទៀត ការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមា បាននិងកំពុងជះឥទ្ធិពលដល់ភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងទីផ្សារសកលផងដែរ។

តារាងទី៤ កម្រិតនៃផលិតភាពក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេររបស់កម្ពុជា ធៀបនឹងបណ្តាលប្រទេសមួយចំនួន

	កម្ពុជា	ចិន	វៀតណាម	ភ្ជីគី	ឥណ្ឌា	បង់ក្লាដែស
កម្រិតផលិតភាព	៣៥%-៤៥%	> ៨0%	> ៥0%- ៦0%	> ៨0%	> ៥៥%- ៦៥%	៤៥%-៥៥%

ប្រភព: សៀវភៅណែនាំអង្គការផលិតភាពអាស៊ី ឆ្នាំ២០២0 (Asian Productivity Organisation Handbook)

កត្តាចម្បងដែលបណ្តាលឱ្យផលិតភាពនៃកម្លាំងពលកម្មកម្ពុជា ក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរមានកម្រិតទាបជាងបណ្តាប្រទេសគូប្រកួតប្រជែង រួមមានកង្វះប្រសិទ្ធភាពនៃប្រព័ន្ធអេកូអប់រំនិងអភិវឌ្ឍន៍ជំនាញ ភាពមានកម្រិតនៃសមត្ថភាពទទួលយកនូវបច្ចេកវិទ្យាទំនើប បញ្ហាផ្នត់គំនិតរបស់វិនិយោគិន និងកង្វះប្រសិទ្ធភាពនៃទំនាក់ទំនងរវាងឧស្សាហកម្មនិងគ្រឹះស្ថានបណ្តុះបណ្តាល។

ក-ប្រព័ន្ធអេកូអប់រំនិងអភិវឌ្ឍន៍ជំនាញ

ការអប់រំមូលដ្ឋានរបស់កម្លាំងពលកម្មកម្ពុជានៅមានកម្រិតទាប ដែលជាឧបសគ្គដល់ដំណើរការ និងប្រសិទ្ធភាពនៃបណ្តុះបណ្តាលជំនាញ។ កម្មករភាគច្រើនមានចំណេះដឹងលេខនព្វន្តតិចតួច ធ្វើឱ្យមានភាពលំបាកក្នុងការគណនាលេខកម្រិតមូលដ្ឋាន រួមបញ្ចូលទាំងកម្រិតនៃការយល់ដឹងអំពីប្រព័ន្ធលើកទឹកចិត្តផ្នែកគុណភាព

ការងារផងដែរ។ ម្យ៉ាងវិញទៀត កម្មករភាគច្រើននិងបុគ្គលិកកម្រិតអ្នកគ្រប់គ្រងថ្នាក់កណ្តាលមួយចំនួន មានការពិបាកក្នុងការប្រាស្រ័យទាក់ទងជាភាសាអង់គ្លេស និងភាសាផ្សេងទៀតក្រៅពីភាសាកំណើតរបស់ខ្លួន ស្របពេលដែលម្ចាស់ ឬតំណាងរោងចក្រកាត់ដេរ និងវាយនភណ្ឌភាគច្រើនជាជនជាតិបរទេស។ ឧបសគ្គនៃភាសាធ្វើឱ្យមានការពិបាកក្នុងការយល់ឱ្យបានគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅអំពីការណែនាំ ឬបច្ចេកទេសនានាទាក់ទងនឹងដំណើរការផលិតកម្ម។ ការណ៍នេះជះឥទ្ធិពលដល់ផលិតភាពនៃកម្លាំងពលកម្ម និងដំណើរការផលិតកម្ម។

ខ-ការទទួលយកនូវបច្ចេកវិទ្យាថ្មី

នាពេលបច្ចុប្បន្ន បច្ចេកវិទ្យាដើរតួនាទីសំខាន់ដើម្បីជំរុញការលើកកម្ពស់ផលិតភាព តាមរយៈស្វ័យ-ប្រវត្តិកម្មពេញលេញ ឬពាក់កណ្តាលពេញលេញនៃដំណើរការផលិតកម្ម។ យ៉ាងណាមិញ ការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះ នៅមិនទាន់បានអនុវត្ត និងទាញផលប្រយោជន៍ឱ្យអស់ពីសក្តានុពលនៅឡើយ ដោយសារបញ្ហាកង្វះចំណេះដឹងមូលដ្ឋាន។ ជាការអង្កេត ម្ចាស់រោងចក្រភាគច្រើនជាជនបរទេស ចូលចិត្តជួលកម្មករបុគ្គលិកបរទេស ឬអ្នកជំនាញមកពីប្រទេសដើមកំណើតរបស់ខ្លួន ឱ្យបំពេញការងារពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យា ដើម្បីធានានូវប្រសិទ្ធភាពនិងផលិតភាពការងារ បើទោះប្រាក់ឈ្នួលមានកម្រិតខ្ពស់ធៀបនឹងកម្លាំងពលកម្មក្នុងស្រុកក៏ដោយ។ ទន្ទឹមនេះ ការផ្ទេរនិងការទទួលចំណេះដឹងបច្ចេកវិទ្យាក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជាពីរោងចក្រជាកម្មសិទ្ធបរទេស មករោងចក្រក្នុងស្រុកមានកម្រិតតិចតួច។ ជាក់ស្តែង រោងចក្រក្នុងស្រុកជាច្រើននៅតែបន្តប្រើប្រាស់សៀវភៅបញ្ជីឬទម្រង់ប្រមូលទិន្នន័យដោយដៃ ដើម្បីកត់ត្រាទិន្នន័យផលិតកម្ម។

ទន្ទឹមនេះ កម្រិតនៃការយល់ដឹងពីបដិវត្តកម្មឧស្សាហកម្មជំនាន់ទី ៤.០ ក្នុងចំណោមនិយោជកនៅកម្ពុជាហាក់មានកម្រិតទាបនៅឡើយ បើធៀបទៅនឹងប្រទេសក្នុងតំបន់ រួមមានឥណ្ឌូណេស៊ី ហ្វីលីពីន និងវៀតណាម[18]។ និយោជកក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ប្រមាណតែ ១ ភាគ ៣ ប៉ុណ្ណោះដែលមានការយល់ដឹងខ្ពស់អំពីបដិវត្តកម្មឧស្សាហកម្មជំនាន់ ៤.០ និងការទទួលយកនិងប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗ។

គ-ផ្នត់គំនិតរបស់វិនិយោគិន

វិនិយោគិនភាគច្រើនក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជាផ្តល់អាទិភាពទាប ឬមិនសូវចាប់អារម្មណ៍លើគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ជំនាញដែលផ្សារភ្ជាប់ទៅនឹងការពង្រឹងផលិតភាព។ ជាទូទៅ វិនិយោគិនទាំងនោះចូលចិត្តការបណ្តុះបណ្តាលក្នុងអំឡុងពេលបំពេញការងារជាក់ស្តែង (On-the-job training) ជាជាងការវិនិយោគលើការអភិវឌ្ឍជំនាញជាមួយគ្រឹះស្ថានបណ្តុះបណ្តាលឬដៃគូពាក់ព័ន្ធ យល់ឃើញថា ជាការចំណាយពេលវេលា និងធនធានមិនមានប្រសិទ្ធភាព។ ជាមួយគ្នានេះ វិនិយោគិនយល់ឃើញថា កម្មករភាគច្រើនខ្វះ

---

[18] របាយការណ៍លទ្ធផលសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០២១ ស្តីពីការស្រូបទាញនូវប្រយោជន៍នៃបរិវត្តកម្មឧស្សាហកម្មជំនាន់៤.០ តាមរយៈអភិវឌ្ឍន៍ជំនាញ។

ជំនាញទន់ (Soft skills) រួមមានភាពជាម្ចាស់លើការងារ ការលើកទឹកចិត្តខ្លួនឯង ការគ្រប់គ្រងពេលវេលា និងការទទួលខុសត្រូវ។ល។ ការណ៍នេះក៏អាចឆ្លុះបញ្ចាំងពីភាពមានកម្រិតគុណភាពអប់រំ ដោយហេតុថាជំនាញទន់ជាបញ្ហាពាក់ព័ន្ធនឹងកត្តាផ្នត់គំនិត និងបំណិនជីវិតដែលត្រូវបណ្តុះបណ្តាលចាប់តាំងពីការអប់រំកម្រិតមូលដ្ឋាន។ ក្នុងន័យនេះ កម្ពុជាចាំបាច់ត្រូវវិភាគស៊ីជម្រៅនិងលម្អិត អំពីការចំណាយនិងអត្ថប្រយោជន៍នៃគំនិតផ្តួចផ្តើមអភិវឌ្ឍជំនាញដែលផ្សារភ្ជាប់ទៅនឹងការពង្រីងផលិតភាព ដើម្បីបញ្ជាបដល់តួអង្គដែលមានសិទ្ធិសម្រេចលើការអភិវឌ្ឍជំនាញថ្មី បង្កើនជំនាញ និងបណ្តុះជំនាញឡើងវិញនិងពហុជំនាញ។

ឃ-ទំនាក់ទំនងឧស្សាហកម្ម

ទំនាក់ទំនងរវាងភាគីឧស្សាហកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាលនៅមានកម្រិតនៅឡើយ ភាគច្រើនភាគីទាំងសងខាងមានការយល់ដឹងតិចតួចពីតម្រូវការ និងលក្ខខណ្ឌតម្រូវរបស់ភាគីម្ខាងទៀត។ ជាក់ស្តែង ម្ចាស់រោងចក្រវាយនភណ្ឌ និងកាត់ដេរនៅកម្ពុជាដែលភាគច្រើនជាជនបរទេស មិនមានការយល់ច្បាស់អំពីវត្តមាននៃគ្រឹះស្ថានបណ្តុះបណ្តាលសំខាន់ៗនៅកម្ពុជា រួមមានវិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា សាកលវិទ្យាល័យជាតិគ្រប់គ្រង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលផ្សេងៗទៀត ដែលកំពុងផ្តល់ការបណ្តុះបណ្តាលជំនាញ និងបច្ចេកទេសតាមឯកទេសរៀងៗខ្លួន។

នាពេលបច្ចុប្បន្ន កម្ពុជាមានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈសរុបចំនួនជាង ២០០ គ្រឹះស្ថាន ក្នុងនោះ ៥៦ ជាគ្រឹះស្ថានរបស់រដ្ឋ។ ក្នុងចំណោមគ្រឹះស្ថានបណ្តុះបណ្តាលទាំងនោះមានតែវិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជាតែមួយគត់ ដែលផ្តល់វគ្គបណ្តុះបណ្តាលលើមុខជំនាញផ្នែកឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ និងបានរួមចំណែកដោយផ្ទាល់ដល់ការបង្កើនផលិតភាពកម្លាំងពលកម្មកម្ពុជាក្នុងឧស្សាហកម្មនេះ[19]។

២.៤-ចីរភាព

តរិយាបថនៃការប្រើប្រាស់ប្រកបដោយភាពទទួលខុសត្រូវ សេដ្ឋកិច្ចចក្រា ផលិតកម្មស្អាត និងខ្សែច្រវាក់ផ្គត់ផ្គង់ប្រកបដោយក្រមសីលធម៌ (Ethical supply chains) បាននិងកំពុងក្លាយជានិន្នាការសកលសំខាន់ៗដែលជះឥទ្ធិពលលើឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ ជាពិសេសក្នុងអំឡុង ២ឆ្នាំ ចុងក្រោយ ដោយសារបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩។ ការយល់ដឹងរបស់អ្នកប្រើប្រាស់និងវិនិយោគិន និងការដាក់ចេញបទប្បញ្ញត្តិបរិស្ថាននានា បាននិងកំពុងធ្វើឱ្យយីហោផលិតផលវាយនភណ្ឌ និងកាត់ដេរនៅក្នុងសកលលោក ដាក់ចេញនូវគោលដៅចីរភាពប្រកបដោយមហិច្ឆតា។

---

[19] ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ២០២៣-២០៣៥

ជាទូទៅ រោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា ពឹងផ្អែកខ្លាំងលើទីផ្សារសហរដ្ឋអាមេរិក សហភាពអ៊ីរ៉ុប និងប្រទេសជប៉ុន ដើម្បីធ្វើការនាំចេញ។ ស្របពេលដែលប្រទេសទាំងនោះកំពុងរឹតបន្តឹងអនុលោមភាពតាមបទដ្ឋានចីរភាព កិច្ចខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តរបស់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរនៅកម្ពុជា លើការកាត់បន្ថយផលប៉ះពាល់បរិស្ថានហាក់នៅមានកម្រិតនៅឡើយ[20] កត្តានេះអាចជះឥទ្ធិពលដល់ភាពប្រកួតប្រជែងនៃផលិតផលវាយនភណ្ឌ និងកាត់ដេររបស់កម្ពុជាដែរ។

នៅកម្ពុជា ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ **ឆ្នាំ១៩៩៦** តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) សម្រាប់គម្រោងសាធារណៈនិងឯកជន ដែលអាចមានផលប៉ះពាល់ដល់បរិស្ថាន[21]។ យ៉ាងណាមិញ ការអនុវត្តច្បាប់នេះក៏មិនទាន់មានការត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តនៅឡើយ ដោយសារកង្វះធនធានមនុស្សមានជំនាញ។ ក្នុងឆ្នាំ២០១៥ ក្រសួងបរិស្ថានបានចាប់ផ្តើមរៀបចំសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់បរិស្ថាននានា ប៉ុន្តែការរៀបចំក្រមនេះមិនទាន់ត្រូវបានបញ្ចប់នៅឡើយ។

ក្នុងន័យនេះ ការអប់រំផ្សព្វផ្សាយដល់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ និងក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពីអត្ថប្រយោជន៍នៃការអនុវត្តវិធានការចីរភាពសង្គម និងបរិស្ថាន មានសារៈសំខាន់ដើម្បីធានានូវអនុលោមភាព។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលក៏អាចពិចារណាក្នុងការផ្តល់ឧបត្ថម្ភធនដល់រោងចក្រវាយនភណ្ឌ និងកាត់ដេរ ដើម្បីទទួលយក និងប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗ និងនាំចូលឧបករណ៍ ឬអ្នកមានទេពកោសល្យពីបរទេសដើម្បីជួយផ្តល់ដំណោះស្រាយលើបញ្ហាផលិតកម្មស្អាត។

រាជរដ្ឋាភិបាល ក៏បាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងអនុលោមភាពផ្នែកសង្គមក្នុងប្រភេទឧស្សាហកម្មអតិពលកម្ម ជាពិសេសក្នុងឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌ។ ដើម្បីធានានូវអនុលោមភាពផ្នែកសង្គមប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលក៏ត្រូវគិតគូរផងដែរលើការបញ្ឈប់អំពើហិង្សាផ្នែកលើយេនឌ័រ ផ្តល់ទីកន្លែងការងារសមស្រប ផ្តល់នូវលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាពនិងអនាម័យ ផ្តល់សិទ្ធិអំណាចដល់ស្ត្រី ឱកាសក្នុងការអភិវឌ្ឍគន្លងអាជីពឬការឡើងដំណែង ប្រព័ន្ធក្នុងការផ្តល់ប្រាក់ឈ្នួល និងការលើកទឹកចិត្តនានាប្រកបដោយតម្លាភាព[22]។ល។ បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏ត្រូវគិតគូរផងដែរលើស្ថិរភាពនៃក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដោយត្រូវថ្លឹងថ្លែងយ៉ាងម៉ត់ចត់រវាងផលប្រយោជន៍របស់កម្មករ និងវិនិយោគិន[23]។

---

[20] គេហទំព័រ https://www.geres.eu/en/our-actions/our-projects/promotion-sustainable-energy-practices-garment-sector-cambodia/ ដែលបានដកស្រង់ការពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១

[21] របាយការណ៍របស់អង្គការទិន្នន័យអំពីការអភិវឌ្ឍ(Open Development Cambodia) ឆ្នាំ២០១៩ ស្តីពីការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន តាមរយៈគេហទំព័រ÷ https://opendevelopmentcambodia.net/topics/environmental-impact-assessments/

[22] ព្រឹត្តិបត្រវិស័យកាត់ដេរ និងស្បែកជើងកម្ពុជា លេខ៨

[23] គេហទំព័រ https://survey.ituc-csi.org/Cambodia.html?lang=en#tabs-2 ដែលបានដកស្រង់កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១។

២.៥-ការចាប់យកបច្ចេកវិទ្យា

ការទទួលយកនូវបច្ចេកវិទ្យាថ្មីៗសម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា នៅមានកម្រិតទាបនៅឡើយ។ ទោះបីជារោងចក្រវាយនភណ្ឌ និងកាត់ដេរជាកម្មសិទ្ធិរបស់បរទេសកំពុងប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងផ្នែកមួយចំនួននៃផលិតកម្មក៏ដោយ ក៏កម្រិតនៃការផ្ទេរនិងទទួលយកនូវបច្ចេកវិទ្យារបស់ក្រុមហ៊ុនក្នុងស្រុកនៅមានកម្រិតតិចតួច។

កម្រិតនៃការអភិវឌ្ឍបច្ចេកវិទ្យាក្នុងផ្នែកដេរនិងវេចខ្ចប់ ក៏នៅមានកម្រិតនៅឡើយដែរសូម្បីក្នុងបណ្តារោងចក្រដែលជាកម្មសិទ្ធិបរទេស។ អ្នកគ្រប់គ្រងមកពីប្រទេសដើមរបស់វិនិយោគិន មានឆន្ទៈក្នុងការវិនិយោគលើបច្ចេកវិទ្យាឌីជីថល ដើម្បីសម្រួលដល់ដំណើរការការងារ និងផលិតកម្ម ប៉ុន្តែមិនចង់វិនិយោគលើគ្រឿងចក្រធុនធ្ងន់ និងឧបករណ៍សម្រាប់ប្រតិបត្តិការដេរ (ម៉ាស៊ីនដាក់ហោប៉ៅស្វ័យប្រវត្តិ ដៃមនុស្សយន្តដេរ)ទេ ដោយសារកង្វះនូវព័ត៌មាន និងការយល់ដឹងទាក់ទងនឹងការលើកទឹកចិត្តវិនិយោគក្នុងវិស័យ ឬសកម្មភាពដែលជាអាទិភាពដែលបានកំណត់ដោយរាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើបច្ចុប្បន្នកម្មលើក្របខ័ណ្ឌនៃការលើកទឹកចិត្តសម្រាប់វិនិយោគិនស្របតាមច្បាប់ស្តីពីវិនិយោគ (ថ្មី) ដែលផ្តល់ការលើកទឹកចិត្តដល់ គ.ល.គ. ក្នុងការធ្វើទំនើបកម្មគ្រឿងម៉ាស៊ីនរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២៧ ស្តីពីការទទួលបានការកាត់កងចំណាយក្នុងអត្រារហូតដល់ ១៥0% ពីមូលដ្ឋានគិតពន្ធ ចំពោះការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីន ដើម្បីបម្រើឱ្យខ្សែ-ច្រវាក់ផលិតកម្មរបស់ គ.ល.គ.។

ជាមួយគ្នានេះ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ទំនើបៗនៅតាមរោងចក្រក្នុងស្រុកក៏មានកម្រិតតិចតួចនៅឡើយ ខណៈដែលភាគច្រើននៃរោងចក្រទាំងនោះ នៅតែធ្វើការកត់ត្រាប្រតិបត្តិការដោយដៃ ឬដោយកម្មវិធី Microsoft Excel សម្រាប់ការប្រមូលព័ត៌មាន ដែលឆ្លុះបញ្ចាំងអំពីភាពមានកម្រិតនៃការយល់ដឹងលើអត្ថប្រយោជន៍នៃឌីជីថលូបនីយកម្ម និងបច្ចេកវិទ្យាឌីជីថល ក្នុងយុគសម័យបដិវត្តកម្មឧស្សាហ-កម្មជំនាន់ ៤.0 ក្នុងចំណោមម្ចាស់រោងចក្រ និងបុគ្គលិកក្នុងស្រុក។ ការណ៍នេះ ធ្វើឱ្យវិនិយោគិនក្នុងស្រុកមានការស្ទាក់ស្ទើរក្នុងការវិនិយោគលើឌីជីថលូបនីយកម្ម និងបច្ចេកវិទ្យាឌីជីថល ខណៈដែលកម្លាំងពលកម្ម ក្នុងស្រុកមិនមានជំនាញគ្រប់គ្រាន់ ក្នុងការចូលរួមជំរុញឱ្យរោងចក្រក្នុងស្រុកធ្វើការផ្លាស់ប្តូរឆ្ពោះទៅរកបច្ចេកវិទ្យាទំនើប។

២.៦-ហេដ្ឋារចនាសម្ព័ន្ធ

តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០០៥ ដើម្បីទាក់ទាញការវិនិយោគសម្រាប់ការផលិតដែលផ្តោតលើការនាំចេញ ក្នុងនោះរួមបញ្ចូលទាំងវិស័យវាយនភណ្ឌ និងកាត់ដេរផងដែរ។ វិនិយោគិននៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទទួលបានអត្ថប្រយោជន៍ជាច្រើន តាមរយៈសិទ្ធិក្នុងការស្នើសុំឋានៈជា គ.ល.គ. និងទទួលបានការលើកទឹកចិត្ត និងការការពារដូចគ្នានឹង គ.ល.គ.។ ជាក់ស្តែង វិនិយោគិននៅក្នុងតំបន់

សេដ្ឋកិច្ចពិសេស អាចទទួលបានសេវាច្រកចេញចូលតែមួយនៅនឹងកន្លែងតាមរយៈរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស តាមរយៈរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញឡូជីស្ទិកដែលមានស្រាប់ ការទទួលបាននីតិវិធីគយពិសេសជាដើម។ ទោះយ៉ាងនេះក៏ដោយ ក៏រោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជាមួយចំនួនរក្សាទីតាំងផលិតកម្មរបស់ខ្លួនក្រៅតំបន់សេដ្ឋកិច្ចពិសេស ដោយសារការបត់បែនក្នុងការជ្រើសរើសទីតាំងផលិតកម្ម និងលក្ខខណ្ឌអំណោយផលផ្សេងៗមួយចំនួនទៀត។

ជាមធ្យម ថ្លៃអគ្គិសនីរួមចំណែកប្រមាណ៣% នៃចំណាយសរុបរបស់រោងចក្រប្រភេទស៊ីអ៊ីមធីនៅកម្ពុជា។ ពាក់ព័ន្ធនឹងស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី ក្រសួងរ៉ែនិងថាមពល និងអគ្គិសនីកម្ពុជា បានអនុវត្តការងាររបស់ខ្លួនដោយធ្វើយ៉ាងណាសម្រេចឱ្យបាននូវសូចនាករ “ធានាការដាច់ចរន្តអគ្គិសនីមិនឱ្យលើស ១២ដង ក្នុង១ឆ្នាំ ហើយរយៈពេលដាច់ចរន្តអគ្គិសនីមិនឱ្យលើស ២៤ម៉ោង ក្នុង១ឆ្នាំ”។ សូចនាករនេះក៏មានលើកនៅក្នុងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ និងឯកសារសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាផងដែរ។ ក្រសួងរ៉ែ និងថាមពលក៏បាននិងកំពុងជំរុញការអនុវត្តគោលនយោបាយ និងកម្មវិធីប្រសិទ្ធភាពថាមពល រួមទាំងការបណ្តុះ-បណ្តាលសវនករថាមពលផងដែរ។

ទន្ទឹមនេះ ប្រព័ន្ធឡូជីស្ទិកនៅកម្ពុជា ពុំទាន់មានលក្ខណៈល្អគ្រប់គ្រាន់សមស្រប ដើម្បីគាំទ្រដល់សកម្មភាពឧស្សាហកម្មឱ្យអស់សក្តានុពលនៅឡើយ។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមិនទាន់ឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការ ដោយហេតុថាថ្លៃដឹកជញ្ជូនខ្ពស់ កង្វះយានយន្តដឹកជញ្ជូន កង្វះការថែទាំផ្លូវថ្នល់ និងកង្វះថវិកាសម្រាប់ការអភិវឌ្ឍ។ នេះជាបញ្ហាប្រឈមចម្បងមួយចំនួនដែលរោងចក្រផលិតវាយនភណ្ឌ និងកាត់ដេរកម្ពុជាបាននិងកំពុងជួបប្រទះ។ នៅកម្ពុជា ការដឹកជញ្ជូនត្រូវចំណាយពេលវេលាយូរជាងប្រទេសជាដៃគូប្រកួតប្រជែងសំខាន់ៗនៅក្នុងតំបន់។ ម្យ៉ាងវិញទៀត រថយន្តដឹកទំនិញនៅកម្ពុជាភាគច្រើនជារថយន្តជជុះពីកូរ៉េខាងត្បូង ជប៉ុន និងអាម៉េរិក ដែលរួមចំណែកធ្វើឱ្យការដឹកជញ្ជូនទៅកាន់កំពង់ផែនៃប្រទេសវៀតណាម និងថៃ ត្រូវចំណាយថ្លៃដើមខ្ពស់ ខណៈដែលការប្រើប្រាស់ប្រព័ន្ធ GPS និង IT ក្នុងការតាមដាននិងគ្រប់គ្រងនាវាដឹកជញ្ជូននៅមានកម្រិត។

២.៧-ពាណិជ្ជកម្ម និងអន្តរជាតូបនីយកម្ម

ទីផ្សារក្នុងស្រុករបស់កម្ពុជាមានទំហំតូចសម្រាប់ផលិតផលសម្លៀកបំពាក់។ ដូច្នេះ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ចាំបាច់ត្រូវពង្រឹងនិងពង្រីកសក្តានុពលរបស់ខ្លួនក្នុងការផ្សារភ្ជាប់ទៅនឹងខ្សែ-ច្រវាក់ផលិតកម្មសកល និងពង្រីកការចាប់យកចំណែកទីផ្សារសកលឱ្យបានច្រើន។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាមានភាពចាំបាច់ក្នុងការដាក់ចេញនូវគោលនយោបាយអន្តរាគមន៍ ដើម្បីពង្រឹងភាពប្រកួតប្រជែងនៃថ្លៃដើម កែលម្អហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែប្រសើរឡើង ពង្រីកទំនាក់ទំនងពាណិជ្ជកម្មជាមួយទីផ្សារនិងប្រទេសអ្នកផ្គត់ផ្គង់ធំៗ និងបង្កើននូវភាពងាយស្រួលនៃការធ្វើអាជីវកម្ម។

មេរៀន និងបទពិសោធនៃការរីករាលដាលជំងឺកូវីដ-១៩ បានធ្វើឱ្យម៉ាកយីហោសកលមួយចំនួនកំពុងបង្វែរការបញ្ជាទិញផលិតផលវាយនភណ្ឌ និងកាត់ដេរ ទៅរកប្រភពដែលមានមូលដ្ឋាននៅក្បែរខាង ដើម្បីកាត់បន្ថយនូវហានិភ័យផ្នែកទីតាំងភូមិសាស្ត្រ កាត់បន្ថយបន្ទុកសារពើភ័ណ្ឌ និងបញ្ហាប្រឈមផ្នែកលទ្ធកម្មដែលត្រូវចំណាយពេលវេលាយូរ។

កម្ពុជាអាចនឹងចេញផុតពីឋានៈប្រទេសមានកម្រិតអភិវឌ្ឍណ៍តិចតួច ក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខនេះ ការណ៍នេះនឹងធ្វើឱ្យកម្ពុជាត្រូវបាត់បង់លក្ខខណ្ឌអនុគ្រោះមួយចំនួន ក្នុងការនាំចេញផលិតផលវាយនភណ្ឌ និងកាត់ដេររបស់ខ្លួនទៅកាន់ទីផ្សារចម្បងៗ ជាពិសេសសហភាពអ៊ីរ៉ុប។ ការបាត់បង់លក្ខខណ្ឌអនុគ្រោះ (ដោយផ្នែកឬពេញលេញ) បូករួមជាមួយនឹងសម្ពាធនៃការកើនឡើងនៃប្រាក់ឈ្នួល និងផលិតភាពទាបនៃកម្លាំងពលកម្មកម្ពុជា នឹងមានផលអវិជ្ជមានដល់ភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងវិស័យនេះ។

ជាមួយគ្នានេះ កម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើការនាំចូលនូវវត្ថុធាតុដើម សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៩ កម្ពុជានាំចូលវត្ថុធាតុដើមសម្រាប់ផលិតកម្មវាយនភណ្ឌពីចិនប្រមាណ ៧០%។ ការពឹងផ្អែកខ្លាំងលើការនាំចូលនេះ បានធ្វើឱ្យរោងចក្រវាយនភណ្ឌ និងកាត់ដេរនៅកម្ពុជា ជួបប្រទះកង្វះខាតក្រណាត់ និងវត្ថុធាតុដើមផ្សេងទៀតក្នុងអំឡុងពេលនៃការរីករាលដាលកូវីដ-១៩។ ក្នុងន័យនេះ រោងចក្រវាយនភណ្ឌ និងកាត់ដេរមានបំណងចង់ពង្រីកគោលដៅផ្គត់ផ្គង់វត្ថុធាតុដើមពីប្រទេសជិតខាង នៅក្នុងតំបន់អាស៊ាន ដើម្បីកាត់បន្ថយការពឹងផ្អែកខ្លាំងលើការនាំចូលពីប្រទេសចិន។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងខិតខំប្រឹងប្រែងពង្រឹងនូវគុណភាពហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញការតភ្ជាប់ពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន។

២.៨-ឧទាហរណ៍

វិនិយោគិនបរទេស ពុំសូវចាប់អារម្មណ៍ក្នុងការវិនិយោគលើនវានុវត្តន៍ក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរនៅកម្ពុជាឡើយ ព្រោះវិនិយោគិនទាំងនោះយល់ថាការវិនិយោគបែបនេះ មិនផ្តល់ផលចំណេញដល់ពួកគេច្រើន។ ទន្ទឹមនេះ ថ្វីត្បិតសហគ្រិនជំនាន់ក្រោយរបស់កម្ពុជាហាក់មានការចាប់អារម្មណ៍ និងមានភាពសកម្មច្រើនឡើងៗក្នុងវិស័យបច្ចេកវិទ្យា និងនវានុវត្តន៍ក៏ដោយ ក៏ភាគច្រើននៃសកម្មភាពទាំងនេះផ្តោតលើតែវិស័យសេវាកម្ម ជាជាងវិស័យឧស្សាហកម្ម។

ក្នុងបរិបទនេះ ដើម្បីពង្រឹងភាពប្រកួតប្រជែង និងទាញយកផលប្រយោជន៍ពីកាលានុវត្តភាពនៃវិស័យនេះឱ្យអស់ពីលទ្ធភាព រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ជំរុញនវានុវត្តន៍នៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរក្នុងស្រុក ដោយផ្តោតលើចំណុចខាងក្រោម÷

១-ដំណាក់កាលមុនផលិតកម្ម និងដំណាក់កាលផលិតកម្ម ដែលបច្ចុប្បន្ននេះភាគច្រើនអនុវត្តដោយអ្នកជំនាញបរទេស

២-ការផ្គត់ផ្គង់វត្ថុធាតុដើម និងការរៀបចំប្រព័ន្ធឡូជីស្ទិកក្នុងការដឹកជញ្ជូនទំនិញ ដែលបច្ចុប្បន្នត្រូវបានធ្វើឡើងនៅក្រៅប្រទេស នៅទីស្នាក់ការកណ្តាលនៃសាជីវកម្មពហុជាតិបរទេសដែលមានសាខាផលិត-កម្មនៅកម្ពុជា និង

៣-ការរចនាម៉ូដ និងយីហោ ដែលអាចធ្វើបានដោយក្រុមហ៊ុនក្នុងស្រុក និងការពារកម្មសិទ្ធិបញ្ញា។

២.៩-អតិបាលកិច្ច

កត្តាគន្លឹះក្នុងការកសាង និងរក្សាបាននូវទំនុកចិត្តរបស់វិនិយោគិន រួមមានស្ថិរភាពនៃក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ តម្លាភាព ប្រព័ន្ធច្បាប់ដ៏រឹងមាំ និងអ្នកជំនាញក្នុងការយល់ដឹងនិងអនុវត្តនូវច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។ ម្យ៉ាងវិញទៀត កង្វះនូវយន្តការសម្របសម្រួលនិងជំរុញការអនុវត្ត និងសមត្ថភាពស្ថាប័នក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិថ្មីឱ្យមានប្រសិទ្ធភាព និងយុត្តិធម៌ ជាបញ្ហាដែលវិនិយោគិននៅមានការព្រួយបារម្ភ និងអាចបង្កជាផលលំបាកក្នុងការធានានូវអនុលោមភាព ប្រសិទ្ធភាពក្នុងប្រតិបត្តិការនៃអាជីវកម្ម និងរួមចំណែកដល់ការលើកកម្ពស់ទិដ្ឋភាពចីរភាព។ ក្នុងន័យនេះ កម្ពុជាមានភាពចាំបាច់ក្នុងការពង្រឹងនូវក្របខ័ណ្ឌស្ថាប័ន និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដើម្បីបង្កើនគុណភាពសេវាសាធារណៈ ក្នុងការគាំទ្រដល់ឧស្សាហកម្ម ក៏ដូចជាពង្រឹងទំនុកចិត្តរបស់វិនិយោគិនដែលមានគុណវុធិ។

៣-ឃ្លាស់និងវិធានការយុទ្ធសាស្ត្របរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ

បរិវត្តកម្មឧស្សាហកម្មមានភាពចាំបាច់សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ក្នុងបរិការណ៍នៃការផ្លាស់ប្តូរដែលបានកើតឡើងទាំងបរិយាកាសខាងក្រៅនិងខាងក្នុង នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការរាតត្បាតនៃជំងឺកូវីដ-១៩ បានពន្លឿននូវនិន្នាការអាជីវកម្ម និងគំនិតផ្តួចផ្តើមថ្មីៗ រួមមានការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើចីរភាព បដិវត្តកម្មឧស្សាហកម្មជំនាន់ទី ៤.០ និងការទទួលយកបច្ចេកវិទ្យាជាដើម។ រំហួរពាណិជ្ជកម្មអន្តរជាតិនឹងមានការផ្លាស់ប្តូរ ដោយសារតែការកើនឡើងនៃចរន្តរំកិលទីតាំងផលិតកម្មមកកាន់តែជិតប្រទេសដើម និងកិច្ចខិតខំប្រឹងប្រែងដោយបណ្តាប្រទេសផលិតវាយនភណ្ឌ និងកាត់ដេរធំៗ ដើម្បីពង្រឹងស្វ័យភាពនៃខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងប្រទេសខ្លួនផ្ទាល់។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្ត យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧ កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។ យុទ្ធសាស្ត្រនេះផ្តោតលើគោលដៅអាទិ-ភាពសម្រាប់រយៈពេលខ្លីនិងមធ្យម ដូចខាងក្រោម÷

១-បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករនិយោជិត

២-បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត

៣-លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស

៤-ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ និង
៥-ជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប។

ស្ថានភាពវិវឌ្ឍផ្នែកពាណិជ្ជកម្ម ដូចជាការដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ ពីកម្ពុជាដោយសហភាពអ៊ីរ៉ុប និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីវៀតណាម-សហភាពអ៊ីរ៉ុប អាចនឹងមានផលប៉ះពាល់យ៉ាងខ្លាំងដល់ពាណិជ្ជកម្មផលិតផលវាយនភណ្ឌ និងកាត់ដេរកម្ពុជាផងដែរ។ ម្យ៉ាងវិញទៀត កត្តាខាងក្នុង រួមមានសម្ពាធនៃការកើនឡើងប្រាក់ឈ្នួល ផលិតភាពទាប បញ្ហាផ្ទត់គំនិតក្នុងចំណោមយុវជនទៅលើវិស័យវាយនភណ្ឌ និងកាត់ដេរ និងការយកចិត្តទុកដាក់តិចតួចទៅលើបញ្ហាចីរភាពបរិស្ថានរបស់វិស័យឯកជន ក៏ជាបញ្ហាប្រឈមដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ទាំងពេលបច្ចុប្បន្ននិងអនាគតផងដែរ។ ក្នុងន័យនេះ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧ មានភាពចាំបាច់សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ដើម្បីរក្សាបាននូវភាពប្រកួតប្រជែង និងធានានូវកំណើនប្រកបដោយចីរភាព។

៣.១-គោលបំណង

ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧ ត្រូវបានរៀបចំដោយផ្អែកលើការវាយតម្លៃលើវិស័យវាយនភណ្ឌ និងកាត់ដេរសកល និងកម្ពុជា និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧។ ផែនទីបរិវត្តកម្មនេះ ដើរតួជាឯកសារប្រតិបត្តិគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧ តាមរយៈការដាក់ចេញនូវវិធានការជាក់លាក់សម្រាប់រាជរដ្ឋាភិបាល និងវិស័យឯកជន។

រូបទី២ គោលបំណង និងឃ្លាស់យុទ្ធសាស្ត្រ នៃផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា

ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ ២០២៣-២០២៧ មានគោលបំណងប្រែក្លាយឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ឱ្យមានឧត្តមភាពប្រកួតប្រជែង ដោយផ្តោតលើតម្លៃបន្ថែម ចីរភាព ការប្រើប្រាស់បច្ចេកវិទ្យា ជំនាញ និងសហគ្រិនភាព។ ដើម្បីសម្រេចគោលបំណងខាងលើ ផែនទីបរិវត្តកម្មនេះ បានដាក់ចេញនូវឃ្នាស់យុទ្ធសាស្ត្រចំនួន ៤ រួមមានល្បាយផលិតផលនិងពាណិជ្ជកម្មអន្តរជាតិ ជំនាញនិងបច្ចេកវិទ្យា ចីរភាពនិងនវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធនិងអភិបាលកិច្ច។

៣.២-ឃ្នាស់យុទ្ធសាស្ត្រ និងទិសដៅការយុទ្ធសាស្ត្រ

៣.២.១-ល្បាយផលិតផល និងពាណិជ្ជកម្មអន្តរជាតិ

ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ផលិតសម្លៀកបំពាក់ដែលមានលក្ខណៈសាមញ្ញនិងផ្តោតលើការនាំចេញទៅកាន់ទីផ្សារធំ រួមមានសហភាពអឺរ៉ុប សហរដ្ឋអាមេរិក និងជប៉ុន។ ក្នុងន័យនេះ កម្ពុជាត្រូវតម្រង់ល្បាយផលិតផលរបស់ខ្លួនឱ្យស្របទៅនឹងនិន្នាការប្រភពផ្គត់ផ្គង់អន្តរជាតិ និងជំរុញការធ្វើសមាហរណកម្មប្រតិគមន៍នៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ដើម្បីកាត់បន្ថយការពឹងផ្អែកលើការនាំចូលវត្ថុធាតុដើម និងធ្វើពិពិធកម្មទីផ្សារនាំចេញ។ បន្ថែមពីនេះ កម្ពុជាត្រូវផ្លាស់ប្តូរម៉ូដែលអាជីវកម្មពីប្រភេទស៊ីអិមធីនាពេលបច្ចុប្បន្ន ទៅជាប្រភេទអែហ្វអូប៊ីដែលផ្តល់នូវតម្លៃបន្ថែមខ្ពស់។ ឃ្នាស់យុទ្ធសាស្ត្រនេះ ដាក់ចេញវិធានការសម្រាប់អនុវត្តដូចខាងក្រោម÷

ក-តម្រង់ល្បាយផលិតផលស្របទៅតាមនិន្នាការប្រភពផ្គត់ផ្គង់អន្តរជាតិ

កម្ពុជាគួរផ្តោតលើការអភិវឌ្ឍផលិតផលឱ្យស្របទៅនឹងនិន្នាការប្រភពផ្គត់ផ្គង់អន្តរជាតិ ដូចជាសម្លៀកបំពាក់ដែលមានផលិតពីសសៃប្រភេទអិមអិមអែហ្វ ដែលជាផលិតផលមានតម្លៃបន្ថែមខ្ពស់ និងមានតម្រូវការខ្ពស់លើទីផ្សារអន្តរជាតិ ជំនួសឱ្យសម្លៀកបំពាក់ប្រភេទកប្បាសជាដើម។ បន្ថែមពីនេះ ទីផ្សារនាំចេញសម្លៀកបំពាក់សំខាន់ៗទាំង ៣ របស់កម្ពុជា រួមមានសហរដ្ឋអាមេរិក ជប៉ុន និងអាល្លឺម៉ង់ រួមចំណែករហូតដល់ ៤៧% នៃការនាំចេញសម្លៀកបំពាក់របស់កម្ពុជា។ តួលេខនេះបង្ហាញពីការប្រមូលផ្តុំនៃទីផ្សារនាំចេញសម្លៀកបំពាក់របស់កម្ពុជា ដែលចាំបាច់ត្រូវពង្រីកនិងធ្វើពិពិធកម្ម ដើម្បីជំរុញការធ្វើសមាហរណកម្មកាន់តែប្រសើរឡើងជាមួយនឹងខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរសកល។ ក្នុងន័យនេះ កម្ពុជានឹងជំរុញការអភិវឌ្ឍឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ តាមរយៈការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍផលិតផលនិងពិពិធកម្មទីផ្សារ។

ខ-ជំរុញ និងពន្លឿនសមាហរណកម្មប្រតិគមន៍ទៅក្នុងប្រព័ន្ធអេកូវាយនភណ្ឌ និងកាត់ដេរ

កម្ពុជាត្រូវជំរុញសមាហរណកម្មប្រតិគមន៍នៃវាយនភណ្ឌ និងកាត់ដេរ តាមរយៈការលើកទឹកចិត្តឱ្យមានការផលិតវត្ថុធាតុដើម រួមមានក្រណាត់ និងអំបោះប្រភេទអិមអិមអែហ្វ ដោយខ្លួនឯង ជំនួសឱ្យការនាំចូលវត្ថុធាតុដើមទាំងនេះ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធ លើ

វត្ថុធាតុដើមមួយចំនួនដែលចាំបាច់សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ។ បន្ថែមពីនេះ រាជរដ្ឋាភិបាលនឹងផ្តល់ការគាំទ្រនានាដល់តំបន់សេដ្ឋកិច្ចពិសេស ដែលប្រមូលផ្តុំ និងផ្តោតលើការអភិវឌ្ឍខ្សែច្រវាក់តម្លៃនៃផលិតផលវាយនភណ្ឌ និងកាត់ដេរផងដែរ។ ការជំរុញផលិតកម្មក្នុងស្រុកសម្រាប់ការផលិតវត្ថុធាតុដើមចាំបាច់ខាងលើ នឹងធ្វើឱ្យឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា បង្កើតតម្លៃបន្ថែមខ្ពស់ និងកាត់បន្ថយការពឹងផ្អែកលើការនាំចូលវត្ថុធាតុដើមពីបរទេស។

គ-ជំរុញបរិវត្តកម្មម៉ូដែលអាជីវកម្ម

ប្រព័ន្ធអេកូឡូស៊ីនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា រួមបញ្ចូលគ្រឹះស្ថានរចនាម៉ូដ ស្ទូឌីយ៉ូរចនាម៉ូដ មជ្ឈមណ្ឌលធុរកិច្ច អង្គភាពផលិតកម្មផលិតផលគំរូ និងមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍ផលិតផលជាដើម។ ក្នុងន័យនេះ ភាគីពាក់ព័ន្ធនឹងអនុវត្តកិច្ចសហការ ក្នុងការពង្រឹងយន្តការស្ថាប័ន និងគាំទ្រដល់ប្រព័ន្ធអេកូឡូស៊ីនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរសំដៅសម្រេចបានន្យូវការផ្លាស់ប្តូរម៉ូដែលអាជីវកម្មពីប្រភេទស៊ីអិមធី ទៅអ៊ែហ្វអូប៊ី តាមរយៈការជំរុញឱ្យមានកិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងសហគ្រិនក្នុងស្រុកជាមួយគ្រឹះស្ថានរចនាម៉ូតអន្តរជាតិល្បីៗ ដើម្បីចែករំលែកចំណេះដឹង និងលើកទឹកចិត្តម៉ាកយីហោល្បីៗរបស់បរទេសសំដៅបង្កើតការិយ៍យទិញ-លក់ ការិយាល័យតំណាង ឬស្ទូឌីយ៉ូរចនាម៉ូដនៅកម្ពុជាជាដើម។

ឃ-អភិវឌ្ឍទីផ្សារ

ការអភិវឌ្ឍទីផ្សារមានភាពចាំបាច់សម្រាប់រាជរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីបង្កើនបរិមាណលក់ និងគាំទ្រដល់ការរីកលូតលាស់នៃអាជីវកម្មក្នុងស្រុក ។ សកម្មភាពសម្រាប់ការអភិវឌ្ឍទីផ្សារសម្រាប់ផលិតផលវាយនភណ្ឌ និងកាត់ដេរកម្ពុជា មានដូចខាងក្រោម÷

១-កិច្ចព្រមព្រៀងពាណិជ្ជកម្ម÷ រដ្ឋាភិបាលនឹងពិចារណាប្រកបដោយភាពគ្រប់ជ្រុងជ្រោយក្នុងការជ្រើសរើសប្រទេសដៃគូ ដែលត្រូវចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីឬពហុភាគីជាមួយ។ ជាយុទ្ធសាស្ត្រ កម្ពុជានឹងជ្រើសរើសប្រទេសដៃគូ ដែលផ្តល់ន្យូវប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ និងប្រទេសដែលជាទីផ្សារនាំចូលសម្លៀកបំពាក់ធំៗ ដូចជាសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និងបណ្តាប្រទេសផ្គត់ផ្គង់វត្ថុធាតុដើមជាដើម។

២-សកម្មភាពផ្សព្វផ្សាយទីផ្សារ÷ រាជរដ្ឋាភិបាល និងសមាគមពាណិជ្ជកម្ម នឹងលើកទឹកចិត្តឱ្យមានការតាំងពិព័រណ៍ពាណិជ្ជកម្មធំៗ ការរៀបចំកម្មវិធីទស្សនកិច្ចទៅកាន់ទីផ្សារបរទេសសំខាន់ៗដើម្បីពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម ការអភិវឌ្ឍផលិតផលគំរូថ្មីៗសម្រាប់ការនាំចេញ និងការអភិវឌ្ឍទីផ្សារប៊ីធូប៊ី (Business-to-Business ឬ B2B) សំដៅពង្រីកកិត្យានុភាពនៃផលិតផលវាយនភណ្ឌ និងកាត់ដេរកម្ពុជាទៅកាន់យីហោពិភពលោក។

ង-គាំទ្រសហគ្រិន និងធុរកិច្ចថ្មី

រាជដ្ឋាភិបាល សមាគមពាណិជ្ជកម្ម និងស្ថាប័នអប់រំ នឹងជួយសម្រួលដល់ធុរកិច្ចថ្មី និងអ្នកវិនិយោគក្នុងស្រុក តាមរយៈវិធានការ រួមមាន ១-បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច បង្កើតភាពទាក់ទាញ និងបង្កើនការផ្តល់ដើមទុនដំបូង ២-ពង្រឹងភាពយល់ដឹងក្នុងការកៀរគរថវិកាដូចជា ការប្រើប្រាស់ភាគហ៊ុន ឬកម្ចីដែលមានលក្ខខណៈអនុគ្រោះ ៣-ស្វែងរកធុរកិច្ចថ្មីៗដែលមានសក្តានុពល ដើម្បីផ្តល់ការគាំទ្រលើការបណ្តុះបណ្តាលសមត្ថភាពបន្ថែម ជួយបង្កើតបណ្តាញធុរកិច្ច និងជួយផ្សព្វផ្សាយដើម្បីពង្រីកទីផ្សារ ៤-ជំរុញឱ្យមានការចូលរួមភាគហ៊ុនរវាងសហគ្រិនក្នុងស្រុក និងវិនិយោគិនបរទេស តាមរយៈការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ អនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ញត្តិជាធរមាន ៥-ជំរុញឱ្យមានកិច្ចសហការរវាងរោងចក្រវ-ានភណ្ឌ និងកាតដេរក្នុងស្រុក ជាមួយភ្នាក់ងារថ្នែម្ម៉ូត និងយីហោអន្តរជាតិល្បីៗ និង ៦-លើកកម្ពស់ផលិតផលក្នុងវិស័យថ្នែម្ម៉ូត ឱ្យមានគុណភាពនិងបង្កើតបន្ថែមយីហោក្នុងស្រុក ដើម្បីប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ដែលអាចបង្កើតតម្លៃបន្ថែមខ្ពស់ និង ៧-បញ្ចូលមុខវិជ្ជាសហគ្រិនភាពទៅក្នុងកម្មវិធីសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា និងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈដទៃទៀត។

៣.២.២-ជំនាញ និងបច្ចេកវិទ្យា

ជំនាញ និងបច្ចេកវិទ្យា គឺជាកត្តាគន្លឹះក្នុងការជំរុញបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជាឱ្យបានជោគជ័យប្រកបដោយភាពផ្ទៃផ្ការ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ជំនាញទ្រង់ទ្រាយធំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្មទាំងពេលបច្ចុប្បន្ននិងអនាគត បណ្តុះបណ្តាលធនធានមនុស្សលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងអនុវត្តគំនិតផ្តួចផ្តើមដទៃទៀត ដើម្បីលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីជំនាញក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ។ ឃ្លាស់យុទ្ធសាស្ត្រនេះ បានដាក់ចេញវិធានការសម្រាប់អនុវត្តដូចខាងក្រោម÷

ក-បង្កើតក្របខណ្ឌអភិវឌ្ឍជំនាញសម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ

ក្របខ័ណ្ឌអភិវឌ្ឍជំនាញ ផ្តល់ព័ត៌មានថ្មីៗ និងចាំបាច់នានាពាក់ព័ន្ធនឹងអាជីព តួនាទីការងារ មុខជំនាញដែលមានតម្រូវការខ្ពស់នាពេលបច្ចុប្បន្ននិងអនាគត ព្រមទាំងកម្មវិធីអប់រំបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ដើម្បីរៀបចំនិងផ្សព្វផ្សាយ ក្របខ័ណ្ឌអភិវឌ្ឍជំនាញដល់កម្មករ និយោជក គ្រឹះស្ថានអប់រំថ្នាក់ខ្ពស់គ្រឹះស្ថានបណ្តុះ-បណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ និងរោងចក្រសហគ្រាសនានា។

ខ-បង្កើតថ្នាលសិក្សាបែបឌីជីថល និងកម្មវិធីសិក្សាអនឡាញថ្នាក់ជាតិ សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ

កម្ពុជាជាប្រទេសដែលមានអត្រាអ្នកប្រើប្រាស់ទូរសព្ទចល័តខ្ពស់បំផុតមួយក្នុងពិភពលោក ដោយក្នុងនោះ ភាគរយនៃការប្រើប្រាស់ទូរស័ព្ទប្រភេទស្មាតហ្វូនក្នុងចំណោមអ្នកប្រើប្រាស់ទូរស័ព្ទទាំងអស់ មានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់។ ដូច្នេះ ការរៀនតាមទូរស័ព្ទអាចជាមធ្យោបាយក្នុងការផ្តល់ការអប់រំដ៏មានប្រសិទ្ធភាពមួយជាពិសេសក្នុងចំណោមយុវជនកម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាល និងវិស័យឯកជនពាក់ព័ន្ធនឹងសហការជំរុញការបង្កើតកម្មវិធីសិក្សាដែលមានលក្ខណៈស្តង់ដា លើថ្នាលសិក្សាបែបឌីជីថល និងកម្មវិធីទូរសព្ទ សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ។ មុខវិជ្ជាដែលត្រូវសិក្សា ជាអាទិ៍រួមមានអក្ខរកម្មថ្នាក់មូលដ្ឋាន ចំណេះដឹងលេខនព្វន្ត ជំនាញវិភាគមូលដ្ឋាន ការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្មនិងគណិតវិទ្យា (STEM) ភាសាអង់គ្លេសនិងភាសាចិនកម្រិតមូលដ្ឋាន។

គ-ជំរុញការសិក្សាផ្នែកលើបទពិសោធ និងការអនុវត្តផ្ទាល់

ការសិក្សាផ្នែកលើបទពិសោធ និងការអនុវត្តផ្ទាល់ សម្រាប់រយៈពេលពី ៣ ទៅ ៦ខែ ជាផ្នែកដ៏សំខាន់ នៃការអប់រំនិងការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ជាពិសេសសម្រាប់កម្មវិធីកម្រិតសញ្ញាបត្រ។ ក្នុងន័យនេះ រោងចក្រសហគ្រាសគួរចូលរួមផ្តល់ការលើកទឹកចិត្តដល់សិក្ខាកាមជាកម្មករ និយោជិតរបស់ខ្លួន តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភ ក្នុងអំឡុងពេលកម្មសិក្សា។ ទន្ទឹមនេះ រដ្ឋាភិបាលក៏អាចផ្តល់ការលើកទឹកចិត្តផ្សេងៗបន្ថែមដល់សិក្ខាកាម និងរោងចក្រសហគ្រាសនានាដែលបានចូលរួមកម្មវិធីបណ្តុះបណ្តាល ក្រោយបញ្ចប់វគ្គសិក្សា។

ឃ-ជំរុញរោងចក្រសហគ្រាស ឱ្យបង្កើនការចូលរួមក្នុងការអភិវឌ្ឍជំនាញ

ការធានានូវកិច្ចសហការល្អរវាងឧស្សាហកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាព ដើម្បីធានាថាកម្មវិធីអភិវឌ្ឍន៍ជំនាញនានា មានលក្ខណៈស្របតាមតម្រូវការជាក់ស្តែងរបស់ឧស្សាហកម្ម។ ក្នុងន័យនេះ រោងចក្រសហគ្រាសត្រូវចូលរួមយ៉ាងសកម្មនៅក្នុងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍជំនាញ ដែលរួមមានការវាយតម្លៃតម្រូវការជំនាញ ការរៀបចំផែនការបណ្តុះបណ្តាលការបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាពក្រោយការបណ្តុះបណ្តាល។

ង-ពង្រឹងការផ្សព្វផ្សាយអំពីថ្នាលទីផ្សារការងារ (Job Portals)

ជាមួយនឹងការវិវត្តនៃបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដូចជា ទិន្នន័យធំ និងបញ្ញាសិប្បនិម្មិត វែបសាយការងារ ដូចជា WorkNet, CamHR, Job Cambodia ជាដើម ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជ្រើសរើសបុគ្គលិក និងស្វែងរកការងារ។ ក្នុងន័យនេះ សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និង

ផលិតផលធ្វើដំណើរនៅកម្ពុជា វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានាក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ត្រូវបង្កើនការផ្សព្វផ្សាយអំពីវេបសាយទាំងនេះ ព្រមទាំងរបៀបប្រើប្រាស់ក្នុងចំណោមសិស្ស និស្សិត កម្មករ និយោជិត និងនិយោជក នៅក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលនានា និងនៅតាមពិព័រណ៍ការងារជាដើម។

ច-ផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈដល់អ្នកអភិវឌ្ឍបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងអ្នកវាយតម្លៃការបណ្តុះបណ្តាល

ការផ្តល់វិញ្ញាបនបត្របញ្ជាក់សម្រាប់កម្មវិធីបណ្តុះបណ្តាលលើកកម្ពស់ជំនាញដល់ អ្នកអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងអ្នកវាយតម្លៃការបណ្តុះបណ្តាលជំនាញ នៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ជាកត្តាចាំបាច់ដើម្បីធានានូវគុណភាពបណ្តុះបណ្តាល។ វគ្គបណ្តុះបណ្តាលសម្រាប់អ្នកជំនាញទាំងនេះ គួរផ្តោតលើប្រធានបទនានា ដូចជាក្របខ័ណ្ឌអភិវឌ្ឍន៍ជំនាញសម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ការធ្វើបច្ចុប្បន្នភាពមុខជំនាញតាមតម្រូវការឧស្សាហកម្ម ការអភិវឌ្ឍសម្ភារៈបណ្តុះបណ្តាលដែលមានលក្ខណៈស្តង់ដា បច្ចេកទេសបណ្តុះបណ្តាល បច្ចេកទេសវាយតម្លៃ ជំនាញទីផ្សារឌីជីថល។ល។ អ្នកអភិវឌ្ឍន៍កម្មវិធីសិក្សា គ្រូបណ្តុះបណ្តាល និងអ្នកវាយតម្លៃការបណ្តុះបណ្តាលជំនាញ ត្រូវមានបទពិសោធការងារពាក់ព័ន្ធក្នុងវិស័យនេះ។

ឆ-លើកទឹកចិត្តដល់ការអភិវឌ្ឍជំនាញ

រាជរដ្ឋាភិបាល បាននិងកំពុងលើកទឹកចិត្តដល់វិស័យឯកជនឱ្យវិនិយោគលើការអភិវឌ្ឍជំនាញរបស់កម្មករ និយោជិតរបស់ខ្លួន តាមរយៈកិច្ចសហការជាមួយគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ដោយប្រើប្រាស់យន្តការមូលនិធិអភិវឌ្ឍន៍ជំនាញ។ តាមរយៈយន្តការនេះ និយោជក និងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវដាក់សំណើមកមូលនិធិដើម្បីស្នើសុំការលើកទឹកចិត្តលើការបណ្តុះបណ្តាលជំនាញដល់កម្មករ និយោជិតរបស់ខ្លួន ក្នុងទម្រង់ជា វិភាគទានលើប្រាក់ខែគ្រូ និងអ្នកបណ្តុះបណ្តាល ប្រាក់ឧបត្ថម្ភសិក្ខាកាម សម្ភារៈបណ្តុះបណ្តាល ថ្លៃទឹក ភ្លើង និងចំណាយរដ្ឋបាលដទៃទៀតសម្រាប់ការបណ្តុះបណ្តាល។ ដើម្បីពង្រីកប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពនៃយន្តការនេះ គម្រោងមូលនិធិអភិវឌ្ឍន៍ជំនាញ នឹងត្រូវកែទម្រង់ទៅជាស្ថាប័នមូលនិធិអភិវឌ្ឍន៍ជំនាញនាពេលខាងមុខ។

ជ-បង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យ សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ

បច្ចុប្បន្ន វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា មានក្រុមប្រឹក្សាផ្តល់យោបល់លើជំនាញ (SAB) ដែលមានតំណាង២រូប មកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាជិកមួយចំនួនទៀត ដែលតំណាងឱ្យឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ។ ក្រុមប្រឹក្សានេះ ត្រូវកែទម្រង់ទៅជាក្រុមប្រឹក្សាជំនាញតាមវិស័យ

សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ (Sector Skills Council ឬ SSC) ដែលគ្រប់គ្រងដោយសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា និងមានតំណាងមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត និងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈឯកជន ជាសមាជិកនៃក្រុមប្រឹក្សាថ្មីនេះ។ ក្រុមប្រឹក្សាថ្មីនេះ ត្រូវផ្តោតលើការអភិវឌ្ឍ និងគាំទ្រប្រព័ន្ធអេកូឡូស៊ីជំនាញនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ រួមមានការកំណត់និន្នាការនៃតម្រូវការជំនាញ ការអភិវឌ្ឍជំនាញ ការស្រាវជ្រាវនិងការបោះផ្សាយព័ត៌មានទីផ្សារការងារ ការគាំទ្រដល់ការអភិវឌ្ឍគុណវុធិ និងកម្ម-វិធីបណ្តុះបណ្តាលដែលបំពេញទៅតាមតម្រូវការរបស់និយោជក។

ឈ-បង្កើតមជ្ឈមណ្ឌលឧត្តមភាព

កម្ពុជាត្រូវការកម្លាំងពលកម្មដែលមានជំនាញខ្ពស់ ដើម្បីជំរុញផលិតភាព និងធានាបានន្ទវជ្រភាពកំណើននៃឧស្សាហកម្មនេះ។ មជ្ឈមណ្ឌលឧត្តមភាព គួរបង្កើតឡើងនៅក្នុងបរិវេណរោងចក្រឬគ្រឹះស្ថានបណ្តុះ-បណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈដែលមានស្រាប់ ដើម្បីកែលម្អគុណភាពនៃការបណ្តុះបណ្តាល សំដៅលើកកម្ពស់ស្តង់ដានិងផលិតភាព និងជំរុញនវានុវត្តន៍ និងការរៀនអនុវត្តជាក់ស្តែង នៅក្នុងឧស្សាហកម្មវាយ-នភណ្ឌ និងកាត់ដេរ។ ក្នុងន័យនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា ដើម្បីបង្កើតមជ្ឈមណ្ឌលឧត្តមភាព ដោយចាប់ផ្តើមជំហានដំបូងជាលក្ខណៈគម្រោងសាកល្បងផ្តោតលើ ការបង្កើនផលិតភាពរបស់ប្រតិបត្តិករម៉ាស៊ីនដេរឱ្យមានលក្ខណៈស្តង់ដាសកល។ មជ្ឈមណ្ឌលឧត្តមភាព ក៏អាចដើរតួនាទីជារោងចក្រ ឬមន្ទីរពិសោធន៍ សម្រាប់ការតេស្តសាក-ល្បង និងបង្ហាញពីផលិតផល វិធីសាស្ត្រផលិតកម្ម សុស្សហ្ស៊ែរ និងបច្ចេកវិទ្យាថ្មីផងដែរ។ បន្ទាប់ពីការអនុវត្តគម្រោងសាកល្បងទទួលបានជោគជ័យ រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសមាគមពាណិជ្ជកម្ម នឹងគាំទ្រនិងលើកទឹកចិត្តការអនុវត្តគំរូនេះឱ្យបានទូលំទូលាយនៅតាមរោងចក្រ និងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈផ្សេងទៀត។

ញ-បង្កើនកិច្ចសហការជាមួយស្ថាប័នអន្តរជាតិដែលមានឧត្តមានុវត្តន៍ក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ

កិច្ចសហការជាលក្ខណៈអន្តរជាតិជាមួយស្ថាប័ន ឬអង្គភាពដែលមានឧត្តមានុវត្តន៍លើវិស័យនេះ ដើម្បីសិក្សាផ្ទេរចំណេះដឹងដល់ស្ថាប័ន និងគ្រូបណ្តុះបណ្តាលក្នុងស្រុក ជាកត្តាចាំបាច់មួយដើម្បីជំរុញភាពប្រកួតប្រជែងនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ នឹងជំរុញកិច្ចសហការជាមួយស្ថាប័នអន្តរជាតិដែលមានឧត្តមានុវត្តន៍ ឬកិត្តិនាមក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ក្នុងទម្រង់ជាកិច្ចសហការរវាងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈក្នុងស្រុក ជាមួយគ្រឹះស្ថានបរទេស ការចុះកម្មសិក្សា កិច្ចសហការលើគ្រឿងម៉ាស៊ីននិងបរិក្ខារផលិតកម្ម និងកិច្ចសហការលើបច្ចេកវិទ្យា និងកម្មវិធីសុស្សហ្ស៊ែរជាដើម ដោយប្រើប្រាស់យន្តការភាពជាដៃគូរដ្ឋនិងឯកជន។

៨-អភិវឌ្ឍជំនាញកម្រិតខ្ពស់សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ជួបប្រទះនឹងការប្រែ-ប្រួលយ៉ាងឆាប់រហ័សលើទិដ្ឋភាពបច្ចេកវិទ្យា ទាំងនៅក្នុងផលិតកម្មផ្ទាល់ និងនៅក្នុងប្រព័ន្ធអេកូឡូស៊ីគាំទ្រដល់ឧស្សាហកម្មនេះ។ ក្នុងបរិបទនេះ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរបស់កម្ពុជា ត្រូវអភិវឌ្ឍជំនាញកម្រិតខ្ពស់ទាំងផ្នែកបច្ចេកទេស និងជំនាញទន់ ដើម្បីរក្សានូវភាពប្រកួតប្រជែងរបស់ខ្លួន ដូចខាងក្រោម÷

១-ការចាប់យក និងប្រើប្រាស់វិធីសាស្ត្រផលិតកម្មវិសិដ្ឋ (Lean Manufacturing Adoption) និងវិធីសាស្ត្រ ស៥ (5S Methodologies)[24]÷ ការអនុវត្តវិធីសាស្ត្រផលិតកម្មវិសិដ្ឋ និងវិធីសាស្ត្រ ស៥ មិនត្រឹមរួមចំណែកដល់ការលើកកម្ពស់ផលិតភាពប៉ុណ្ណោះទេ តែថែមទាំងអាចរួមចំណែកដល់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តល់ការគាំទ្រដល់សមាគមវាយនភណ្ឌ សម្លៀកបំពាក់ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា និងវិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា ក្នុងការទាក់ទាញអ្នកជំនាញផ្នែកវិធីសាស្ត្រផលិតកម្មវិសិដ្ឋ និងវិធីសាស្ត្រ ស៥ ពីបរទេស ដើម្បីកសាងសមត្ថភាពអ្នកជំនាញក្នុងស្រុក សំដៅជំរុញការអនុវត្តវិធីសាស្ត្រផលិតកម្មថ្មីនេះ នៅតាមបណ្តារោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា។

២-ការពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំ និងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ÷ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអប់រំ និងបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈជាកត្តាចាំបាច់ដើម្បីអភិវឌ្ឍធនធានមនុស្សនៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជាចាំបាច់ត្រូវកសាងជំនាញបច្ចេកទេសកម្រិតខ្ពស់ និងជំនាញស្នូលសំខាន់ៗដែលចាំបាច់សម្រាប់ផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់ បណ្តុះបណ្តាលអ្នកគ្រប់គ្រងថ្នាក់កណ្តាលឱ្យបានច្រើន ខណៈដែលបច្ចុប្បន្ន អ្នកកាន់មុខតំណែងនេះភាគច្រើនជាជនបរទេស និងអភិវឌ្ឍកម្មវិធីកម្មសិក្សាសញ្ញាបត្រ (Degree apprenticeship programs) ដែលបន្ទាប់ពីបញ្ចប់ការសិក្សា សិក្ខាកាមទទួលបានទាំងសញ្ញាបត្រ ទាំងបទពិសោធការងារ។

៣.២.៣-ចីរភាព និងនិរន្តរភាព

ការអនុវត្តប្រព័ន្ធផលិតកម្មស្អាត ជាកត្តាគន្លឹះមួយដើម្បីធានាបាននូវភាពប្រកួតប្រជែងនៃផលិតផលវាយនភណ្ឌ និងកាត់ដេរកម្ពុជា នៅក្នុងទីផ្សារពិភពលោក។ ក្នុងន័យនេះ រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធចាំបាច់ត្រូវជំរុញការអនុវត្តប្រព័ន្ធផលិតកម្មស្អាត នៅតាមរោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា។ បន្ថែមពីនេះ

[24] ស៥ (5S) រួមមាន សម្រិតសម្រាំង (Sort) សណ្តាប់ធ្នាប់ (Set in order) ស្ថិតស្ថេរ (Sustain) ស្តង់ដារ (Standardize) និងសម្អាត (Shine)

ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ត្រូវចេះចាប់យកកាលានុវត្តភាពបច្ចេកវិទ្យាក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មជំនាន់ ៤.០ ដែលមានលក្ខណៈសមស្របសម្រាប់អនុវត្តក្នុងស្រុក និងត្រូវវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់នវានុវត្តន៍នៅក្នុងឧស្សាហកម្មនេះ។ ឃ្នាស់យុទ្ធសាស្ត្រនេះ បានដាក់ចេញនូវវិធានការសម្រាប់អនុវត្តដូចខាងក្រោម÷

ក-អនុវត្តប្រព័ន្ធផលិតកម្មស្អាត និងប្រកបដោយប្រសិទ្ធភាព

រាជរដ្ឋាភិបាល និងវិស័យឯកជន ត្រូវផ្តោតការយកចិត្តទុកដាក់លើកត្តាចីរភាពបរិស្ថាន នៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា តាមរយៈការផ្លាស់ប្តូរទៅរកប្រព័ន្ធផលិតកម្មស្អាត និងប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ ស្ថាប័នរដ្ឋាភិបាលនិងវិស័យឯកជននឹងជំរុញ÷

១-ការពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងអនុលោមភាពផ្នែកបរិស្ថាន និងសង្គម÷ រាជរដ្ឋាភិបាលចាំបាច់ត្រូវដាក់ចេញនូវច្បាប់ ឬគោលការណ៍ណែនាំអំពីកម្រិតអនុលោមភាពអប្បបរមាផ្នែកសង្គម និងបរិស្ថានផ្នែកតាមការអនុវត្តរបស់ប្រទេសជាដៃគូប្រកួតប្រជែង និងស្តង់ដាអប្បបរមាដែលកំណត់ដោយយីហោល្បីៗរបស់ពិភពលោក ដោយឆ្លងកាត់ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។

២-ការពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គល÷ រាជរដ្ឋាភិបាលនឹងសហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរ-ជាតិ និងអ្នកជំនាញក្នុងវិស័យឧស្សាហកម្ម ដើម្បីអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គល ពាក់ព័ន្ធនឹងអនុលោមភាពផ្នែកបរិស្ថាន និងសង្គម។

៣-ការអនុវត្តគំនិតផ្តួចផ្តើមផលិតកម្មស្អាតដោយមានការចូលរួមពីភាគីពាក់ព័ន្ធ÷ រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សមាគមពាណិជ្ជកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈនានា នឹងសហការរៀបចំ និងអនុវត្តគម្រោងលើកកម្ពស់ផលិតកម្មស្អាត ដែលបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក សារធាតុគីមី ថាមពល និងថាមពលកកើតឡើងវិញ និងកែលម្អបរិយាកាសការងារ និងសុវត្ថិភាពឧស្សាហកម្ម ព្រមទាំងកែលម្អប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន តាមរយៈការកាត់បន្ថយ និងការប្រើប្រាស់ ឬកែច្នៃឡើងវិញ។

ខ-អនុវត្តគំនិតផ្តួចផ្តើមផ្នែកចីរភាពនៅកម្រិតរោងចក្រ

រោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា ត្រូវអនុវត្តគំនិតផ្តួចផ្តើម និងឧត្តមានុវត្តន៍ ដើម្បីលើកកម្ពស់ចីរ-ភាពផ្នែកបរិស្ថាន និងសង្គមនៃប្រតិបត្តិការរបស់ខ្លួន តាមរយៈការអនុវត្តវិធានការ ដូចខាងក្រោម÷

១-បង្កើតគណៈកម្មការចីរភាពផ្នែកបរិស្ថាន និងសង្គម ដែលមានតួនាទី ការទទួលខុសត្រូវ និងសូចនាករគន្លឹះច្បាស់លាស់

២-កសាងសមត្ថភាពទាក់ទងនឹងចីរភាពផ្នែកបរិស្ថាន និងសង្គម តាមរយៈការលើកកម្ពស់ការយល់ដឹងនៅគ្រប់កម្រិត និងគ្រប់ផ្នែកនៃរោងចក្រវាយនភណ្ឌ និងកាត់ដេរ

៣-កំណត់បន្ទាត់មូលដ្ឋាន នៃការវាយតម្លៃសូចនាករផ្នែកបរិស្ថាន (ថាមពល ទឹក កាកសំណល់ សារធាតុគីមី និងការបំពុលខ្យល់ ជាដើម) និងផ្នែកសង្គម (អត្រារងរបួស និងចំនួនម៉ោងបណ្តុះបណ្តាល ជាដើម) និងបង្កើតនិងផ្សព្វផ្សាយផែនការសកម្មភាពសម្រាប់អនុវត្តសូចនាករដែលបានកំណត់

៤-ជំរុញ និងវិនិយោគលើបច្ចេកវិទ្យាសន្សំសំចៃធនធាន និង

៥-តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ដោយផ្អែកលើការប្រមូលទិន្នន័យជាក់ស្តែង និងរៀបចំរបាយការណ៍លទ្ធផល និងផ្សព្វផ្សាយទៅកាន់អ្នកបញ្ជាទិញ និងម្ចាស់យីហោ ជារៀងរាល់ឆ្នាំ។

គ-លើកទឹកចិត្តដល់សកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ និងការទទួលយកបច្ចេកវិទ្យាថ្មីៗ

រាជរដ្ឋាភិបាលនឹងផ្តល់ការលើកទឹកចិត្តដល់ការទទួលបច្ចេកវិទ្យា ឬការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ នៅតាមរោងចក្រ ឬបណ្តុំរោងចក្រ តាមរយៈវិធានការខាងក្រោម÷

១-សម្របសម្រួល និងលើកទឹកចិត្តដល់រោងចក្រកាត់ដេរ និងវានភណ្ឌនានា ឱ្យធ្វើទស្សនកិច្ចដកស្រង់បទ-ពិសោធនៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗនៅក្រៅប្រទេស និងផ្តល់ជំនួយ ឬកម្ចីដល់គម្រោងនវានុវត្តន៍ និងការទទួលយកបច្ចេកវិទ្យាថ្មីៗ ព្រមទាំងផ្តល់ការលើកទឹកចិត្តក្នុងទម្រង់ជាការលើកលែងពន្ធ ឥណទានពន្ធ ឬការកាត់កងចំណាយមួយចំនួនស្របតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណា-ចក្រកម្ពុជា

២-ជំរុញឱ្យមានកិច្ចសហការស្រាវជ្រាវ និងអភិវឌ្ឍន៍រួមគ្នារវាងភាគីពាក់ព័ន្ធ រួមមានរោងចក្រផលិត អ្នករចនាម៉ូដ អ្នកផ្គត់ផ្គង់វត្ថុធាតុដើម អ្នកផ្គត់ផ្គង់បច្ចេកវិទ្យា អ្នកផ្គត់ផ្គង់សារធាតុគីមី និងអ្នកផ្គត់ផ្គង់គ្រឿងបន្ថាស់ ដើម្បីចែករំលែកនិងផ្លាស់ប្តូរចំណេះដឹងនិងគំនិតច្នៃប្រឌិត ឬអភិវឌ្ឍផលិតផល វិធីសាស្ត្រផលិតថ្មីរួមគ្នា និងចុះបញ្ជីកម្មសិទ្ធិបញ្ញា និង

៣-ផ្តល់ការលើកទឹកចិត្តសម្រាប់ការដំឡើង និងអនុវត្តបច្ចេកវិទ្យាផលិតកម្មស្អាត តាមរយៈការបង្កើតនូវមូលនិធិបៃតង ដើម្បីផ្តល់ឥណទានដល់រោងចក្រវាយនភណ្ឌ និងកាត់ដេរ ដែលអនុវត្តប្រព័ន្ធផលិតកម្មស្អាត និងប្រកបដោយប្រសិទ្ធភាព តាមរយៈកិច្ចសហការជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍អន្តរជាតិ។

ឃ-អនុវត្តយន្តការជួល ឬបង់រំលស់គ្រឿងម៉ាស៊ីន

រាជរដ្ឋាភិបាល ឬសមាគមពាណិជ្ជកម្ម នឹងផ្តល់ការឧបត្ថម្ភធន និងបង្កើតយន្តការបង់រំលស់លើការដំឡើងឧបករណ៍បច្ចេកវិទ្យាចាំបាច់មួយចំនួនសម្រាប់ផលិតកម្មវាយនភណ្ឌ និងកាត់ដេរ ដែលវិនិយោគិនពុំមានលទ្ធភាពវិនិយោគលើគ្រឿងម៉ាស៊ីនដោយខ្លួនឯង។ ក្នុងយន្តការនេះ រាជរដ្ឋាភិបាល ឬសមាគមពាណិជ្ជកម្មជាកម្មសិទ្ធិករនៃគ្រឿងម៉ាស៊ីនដែលដំឡើងនៅក្នុងរោងចក្ររបស់វិនិយោគិន ដោយវិនិយោគិនត្រូវបង់ថ្លៃជួលប្រចាំខែដល់ស្ថាប័នរាជរដ្ឋាភិបាលឬសមាគមពាណិជ្ជកម្ម ដើម្បីសងរំលស់ថ្លៃដើមសរុបនៃគ្រឿងម៉ាស៊ីន ដោយបូករួមទាំងការប្រាក់ផងដែរ។ រាជរដ្ឋាភិបាលឬសមាគមពាណិជ្ជកម្មនឹងផ្ទេរកម្មសិទ្ធិនៃគ្រឿងម៉ាស៊ីនខាងលើទៅវិនិយោគិន បន្ទាប់ពីទទួលបានការសងគ្រប់ចំនួន។

ង. ចាប់យក និងអនុវត្តនូវបច្ចេកវិទ្យាបដិវត្តឧស្សាហកម្មជំនាន់ ៤.0 ជាជំហាន

រាជរដ្ឋាភិបាល នឹងលើកទឹកចិត្ត និងគាំទ្រដល់រោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា ដើម្បីចាប់យក និងអនុវត្តជាជំហានន្ទូវបច្ចេកវិទ្យាបដិវត្តឧស្សាហកម្មជំនាន់៤.0 ដូចជា 3D Virtual sampling and prototyping, IoT sensors, Robotic process automation, Big data and analytics (ការវិភាគ និងទិន្នន័យធំ), RFID, Blockchain Technology (បច្ចេកវិទ្យាប្លុកឆេន), Augmented reality (AR) និង virtual reality (VR) applications ជាដើម។ ដើម្បីចាប់យក និងអនុវត្តជាជំហានៗនូវបច្ចេកវិទ្យាទាំង-នេះប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ ដូចខាងក្រោម÷

១- ពង្រឹងកិច្ចសហការប្រកបដោយស៊ីជម្រៅរវាងរាជរដ្ឋាភិបាល សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា និងអ្នកជំនាញឬអ្នកផ្តល់សេវាកម្មសុស្សហ្ស៊ែ្ករ ដើម្បីជំរុញការប្រើ-ប្រាស់សុស្សហ្ស៊ែ្ករចាំបាច់នានា នៅតាមរោងចក្រផលិតខ្នាតតូចនិងមធ្យម

២- ជំរុញកិច្ចសហការរវាងរាជរដ្ឋាភិបាល និងអ្នកផ្គត់ផ្គង់បច្ចេកវិទ្យាអន្តរជាតិ និងរោងចក្រវាយនភណ្ឌ និងកាត់ដេរក្នុងស្រុក ដើម្បីផ្តល់ការបណ្តុះបណ្តាល និងការអនុវត្តជាក់ស្តែងលើការប្រើប្រាស់បច្ចេកវិទ្យាទាំងនោះ តាមរយៈការផ្តល់ថវិកាគាំទ្រ ក្នុងរយៈពេលជាក់លាក់ណាមួយ

៣- បង្កើនការផ្សព្វផ្សាយអំពីការអភិវឌ្ឍនៃបច្ចេកវិទ្យាថ្មីៗ បច្ចេកវិទ្យាបៃតង និងអត្ថប្រយោជន៍នៃបច្ចេកវិទ្យាទាំងនោះ ដល់រោងចក្រវាយនភណ្ឌ និងកាត់ដេរក្នុងស្រុក

៤- អនុវត្តគម្រោងរោងចក្រសាកល្បង ដើម្បីសាកល្បងប្រើប្រាស់បច្ចេកវិទ្យាបដិវត្តឧស្សាហកម្មជំនាន់ ៤.0 ដែលត្រូវប្រើប្រាស់ក្នុងរយៈពេលខ្លី មធ្យម និងវែង ដោយប្រើប្រាស់យន្តការភាពជាដៃគូរដ្ឋ និងឯកជន និង

៥- សហការជាមួយសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា គួររៀបចំការតាំងពិព័រណ៍ និងកម្មវិធីប្រកួតប្រជែងនានា ដើម្បីផ្លាស់ប្តូរចំណេះដឹង និងលើកកម្ពស់ការច្នៃប្រឌិតនៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ដោយផ្តល់ជារង្វាន់ដល់ជ័យលាភី។

៣.២.៤-ហេដ្ឋារចនាសម្ព័ន្ធ និងអភិបាលកិច្ច

សួនឧស្សាហកម្មដែលមានស្រាប់ និងដែលត្រូវអភិវឌ្ឍនាពេលខាងមុខ ចាំបាច់ត្រូវអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធគាំទ្រនានា ដើម្បីគាំទ្រផលិតកម្មប្រកបដោយចីរភាព រក្សាថ្លៃដើមផលិតកម្មទាប និងលើកកម្ពស់ជីវភាពរស់នៅសម្រាប់អ្នករស់នៅក្នុងសួនឧស្សាហកម្ម។ បន្ថែមពីនេះ ភាគីពាក់ព័ន្ធទាំងអស់ចាំបាច់ត្រូវសហការលើកកម្ពស់កិត្តិនាមនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ដើម្បីទាក់ទាញអ្នកមានទេពកោសល្យ និងសហគ្រិនក្នុងស្រុកឱ្យចូលរួមកាន់តែច្រើនក្នុងវិស័យនេះ។ ឃ្លាស់យុទ្ធសាស្ត្រនេះ បានដាក់ចេញនូវធានការសម្រាប់អនុវត្តដូចខាងក្រោម÷

ក-អភិវឌ្ឍឬកែលម្អសួនឧស្សាហកម្ម

រាជរដ្ឋាភិបាល និងសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា នឹងផ្តួចផ្តើមគំនិតក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានាក្នុងសួនឧស្សាហកម្មថ្មី និងកែលម្អសួនឧស្សាហកម្មដែលមានស្រាប់ ដូចជាប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ប្រព័ន្ធគ្រប់គ្រងកាកសំណល់ និងការផ្គត់ផ្គង់ថាមពលអគ្គិសនីជាដើម ដើម្បីរួមចំណែកកាត់បន្ថយថ្លៃដើមផលិតកម្ម ផ្តល់គ្រឿងបរិក្ខារប្រសើរជាងមុនដល់កម្មករ និយោជិតក្នុងការបំពេញការងារ និងកែលម្អសន្ទស្សន៍ចីរភាពបរិស្ថាន។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងផ្តល់ការលើកទឹកចិត្តផ្នែកមិនមែនសារពើពន្ធបន្ថែម សម្រាប់ការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសឬតំបន់សួនឧស្សាហកម្ម ដើម្បីទាក់ទាញ និងប្រមូលផ្តុំសកម្មភាពខ្សែច្រវាក់តម្លៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ និងឧស្សហកម្មគាំទ្រ ដើម្បីជំរុញការអភិវឌ្ឍវិស័យនេះ។

ខ-ជំរុញការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងរ៉ែ និងថាមពល បានអនុម័តលើផែនការមេអភិវឌ្ឍន៍វិស័យអគ្គិសនីនៅកម្ពុជា ឆ្នាំ២០២២-២០៤០។ តាមរយៈផែនការមេនេះ កម្ពុជានឹងវិនិយោគលើទំនើបកម្មក្នុងវិស័យអគ្គិសនីដែលធ្វើឱ្យប្រព័ន្ធអគ្គិសនី ចាប់យកនូវការប្រើប្រាស់អគ្គិសនីពីប្រភពពន្លឺព្រះអាទិត្យបានចំនួន ២៩% ស្មើនឹង ៣ ១០០មេហ្គាវ៉ាត់ នៅឆ្នាំ២០៤០។ ដើម្បីធានានូវចីរភាពនៃការអភិវឌ្ឍវិស័យអគ្គិសនី និងស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី កម្ពុជាត្រូវគ្រប់គ្រងការប្រើប្រាស់ប្រភពថាមពលពីពន្លឺព្រះអាទិត្យឱ្យបានគ្រប់ជ្រុងជ្រោយ។ ក្នុងន័យនេះ ក្រសួងរ៉ែ និងថាមពលកំពុងរៀបចំគោលការណ៍សម្រាប់អនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូល (Rooftop solar energy) នៅកម្ពុជា ដែលគ្រោងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២៣នេះ។ គោលការណ៍នេះនឹងផ្តល់លទ្ធភាពឱ្យរោងចក្រសហគ្រាសប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលក្នុងលក្ខខណ្ឌសមស្របមួយ ដែលអាចរក្សាបាននូវចីរភាព និងស្ថិរភាពវិស័យអគ្គិសនី។ ក្នុងទិដ្ឋភាពចីរភាពបរិស្ថាននេះដែរ កម្ពុជាក៏បានដាក់ឱ្យអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ឆ្នាំ២០២២-២០៣០ ជាផ្លូវការកាលពីខែធ្នូ ឆ្នាំ២០២២ កន្លងទៅផងដែរ។

គ-ជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទិកពហុម៉ូដ

ជាការពិត ការអភិវឌ្ឍនិងលើកកម្ពស់ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទិក មិនត្រឹមតែគាំទ្រនិងជំរុញដល់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសទេ ប៉ុន្តែក៏ជាកម្លាំងចលករដ៏មានសារៈសំខាន់ក្នុងការជំរុញវិស័យឧស្សាហកម្ម និងសេដ្ឋកិច្ចទាំងមូលរបស់ប្រទេសជាតិ។ ក្នុងន័យនេះ កម្ពុជាបាននិងកំពុងរៀបចំផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយកម្ពុជា ឆ្នាំ២០២២-២០៣០ ដែលមានចក្ខុវិស័យបន្តកែលម្អ និងអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទិក ដោយផ្តោតលើការជំរុញការកសាងហេដ្ឋារចនា សម្ព័ន្ធរូបវន្ត និងមិនមែនរូបវន្ត ឆ្ពោះទៅ

រកការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ មានការតភ្ជាប់ខ្ពស់ និងភាពប្រទាក់ក្រឡា ដែលនឹងបន្ថយចំណែកជំរុញ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងបំពេញសេចក្ដីត្រូវការសង្គមសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាបន្ន។ បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏ចាំបាច់ក្នុងការផ្តោតលើការពង្រីកកំពង់ផែទឹកជ្រៅ និងសមត្ថភាពស្ថានីយកុងតឺន័រផងដែរ។ ការបង្កើតមជ្ឈមណ្ឌលឡូជីស្ទិកភ្នំពេញ និងច្រកទ្វារអន្តរជាតិព្រៃវល្លិ-ចិញ្ចរៀប នាពេលខាងមុខ នឹងរួមចំណែកជំរុញការអភិវឌ្ឍឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា តាមរយៈការកាត់បន្ថយពេលវេលា និងថ្លៃដឹកជញ្ជូន។

ឃ-រៀបចំ និងអភិវឌ្ឍភណ្ឌាគារឃ្លាំងស្តុក

រាជរដ្ឋាភិបាលនឹងសិក្សាលទ្ធភាពរៀបចំ និងអភិវឌ្ឍភណ្ឌាគារមានដែនកំណត់ (Bonded warehouse facility) ដើម្បីជួយសម្រួលដល់អ្នកនាំចេញក្នុងការរក្សាទុកសម្ភារៈវត្ថុធាតុដើម ដូចជាអំបោះ ក្រណាត់ ថ្នាំពណ៌ សារធាតុគីមី សម្ភារៈវេចខ្ចប់ជាដើម) សម្រាប់ផលិតកម្ម។ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំឃ្លាំងស្តុកដែលមានទំហំធំ ដើម្បីជួលឱ្យអ្នកនាំចេញសម្លៀកបំពាក់ សម្រាប់រយៈពេលវែងក្នុងតម្លៃសមរម្យ។ ភណ្ឌាគារមានដែនកំណត់នឹងជួយឱ្យអ្នកផលិតអាចរក្សាស្តុកផលិតផលរបស់ខ្លួនជាប្រចាំសម្រាប់នាំចេញទៅកាន់ទីផ្សារគោលដៅ និងកាត់បន្ថយពេលវេលារៀបចំដឹកទំនិញចេញ ដែលការណ៍នឹងរួមចំណែកកក្នុងការបង្កើនចំណែកទីផ្សារនាំចេញផលិតផលវាយនភណ្ឌ និងកាត់ដេរកម្ពុជា។

ង-លើកកម្ពស់ប្រព័ន្ធ និងដំណើរការដែលប្រើបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍

ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ នៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងដំណើរការត្រួតពិនិត្យនិងវាយតម្លៃកាន់តែប្រសើរ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល និងសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា ត្រូវបង្កើនការផ្សព្វផ្សាយដល់រោងចក្រវាយនភណ្ឌ និងកាត់ដេរក្នុងស្រុក ឱ្យយល់ដឹងកាន់តែច្បាស់អំពីថ្នាលចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធអនឡាញ និងវែបសាយ KhmerSME។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏នឹងពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រី ដើម្បីលើកកម្ពស់ការប្រើប្រាស់វិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងបច្ចេក-វិទ្យាឌីជីថល។

ច-ពង្រឹងអភិបាលកិច្ចដែលមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ

យន្តការអភិបាលកិច្ចសម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ចាំបាច់ត្រូវមានកិច្ចសហការទូលំទូលាយរវាងភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់តម្លាភាពក្នុងការសម្រេចនានា ជាពិសេសចំពោះការដាក់ចេញនូវច្បាប់ថ្មីឬការធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់ សង្គតិភាពក្នុងការអនុវត្តច្បាប់ឬបទប្បញ្ញត្តិនានាចំពោះភាគី

ពាក់ព័ន្ធទាំងអស់ និងបទប្បញ្ញត្តិទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាផ្សេងៗនៅក្នុងដំណើរការផលិតកម្ម។ រាជរដ្ឋាភិបាលនឹងពង្រឹងតួនាទីរបស់ភាគីពាក់ព័ន្ធក្នុងវិស័យឯកជន រួមមានសមាគមវាយនភណ្ឌ សម្លៀកបំពាក់ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា និងសមាគមពាក់ព័ន្ធដទៃទៀតនៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា នៅក្នុងវេទិការដ្ឋាភិបាល និងវិស័យឯកជន តាមរយៈការបង្កើតក្រុមការងារចំពោះកិច្ចសម្រាប់វេទិកានេះ។ បន្ថែមពីនេះ រាជរដ្ឋាភិបាលនឹងបង្កើតក្រុមការងារអន្តរក្រសួងមួយតាមភាពចាំបាច់ ឬបង្កើនប្រសិទ្ធភាពនៃយន្តការដែលមានស្រាប់ ដើម្បីពង្រឹងអភិបាលកិច្ចនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ សំដៅដោះស្រាយបញ្ហាប្រឈមជាអាទិភាពនានា។

ឆ-លើកកម្ពស់កិត្តិនាមនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ

រាជរដ្ឋាភិបាល និងរោងចក្រវាយនភណ្ឌ និងកាត់ដេរកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់កិត្តិនាមនៃវិស័យនេះ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នឹងសហការជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា អនុវត្តវិធានការ រួមមាន ១-សហការជាមួយរោងចក្រនានាដែលមានកិត្តិនាមល្អ ដើម្បីផ្សព្វផ្សាយបង្កើនការយល់ដឹងក្នុងចំណោមយុវជនអំពីជម្រើសការងារដែលផ្តល់នូវអត្ថប្រយោជន៍ខ្ពស់ នៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ២-រៀបចំដំណើរទស្សនកិច្ចសិក្សាសម្រាប់សិស្សអនុវិទ្យាល័យ ទៅកាន់រោងចក្រគំរូនៅក្នុងឧស្សាហកម្មវាយ-នភណ្ឌនិងកាត់ដេរ និងការិយាល័យតំណាង ឬសាខាម៉ាកយីហោល្បីៗលំដាប់ពិភពលោក ដើម្បីទាក់ទាញចំណាប់អារម្មណ៍ពួកគេទៅលើគន្លងអាជីពនៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ៣-ជំរុញកិច្ចសហការជាមួយប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ដើម្បីផ្សព្វផ្សាយអំពីឱកាសការងារនៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ និង ៤-អនុវត្តយុទ្ធនាការផ្សព្វផ្សាយនៅតាមសហគមន៍ ដើម្បីចែករម្លែកអំពីឱកាសការងារដែលមាននៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ដោយរំលេចនូវបទពិសោធបុគ្គលជោគជ័យនៅក្នុងវិស័យនេះ។

៤-ការរៀបចំយន្តការស្ថាប័នសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តវិធានការ

ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ចាំបាច់ត្រូវការការកែប្រែរចនាសម្ព័ន្ធ និងពង្រឹងមូលដ្ឋានពិពិធកម្មនិងសមត្ថភាពប្រកួតប្រជែង ដើម្បីបង្កើនការចូលរួមចំណែកដល់គោលដៅអភិវឌ្ឍន៍កាន់តែប្រសើរ។ ការខកខានមិនបានអនុវត្តវិធានការបានដាក់ចេញក្នុងផែនទីបរិវត្តកម្មនេះ ដើម្បីចាប់យកកាលានុវត្តភាពខាងលើ អាចជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍកម្ពុជាក្នុងបរិការណ៍នៃការប្រែប្រួលយ៉ាងឆាប់-រហ័សនៃនិម្មានកម្មតំបន់និងពិភពលោក។

ជាកត្តាសត្យានុម័ត កិច្ចសម្របសម្រួលអន្តរស្ថាប័នជាមួយតួអង្គពាក់ព័ន្ធជាកត្តាចាំបាច់សម្រាប់ការអនុវត្តផែនទីបរិវត្តកម្មនេះដោយជោគជ័យ។ ការរៀបចំយន្តការស្ថាប័នប្រកបដោយកិច្ចសម្របសម្រួល ដែលមានប្រសិទ្ធ-ភាព និងមានភាពប្រទាក់ក្រឡា ជាបុរេលក្ខខណ្ឌដើម្បីឈានទៅសម្រេចគោលបំណងនៃផែនទីបរិវត្តកម្មនេះ។ ដោយសារផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧ នេះ មានលក្ខណៈជាឯកសារប្រតិបត្តិសម្រាប់បម្រើឱ្យការអនុវត្ត យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា

ឆ្នាំ២០២២-២០២៧ ដែលបានដាក់ចេញកាលពីខែកុម្ភៈ ឆ្នាំ២០២២ កន្លងទៅ រាជរដ្ឋាភិបាលនឹងប្រើប្រាស់យន្តការស្ថាប័នដែលមានស្រាប់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឆ្នាំ២០២២-២០២៧ ដើម្បីអនុវត្តផែនទីបរិវត្តកម្មនេះផងដែរ។

៤.១-រចនាសម្ព័ន្ធនៃការរៀបចំយន្តការស្ថាប័ន

រាជរដ្ឋាភិបាលបានពិនិត្យឃើញនូវភាពចាំបាច់ក្នុងការរៀបចំយន្តការអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលនិងតាមដានការអនុវត្តផែនទីបរិវត្តកម្មសម្រាប់វិស័យនេះ ក្រោមការដឹកនាំរបស់គណៈកម្មាធិការគោលនយោ-បាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**គ.ស.ហ.**) ដែលនឹងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើការអនុវត្តវិធានការ ផ្តល់អនុសាសន៍ និងរាយការណ៍ពីវឌ្ឍនភាពជូនប្រមុខរាជរដ្ឋាភិបាល។ ក្នុងដំណាក់កាលអនុវត្តវិធានការ ក្រសួងស្ថាប័នទទួលបន្ទុកត្រូវរៀបចំផែនការសកម្មភាពជាក់លាក់និងពេលវេលាកំណត់ជាក់លាក់តាមមុខសញ្ញាសកម្មភាពនៃវិធានការនីមួយៗ ក្រោមការត្រួតពិនិត្យរបស់ **គ.ស.ហ.** និងមានការសម្របសម្រួលដោយក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តផែនទីបរិវត្តកម្ម ដែលជាផ្នែកមួយនៃយន្តការអន្តរស្ថាប័ន។ រាជរដ្ឋាភិបាល ក៏នឹងប្រើប្រាស់យន្តការដែលមានស្រាប់គឺក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិត ស្បែកជើង និងកាបូប ដែលមានសមាសភាពពីតំណាងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ជំនាញការឯករាជ្យ តំណាងសមាគម និងសហជីពជាដើម ដើម្បីផ្តល់នូវប្រភពធាតុចូលមួយបន្ថែមទៀតសំដៅជួយសម្រួលដល់ការអនុវត្តផែនទីបរិវត្តកម្មនេះឱ្យបានគ្រប់ជ្រុងជ្រោយផងដែរ។

រូបទី៣ រចនាសម្ព័ន្ធនៃការរៀបចំយន្តការស្ថាប័ន



៤.២-ក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រ

ការសម្របសម្រួលអនុវត្តផែនទីបរិវត្តកម្មនេះ នឹងប្រើប្រាស់ក្រុមការងារដែលមានស្រាប់គឺ ក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជាឆ្នាំ២០២២-២០២៧ ឬ «ក្រុមការងារអន្តរស្ថាប័ន» ដែលត្រូវបានបង្កើតឡើង ដោយមានសមាជិកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ហ.** និងមានតួនាទីនិងភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលនិងជំរុញការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) និងក្របខ័ណ្ឌពេលវេលារបស់ក្រសួងស្ថាប័នទទួលបន្ទុក ក្នុងគោលបំណងរៀបចំផែនការសកម្មភាពលម្អិត ដើម្បីអនុវត្ត និងសម្រេចវិធានការនៅក្នុងផែនទីបរិវត្តកម្មនេះ
- សហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុក ដើម្បីផ្តល់ការគាំទ្រដល់ **គ.ស.ហ.** ក្នុងការរៀបចំយន្តការឬក្របខ័ណ្ឌតាមដាននិងវាយតម្លៃ (M&E)នៃការអនុវត្តផែនទីបរិវត្តកម្មនេះ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តផែនទីបរិវត្តកម្មនេះ និងវិស័យកាត់ដេរ ផលិតស្បែកជើង និងការបូប តាមយន្តការដែលមានស្រាប់ មុននឹងបញ្ជូនសំណើទៅ **គ.ស.ហ.** ដើម្បីពិនិត្យ និងបន្តនីតិវិធីជាធរមាន
- សម្របសម្រួលជាមួយ**ក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប** ដើម្បីពិភាក្សាការងារ និងដោះស្រាយរាល់កង្វល់និងបញ្ហាប្រឈមក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ
- បំពេញតួនាទីជាច្រកចេញ ចូលមួយនៃទំនាក់ទំនងសាធារណៈជាមួយដៃគូពាក់ព័ន្ធក្នុងវិស័យវាយ-នភណ្ឌ និងកាត់ដេរ
- រាយការណ៍ជូន **គ.ស.ហ.** អំពីលទ្ធផលនៃការតាមដានវឌ្ឍនភាពការងារនិងការវាយតម្លៃនៃការអនុវត្តផែនទីបរិវត្តកម្ម
- ស្នើសុំការពិនិត្យឡើងវិញនូវផែនទីបរិវត្តកម្មនេះ ក្នុងករណីចាំបាច់ និង
- បំពេញភារកិច្ចដទៃទៀត។

៤.៣-ក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប

ក្នុងការអនុវត្តផែនទីបរិវត្តកម្មនេះដែរ រាជរដ្ឋាភិបាលក៏នឹងប្រើប្រាស់ក្រុមការងារប្រឹក្សាយោបល់ដែលមានស្រាប់គឺ **ក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប** ដែលជាក្រុមការងារចំពោះកិច្ចមួយដែលត្រូវបានបង្កើតឡើង ដើម្បីផ្តល់ប្រភពធាតុចូលមួយផ្សេងទៀត សំដៅជួយសម្រួលដល់ការអនុវត្តផែនទីបរិវត្តកម្មនេះឱ្យមានប្រសិទ្ធភាព ។ ក្រុមការងារនេះ ក៏នឹងបំពេញមុខងារជាផ្នែកមួយនៃប្រព័ន្ធប្រតិតុល្យភាព និងបំពេញបន្ថែម ជាពិសេសការផ្តល់មតិយោបល់និងអនុសាសន៍ជូន **គ.ស.ហ.** លើការអនុវត្តផែនទីបរិវត្តកម្មនេះ។

ក្រុមការងារនេះ មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ផ្តល់មតិយោបល់និងអនុសាសន៍ជូន **គ.ស.ហ.**
- សហការជាមួយក្រុមការងារអន្តរស្ថាប័ន និងក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ធាតុចូល ដើម្បីរៀបចំផែនការសកម្មភាព សម្រាប់ការអនុវត្តផែនទីបរិវត្តកម្មនេះ
- ចូលរួមរៀបចំយន្តការឬក្របខ័ណ្ឌតាមដាននិងវាយតម្លៃ (M&E) សម្រាប់អនុវត្តផែនទីបរិវត្តកម្មនេះ,
- ចូលរួមកិច្ចប្រជុំ ដើម្បីតាមដានលើវឌ្ឍនភាពនៃការអនុវត្តផែនទីបរិវត្តកម្មនេះ
- ក្បៀតគរការគាំទ្រពីភាគីពាក់ព័ន្ធ ទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីជំរុញការអនុវត្តផែនទីបរិវត្តកម្មនេះ និង
- បំពេញភារកិច្ចដទៃទៀត។

៥-សេចក្តីសន្និដ្ឋាន

ដើម្បីពង្រឹងពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងសមត្ថភាពប្រកួតប្រជែង រាជរដ្ឋាភិបាលសម្រេចដាក់ចេញ **ផែនទីបរិវត្តកម្មខ្សាច្រវាកកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧**។ ផែនទីបរិវត្តកម្មនេះផ្តល់នូវទិសដៅរួមសម្រាប់ការអភិវឌ្ឍវិស័យវាយនភណ្ឌ និងកាត់ដេរបន្ថែមទៀត ប្រកបដោយចីរភាព និងបរិយាបន្ន និងជាឯកសារប្រតិបត្តិសម្រាប់បម្រើឱ្យការអនុវត្ត **យុទ្ធសាស្ត្ររតិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងការបូមកម្ពុជាឆ្នាំ២០២២-២០២៧** ដែលរាជរដ្ឋាភិបាលបានដាក់ចេញនាពេលកន្លងមក។

ដើម្បីសម្រេចបាននូវគោលដៅនៃផែនទីបរិវត្តកម្មនេះ ការអនុវត្តវិធានការតម្រូវឱ្យមានកិច្ចសម្រប-សម្រួលអន្តរស្ថាប័នប្រសើរជាងមុន ការប្តេជ្ញា ការចូលរួមយ៉ាងសកម្ម អន្តរសកម្ម និងស្មារតីទទួលខុសត្រូវខ្ពស់ពីក្រសួងស្ថាប័ន និងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ជាពិសេសឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ដោយប្រកាន់ភ្ជាប់នូវអភិក្រម និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ន្លះកញ្ចាក់ ចូតធីក ជ្ងុសក្ដែល ញ្យាឃាល និងឆ ះកាត់** និង **កែឆម្រាស់ខាងក្នុងនិងបង្ហើនមិត្តខាងក្រៅក្នុងស្មារតីពង្រឹងឯករាជ្យនិងអធិបតេយ្យភាពជាតិ**។

ការសម្រេចបាននូវសមិទ្ធផលនៃផែនទីបរិវត្តកម្មនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមផ្លាស់ប្តូរវិស័យនេះឱ្យទៅជាឧស្សាហកម្មមួយ ដែលមានចីរភាពបរិស្ថាន ភាពធន់ តម្លៃបន្ថែមខ្ពស់ កម្លាំងពលកម្មជំនាញ ទីកន្លែងធ្វើការសមរម្យនិងផលិតភាពខ្ពស់ សមាហរណកម្មទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃតំបន់និងពិភពលោក បរិយាកាសធុរកិច្ចល្អនិងភាពជាដៃគូល្អរវាងភាគីរដ្ឋ និយោជក សហជីព និងតួអង្គផ្សេងទៀត។ ផែនទីបរិវត្តកម្មនេះក៏នឹងចូលរួមចំណែកក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែង ជំរុញការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះចាំបាច់ឆ្ពោះទៅសម្រេចបាននូវបង្គោលចរ ឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ផងដែរ॥

ឧបសម្ព័ន្ធ៖ យ្លាស់យុទ្ធសាស្ត្រ និងវិធានការយុទ្ធសាស្ត្រ

យ្លាស់យុទ្ធសាស្ត្រ		វិធានការយុទ្ធសាស្ត្រ	ក្រសួង-ស្ថាប័នទទួលបន្ទុក
១-លក្ខាយផលិតផល និងពាណិជ្ជកម្មអន្តរជាតិ	**២០២៣-២០២៧**	តម្រង់ល្បាយផលិតផលស្របទៅតាមនិន្នាការប្រភពផ្គត់ផ្គង់អន្តរ-ជាតិ (ផលិតផលដែលផ្តល់តម្លៃបន្ថែមខ្ពស់ និងមានតម្រូវការខ្ពស់)	*រដ្ឋាភិបាល*÷ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា *វិស័យឯកជន*÷ TAFTAC
		ជំរុញ និងពន្លឿនសមាហរណកម្មប្រតិគមន៍ទៅក្នុងប្រព័ន្ធអេកូវាយនភ័ណ្ឌ និងកាត់ដេរ	*រដ្ឋាភិបាល*÷ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា *វិស័យឯកជន*÷TAFTAC
		ជំរុញបរិវត្តកម្មម៉ូដែលអាជីវកម្មនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ពីប្រភេទស៊ីអិមធី ទៅអ៊ែហ្វអ្ហូ ប ី	*រដ្ឋាភិបាល*÷ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា *វិស័យឯកជន*÷TAFTAC
		អភិវឌ្ឍទីផ្សារសម្រាប់ផលិតផលវាយនភណ្ឌ និងកាត់ដេរកម្ពុជាតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងវិនិយោគ ព្រមទាំងសកម្មភាពផ្សព្វផ្សាយទីផ្សារ	*រដ្ឋាភិបាល*÷ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា *វិស័យឯកជន*÷TAFTAC

ឃ្លាស់យុទ្ធសាស្ត្រ		១ចាន១ការយុទ្ធសាស្ត្រ	ក្រសួង-ស្ថាប័នទទួលបន្ទុក
		គាំទ្រសហគ្រិន និងធុរកិច្ចថ្មី នៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ	*រដ្ឋាភិបាល*÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ សហ-គ្រាសខ្មែរ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ *វិស័យឯកជន*÷ TAFTAC CAMFEBA
២-ជំនាញ និងបច្ចេកវិទ្យា	**២០២៣-២០២៤**	បង្កើតក្របខ័ណ្ឌអភិវឌ្ឍជំនាញសម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ	*រដ្ឋាភិបាល*÷ NTB/ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឬ ក្រសួងសេដ្ឋ-កិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ *វិស័យឯកជន*÷ TAFTAC CAMFEBA
	២០២៣-២០២៧	បង្កើតថ្នាលសិក្សាបែបឌីជីថល និងកម្មវិធីសិក្សាអនឡាញថ្នាក់ជាតិ សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ	*រដ្ឋាភិបាល*÷ គណៈកម្មាធិការជាតិបណ្តុះបណ្តាល/ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឬ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ *វិស័យឯកជន*÷ TAFTAC/CGTI CAMFEBA
		ជំរុញការសិក្សាផ្នែកលើបទពិសោធន៍ និងការអនុវត្តផ្ទាល់	*រដ្ឋាភិបាល*÷ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងអប់រំ យុវជន និងកីឬ *វិស័យឯកជន*÷ TAFTAC CAMFEBA

ឃ្លាសំយុទ្ធសាស្ត្រ		វិធានការយុទ្ធសាស្ត្រ	ក្រសួង-ស្ថាប័នទទួលបន្ទុក
		ជំរុញរោងចក្រសហគ្រាស ឱ្យបង្កើនការចូលរួមក្នុងការអភិវឌ្ឍជំនាញ	*រដ្ឋាភិបាល÷* គណៈកម្មាធិការជាតិបណ្តុះបណ្តាល/ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឬ្យ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា *វិស័យឯកជន÷* TAFTAC CAMFEBA
	២០២៣-២០២៤	ពង្រឹងការផ្សព្វផ្សាយអំពីថ្នាលទីផ្សារការងារ (Job Portals)	*រដ្ឋាភិបាល÷* ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ/ទីភ្នាក់ងារជាតិមុខរបរ និងការងារ *វិស័យឯកជន÷* TAFTAC CAMFEBA
	២០២៣-២០២៧	ផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈដល់អ្នកអភិវឌ្ឍបណ្តុះបណ្តាល គ្រូបណ្តុះ-បណ្តាល និងអ្នកវាយតម្លៃការបណ្តុះបណ្តាល	*រដ្ឋាភិបាល÷* ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ *វិស័យឯកជន÷* TAFTAC CAMFEBA
		លើកទឹកចិត្តដល់ការអភិវឌ្ឍជំនាញ	*រដ្ឋាភិបាល÷* ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ *វិស័យឯកជន÷* TAFTAC CAMFEBA
	២០២៣-២០២៤	បង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យ សម្រាប់ឧស្សាហកម្មវាយ-នភណ្ឌ និងកាត់ដេរ	*រដ្ឋាភិបាល÷* ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ *វិស័យឯកជន÷* TAFTAC CAMFEBA

ឃ្លាស់យុទ្ធសាស្ត្រ		១ចាងការយុទ្ធសាស្ត្រ	ក្រសួង-ស្ថាប័នទទួលបន្ទុក
		បង្កើតមជ្ឈមណ្ឌលឧត្តមភាព សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ	*រដ្ឋាភិបាល÷* ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ *វិស័យឯកជន÷* TAFTAC/CGTI CAMFEBA
	២០២៣-២០២៧	បង្កើនកិច្ចសហការជាមួយស្ថាប័នអន្តរជាតិដែលមានឧត្តមានុវត្តន៍ក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ	*រដ្ឋាភិបាល÷* ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឬា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ *វិស័យឯកជន÷* TAFTAC CAMFEBA
		អភិវឌ្ឍជំនាញកម្រិតខ្ពស់សម្រាប់ឧស្សាហកម្មវាយនភណ្ឌ និងកាត់-ដេរ	*រដ្ឋាភិបាល÷* ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឬា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ *វិស័យឯកជន÷* TAFTAC CAMFEBA
៣-ចីរភាព និងនវានុវត្តន៍	២០២៣-២០២៧	អនុវត្តប្រព័ន្ធផលិតកម្មស្អាត និងប្រកបដោយប្រសិទ្ធភាព	*រដ្ឋាភិបាល÷* ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *វិស័យឯកជន÷* TAFTAC
		អនុវត្តគំនិតផ្តួចផ្តើមផ្នែកចីរភាពនៅកម្រិតរោងចក្រ	*រដ្ឋាភិបាល÷* ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេក-

ឃ្លាស់យុទ្ធសាស្ត្រ	វិធានការយុទ្ធសាស្ត្រ		ក្រសួង-ស្ថាប័នទទួលបន្ទុក
			វិទ្យា និងនវានុវត្តន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងពាណិជ្ជកម្ម *វិស័យឯកជន÷* TAFTAC
		លើកទឹកចិត្តដល់សកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ និងការចាប់យកបច្ចេកវិទ្យាថ្មីៗ	*រដ្ឋាភិបាល÷* ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេក-វិទ្យា និងនវានុវត្តន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងពាណិជ្ជកម្ម *វិស័យឯកជន÷* TAFTAC
		អនុវត្តយន្តការជួលឬបង់រំលស់គ្រឿងម៉ាស៊ីន	*រដ្ឋាភិបាល÷* ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *វិស័យឯកជន÷* TAFTAC
		ចាប់យក និងអនុវត្តបច្ចេកវិទ្យាបដិវត្តឧស្សាហកម្មជំនាន់៤.០ ទៅឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ក្នុងជាជំហានៗ	*រដ្ឋាភិបាល÷* ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេក-វិទ្យា និងនវានុវត្តន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *វិស័យឯកជន÷* TAFTAC CAMFEBA

ឃ្លាស់យុទ្ធសាស្ត្រ		វិធានការយុទ្ធសាស្ត្រ	ក្រសួង-ស្ថាប័នទទួលបន្ទុក
៤-ហេដ្ឋារចនាសម្ព័ន្ធ និងអតិថិជនកិច្ច	**២០២៣-២០២៧**	អភិវឌ្ឍ ឬកែលម្អតំបន់សេដ្ឋកិច្ចពិសេស និងសួនឧស្សាហកម្ម	*រដ្ឋាភិបាល÷* ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យា-សាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ *វិស័យឯកជន÷* TAFTAC
		ជំរុញការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ	*រដ្ឋាភិបាល÷* ក្រសួងរ៉ែ និងថាមពល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ *វិស័យឯកជន÷* TAFTAC
		អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទិកពហុម៉ូដ	*រដ្ឋាភិបាល÷* ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *វិស័យឯកជន÷* TAFTAC CAMFEBA
		រៀបចំ និងអភិវឌ្ឍភណ្ឌាគារ ឬឃ្លាំងស្តុក	*រដ្ឋាភិបាល÷* ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា *វិស័យឯកជន÷* TAFTAC
		លើកកម្ពស់ប្រព័ន្ធ និងដំណើរការដែលប្រើបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍	*រដ្ឋាភិបាល÷* ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ឃ្លាសំយុទ្ធសាស្ត្រ			ក្រសួង-ស្ថាប័នទទួលបន្ទុក
			វិស័យឯកជន÷ TAFTAC
		ពង្រឹងអភិបាលកិច្ចដែលមានការពិគ្រោះយោបល់ជាមួយភាគីពាក់-ព័ន្ធ	*រដ្ឋាភិបាល÷* គណកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា *វិស័យឯកជន÷* TAFTAC CAMFEBA
		លើកកម្ពស់កិត្តិនាមនៃឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា	*រដ្ឋាភិបាល÷* ក្រសួងពាណិជ្ជកម្ម ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញ-វត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា *វិស័យឯកជន÷* TAFTAC CAMFEBA

សន្ទានុក្រមនៃពាក្យបច្ចេកទេសគន្លឹះក្នុង
ផែនទីបរិវត្តកម្មខ្សែសង្វាក់កម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧

ពាក្យជាភាសាខ្មែរ	ពាក្យជាភាសាអង់គ្លេស	អត្ថន័យ
សរសៃអិមអិមអ៊ីហ្ស	MMF (Man Made Fibers)	ប្រភេទសរសៃសិប្បនិមិត្ត ដែលមានការកែប្រែទៅលើធាតុគីមី ដោយចូលរួមផ្សំ លក្ខណៈរូប និងគ្រោងបង្ក្រាជាដើម ក្នុងដំណើរការផលិត ឧទាហរណ៍ សសៃប៉ូលីយេស្ទើ។
សរសៃធម្មជាតិ	Natural Fibers	ប្រភេទសរសៃដែលបានមកពី សត្ត្ব បន្លែ រុក្ខជាតិ ឬរ៉ែធម្មជាតិផ្សេងៗ ដែលអាចបំលែងទៅជាអំបោះបាន។
សរសៃប៉ូលីស្ទើ	Polyester	ប្រភេទសរសៃសិប្បនិមិត្ត ធ្វើឡើងពីប្លាស្ទិកដែលបំលែងមកពីឥន្ធនៈ។
ថ្ពេច	Ginning	ដំណើរការសម្ងួត និងសម្អាត សរសៃសំឡី ដោយដកចេញនូវគ្រាប់ និងកម្ទេចកម្ទី (ដី គ្រួស ស្លឹកឈើផ្សេងៗ) ដើម្បីទទួលបាននូវសរសៃសំឡីសុទ្ធ។
រង្វឹង/រវៃអំបោះ	Spinning	ដំណើរការរមួលសរសៃផ្សេងៗទៅជាអំបោះដេរ ឬអំបោះចាក់/ត្បាញ។
អ៊ែហ្វអ្ហូប៊ី	FOB (Free-on-Board)	កិច្ចទទួលខុសត្រូវតាមរយៈការព្រមព្រៀងដឹកជញ្ជូនទំនិញ ដែលអ្នកផលិតត្រូវមានទំនួលខុសត្រូវទៅលើទំនិញរហូតដល់វាត្រូវបានបញ្ចូលទៅក្នុងកប៉ាល់ យន្តហោះ ឬយានដឹកជញ្ជូនផ្សេងទៀត ដែលកំណត់ដោយអ្នកបញ្ជាទិញ។
កាត់ដេរនិងតម្រឹម ឬស៊ីអ៊ីមធី	CMT (Cut-Make-Trim)	ជំហាននៃផលិតកម្មដែលកំណត់ដោយ ជំហានទី ១ កាត់: កាត់ទៅតាមពុម្ពគំរូ និង អាចដេរភ្ជាប់បាន ជំហានទី ២ បង្កើត: ដេរភ្ជាប់ផ្នាំងក្រណាត់ និងបង្កើតចេញជារូបរាងសម្លៀកបំពាក់ ជំហានទី៣ តម្រឹម: តម្រឹមរាល់ព្រុយ ឬកែកំហុស និងតម្រូវអោយមានការត្រួតពិនិត្យគុណភាព និងវេចខ្ចប់។
ទីផ្សារប៊ីធូប៊ី	B2B (Business-to-Business) Marketplaces	ទម្រង់អាជីវកម្មដែល ក្រុមហ៊ុនអាជីវកម្មមួយបង្កើតផលិតផល ឬសេវាកម្មដល់ក្រុមហ៊ុនអាជីវកម្មមួយទៀត។
ថ្នាលទីផ្សារការងារ	Job Portals	កន្លែង (អនឡាញ, តាមបណ្តាញអ៊ីនធីណេត) ដែលអាចជួយដល់អ្នកស្វែងរកការងារ និងជួយដល់និយោជកក្នុងការស្វែងរកបេក្ខជនសាកសមនឹងតម្រូវការ ការងាររបស់ខ្លួន។

ប្រព័ន្ធអេកូឡូស៊ីជំនាញ	Skilling Ecosystem	កន្សោម ឬទំនាក់ទំនងរវាងទីផ្សារការងារ ជំនាញវិជ្ជាជីវៈ និងស្ថាប័នបណ្តុះបណ្តាល ដើម្បីគាំទ្រនិរន្តរភាព នវានុវត្តន៍ និងការអភិវឌ្ឍនៅក្នុងតំបន់ណាមួយ។
មជ្ឈមណ្ឌលឧត្តមភាព	Centre of Excellence	កន្លែងដែលរក្សាអោយបាននូវស្តង់ដារខ្ពស់បំផុត ក្រុមដែលមានទំនួលខុសត្រូវដោយឡែកៗពីគ្នា យកចំណេះដែលខ្លួនជំនាញ ដើម្បីជួយផ្នែកដទៃទៀត ដោយផ្តល់ជាគន្លឹះ ការបណ្តុះបណ្តាល និងស្រាវជ្រាវជាដើម ដើម្បីទទួលបាននូវឧត្តមភាព។
កម្មវិធីកម្មសិក្សា សញ្ញាបត្រ	Degree apprenticeship programs	បន្ទាប់ពីបញ្ចប់ការសិក្សា សិក្ខាកាមទទួលបានទាំងសញ្ញាបត្រ ទាំងបទពិសោធការងារ។
វិធីសាស្ត្រផលិតកម្ម វិសិដ្ឋ	Lean Manufacturing Adoption	ការបណ្តុះផ្នត់គំនិតផលិតកម្ម នៃការលប់បំបាត់ភាពខ្ជះខ្ជាយ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផលិតជាអតិបរមា
វិធីសាស្ត្រ ស៥	5S Methodologies	វិធីសាស្ត្រប្រាំជំហាន ដើម្បីបង្កើតកន្លែងការងារដែលមានរបៀបរៀបរយ និងផលិតភាពខ្ពស់ ក្នុងនោះរួមមានសម្រិតសម្រាំង (Sort) សណ្តាប់ធ្នាប់ (Set in order) ស្ថិតស្ថេរ (Sustain) ស្តង់ដារ (Standardize) និងសម្អាត (Shine)។
ប្រព័ន្ធផលិតកម្មស្អាត និងប្រកបដោយប្រសិទ្ធភាព	Resource Efficient Cleaner Production	យន្តការជាបន្តបន្ទាប់ក្នុងការរក្សាការពារបរិស្ថាន នៅក្នុងដំណើរការផលិតផលិតផល និងសេវាកម្ម ដើម្បីបង្កើនប្រសិទ្ធភាព និងកាត់បន្ថយហានិភ័យទៅកាន់មនុស្ស និងបរិស្ថាន។
ខ្សែច្រវាក់ផ្គត់ផ្គង់ប្រកបដោយក្រម-សីលធម៌	Ethical supply chains	ការអនុវត្តដែលផ្តោតទៅលើតម្រូវការសម្រាប់ ទទួលខុសត្រូវសង្គម ការអនុវត្តដើម្បីផលិតនូវផលិតផល និងសេវាកម្ម តាមគោលការណ៍ដែលយកចិត្តទុកដាក់លើកម្មករ និងបរិស្ថានប្រកបដោយគុណធម៌។
សមាហរណកម្មប្រតិ-គមន៍	Backward Integration	ដំណើរការដែលក្រុមហ៊ុនអាជីវកម្ម បន្ថែម ឬរួមបញ្ចូលអាជីវកម្មផ្សេងៗ ដែលអាចផ្គត់ផ្គង់តម្រូវការវត្ថុធាតុដើម សម្រាប់រាល់ដំណើរការផលិត រហូតទទួលបានផលិតផលសម្រេច។